**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**

**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា**

# ការគ្រប់គ្រងឥណទានខ្នាតតូច និងមធ្យម

កម្មសិក្សាពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៩

ឈ្មោះស្ថាប័ន៖ **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករលីមីតធីត សាខា បឹងកេងកង២**


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **ឌុច សុគន្ធារិទ្ធ**

**អ៊ុន យូលៀង**

សាស្ត្រាចារ្យណែនាំ

លោក **អ៊ុន ម៉ារឌី**


ថ្នាក់បរិញ្ញាបត្រ ធនាគារ និងហិរញ្ញវត្ថុ

ជំនាន់ទី ១២

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេររបាយការណ៍ ២០១៩

# សេចក្តីថ្លែងអំណរគុណ

ជាបឋមយើងខ្ញុំទាំងពីរអ្នកឈ្មោះ ឌុច សុគន្ធារិទ្ធ និង អ៊ុន យូលៀង ដែលជានិស្សិតឆ្នាំទី៤ ជំនាន់ទី១២ នៃមហាវិទ្យាល័យ សេដ្ឋកិច្ច ជំនាញហិរញ្ញវត្ថុ និងធនាគារ ដែលបានចូលសិក្សានូវឆ្នាំ ២០១៥-២០១៩ ក្នុងសកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានសរសេររបាយការណ៍កម្មសិក្សាបញ្ចប់សិក្សា សូមធ្វើការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖

លោកឪពុក និងអ្នកម្តាយ យើងខ្ញុំទាំងពីរអ្នកជាពិសេសដែលបានបង្កើតនិងបីបាច់ថែរក្សាទំនុកបម្រុងលើខ្ញុំបាទទាំងពីរអ្នក លើការសិក្សារៀនសូត្រតាំងពីថ្នាក់មត្តេយ្យរហូតមកដល់ថ្នាក់ឧត្តមសិក្សានេះ។ជាងនោះទៅទៀតតែងតែអប់រំ ប្រៀនប្រដៅ និងផ្តល់ដំបូន្មានល្អៗ ដើម្បីឲ្យយើងខ្ញុំទាំងពីរអ្នកក្លាយជា កូនល្អ សិស្សល្អ ពលរដ្ឋល្អ។

គោរពអរគុណទៅដល់ ឯកឧត្តមសាកលវិទ្យាធិការ លុយ ចណ្ណា សាកលវិទ្យាធិការរង និងលោកសាស្រ្តាចារ្យ ព្រមទាំងបុគ្គលិកមន្រ្តីរាជការទាំងអស់ ដែលបានបម្រើការងារនៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលតែងតែណែនាំ បង្ហាត់បង្រៀន ក្នុងគោលបំណងផ្តល់ចំណេះដឹងដល់រូបខ្ញុំបទាំងពីរអ្នកឲ្យមានចំណេះដឹង សមត្ថភាពដើម្បីក្លាយជាទំពាំងស្នងឬស្សី និងអភិវឌ្ឍប្រទេសជាតិឲ្យមានការរីកចម្រើន។

លោកសាស្រ្តចារ្យ អ៊ុន ម៉ារឌី ដែលបានចំណាយពេលដ៏មានតម្លៃរបស់លោកក្នុងការណែនាំផ្តល់យោបល់ល្អៗ រួមជាមួយការផ្តល់នូវឯកសារនានាដែលទាក់ទងនិងប្រធានបទដើម្បីកែតម្រូវ ក្នុងគោលបំណងឲ្យការសរសេររបាយការណ៍មួយនេះមានលទ្ធផលល្អប្រសើរនិងទទួលបានជោគជ័យ។

អគ្គនាយកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករលីមីតធីត នាយកដ្ឋានអភិវឌ្ឍធនធានមនុស្ស ប្រធាននិងបុគ្គលិកសាខាបឹងកេងកងទីពីរ ដែលបានអនុញ្ញាតអោយយើងខ្ញុំចុះទៅធ្វើកម្មសិក្សាស្រាវជ្រាវ និងចំណាយពេលដ៏មានតម្លៃក្នុងការផ្តល់យោបល់ ដំបូន្មាន និងចែករំលែកបទពិសោធន៍ ក៏ដូចជាផ្តល់ឯកសារផ្សេងៗដែលទាក់ទងទៅនឹងប្រធានបទ ដើម្បីជាជំនួយ និង សម្រួលទៅដល់ការសរសេររបាយការណ៍កម្មសិក្សារបស់ក្រុមខ្ញុំទាំងពីរនាក់។

ជាទីបញ្ចប់ យើងខ្ញុំសូមថ្លែងអំណរគុណ និងជូនពរ ទៅដល់ លោកឪពុក អ្នកម្តាយ សកលវិទ្យាធិការ សកលវិទ្យាធិការរង លោកសាស្រ្តាចារ្យ មិត្តនិស្សិតទាំងអស់ និងលោកអគ្គនាយក

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហាត្ថាកសិករ រួមទាំងប្រធានសាខា ឲ្យជួបប្រទះតែសេចក្តីសុខ រកស៊ីមានបាន និងទទួលបាននូវពុទ្ធិពរទាំងបួនប្រការ ពោលគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីបានសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចលើមុខជំនាញធនាគារ និង ហិរញ្ញវត្ថុអស់រយៈពេល៤ឆ្នាំមក ហើយនេះគឺជាឆ្នាំដែលបញ្ចប់ការសិក្សា។ ឆ្លងកាត់តាមការពិភាក្សាយ៉ាងម៉ត់ចត់មកយើងខ្ញុំទាំងពីរនាក់ជានិស្សិតហើយ និងមានទទួលបានការណែនាំពីសំណាក់លោកសាស្រ្តចារ្យ អ៊ុន ម៉ារឌី នោះក្រុមខ្ញុំបាទបានសំរេចចិត្តជ្រើសយកនូវប្រធានបទមួយក្រោមចំណងជើងថា ការគ្រប់គ្រងឥណទានសហគ្រាសធន់តូចនិងមធ្យម(SME Loan )។

មូលហេតុដែលជំរុញទឹកចិត្តអោយក្រុមខ្ញុំជ្រើសយកប្រធានបទនេះ គឺតាមរយៈការសង្កេតឃើញវិស័យហិរញ្ញវត្ថុមិនថាតែជា ធនាគារ ឬជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានដើរតួយ៉ាងសំខាន់ក្នុងការជួយអោយប្រទេសកម្ពុជាយើងមានការរីកចម្រើន។ ក្នុងនោះផងដែរការផ្តល់ឥណទានទៅលើការបើកអាជីវកម្មខ្នាតតូច និងមធ្យមពិតជាសំខាន់ណាស់សម្រាប់ដំណើរការបើកអាជីវកម្មថ្មី ឬបង្កើនដើមទុនដែលជាកត្តាចម្បងក្នុងការជំរុញសេដ្ឋកិច្ចរបស់ខ្លួន។

ហេតុនេះហើយទើបក្រុមខ្ញុំបាទ សម្រេចចិត្តធ្វើការស្រាវជ្រាវលើប្រធានបទនេះឡើងដោយសង្ឃឹមថានឹងអាចជួយដល់ប្អូនៗ និស្សិតដែលមានបំណងចង់យល់ច្បាស់អំពីការគ្រប់ គ្រងឥណទានអាជីវកម្មខ្នាតតូចនិងមធ្យម និងសម្រាប់ទុកធ្វើជាឯកសារជួយដល់ប្អូននិស្សិតដែលមានបំណងចង់សិក្សាស្រាវជ្រាវលើប្រធានបទ ដែលទាក់ទងនិងដំណើរការនិងការគ្រប់គ្រង់ឥណទានអាជីវកម្មខ្នាតតូច និងមធ្យមនេះផងដែរ។

ជាចុងក្រោយនេះ យើងខ្ញុំសូមធ្វើការអភ័យទោសទុកជាមុនចំពោះកំហុសឆ្គងទាំងឡាយដោយសារតែចំណេះដឹងមានកំរិត និងឯកសារដែរប្រមូលបានមិនគ្រប់ជ្រុងជ្រោយ រួមទាំងខ្វះការអនុវត្តជាក់ស្តែងផងនោះដែលអាចបានបណ្តាលអោយមាននូវកំហុសខុសឆ្គងមួយចំនួនកើតឡើង

ហេតុដូចនេះយើងខ្ញុំសូមទទួលរាល់មតិយោបល់ គំនិតដែលបានរិះគន់ក្នុងន័យស្ថាបនាពីសំណាក់គណៈកម្មការ លោក លោកស្រី អ្នកនាង កញ្ញា និងមិត្តនិស្សិតទាំងឡាយដែលបាន

បញ្ចេញមតិយោបល់ផ្សេងៗ ដើម្បីកែលំអរឱ្យការសរសេររបាយការណ៍របស់ក្រុមខ្ញុំបាទមួយនេះទទួលបានលទ្ធផលល្អប្រសើរផងដែរ។

# មាតិកា


បញ្ជីតារាង ......iv
បញ្ជីក្រាហ្វិច ......v
បញ្ជីអក្សរកាត់......vi


# សេចក្តីផ្តើម


១. លំនាំបញ្ហានៃការស្រាវជ្រាវ ......១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ ......១
៣. គោលបំណងនៃការស្រាវជ្រាវ ......២
៤. វិធីសាស្ត្រនៃការស្រាវជ្រាវ ......៣
៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ......៣
៦. សារៈសំខាន់នៃការស្រាវជ្រាវ ......៣
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ......៤


# ជំពូកទី ១
# ទ្រឹស្តីគោល


១.១.ស្ថាប័នមីក្រូហិរញ្ញវត្ថុ......៥
១.១.១ និយមន័យ ......៥
១.១.២ តួនាទីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ......៥
១.១.៣ ផលិតផល និងសេវាកម្ម......៦
១.២ ឥណទាន......៦
១.២.១ និយមន័យ ......៦
១.២.២ ប្រភេទនៃឥណទាន ......៧
១.២.២.១ ឥណទានឯកជន ......៧
១.២.២.២ ឥណទានសាធារណៈ......៧
១.២.៣ តួនាទីរបស់ឥណទាន ......៧
១.២.៤ ការគ្រប់គ្រងឥណទាន ......៨
១.២.៥ គុណសម្បត្តិ និងគុណវិបត្តិ នៃការផ្តល់ឥណទាន......១០
១.២.៥.១ គុណសម្បត្តិនៃការផ្តល់ឥណទាន......១០
១.២.៥.២ គុណវិបត្តិនៃការផ្តល់ឥណទាន......១១
១.២.៧ ហានិភ័យ......១១


# ជំពូកទី ២
# ស្ថានភាពទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត


២.១ ប្រវត្តិសង្ខេបរបស់គ្រឹះស្ថានមីក្រូហត្ថាកសិករ ......១៤
២.២ ទស្សនៈ បេសកម្ម និងតម្លៃស្នូលរបស់ហត្ថាកសិករ លីមីតធីត......១៥

២.៣ និមិត្តសញ្ញារបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ ..........១៧
២.៤ ទីតាំងភូមិសាស្ត្រគ្រឹះស្ថាន ហត្ថាកសិករ..........១៨
២.៥ ផលិតផល និងសេវាកម្មរបស់គ្រឹះស្ថាន ហត្ថាកសិករ..........២០


## ជំពូក ទី៣
## ការគ្រប់គ្រងជាក់ស្តែងទៅលើឥណទានខ្នាតតូច និងមធ្យមរបស់គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត


៣.១ គោលការណ៍ឥណទានសហគ្រាសខ្នាតតូច និងមធ្យម..........២៤
៣.១.១ និយមន័យ..........២៤
៣.១.២ លក្ខណៈសម្បត្តិរបស់អតិថិជន..........២៤
៣.១.៣ លក្ខខណ្ឌនៃអាជីវកម្មដែលសុំបើក..........២៥
៣.១.៤ ការហាមឃាត់អាជីវកម្មនិងអតិថិជន..........២៥
៣.១.៥ តម្រូវការពីអតិថិជន ..........២៥
៣.១.៦ ការរួមចំណែកដើមទុន ..........២៦
៣.២ ការបែងចែកនៃប្រភេទឥណទាន ..........២៧
៣.២.១ការបែងចែកប្រភេទ SME loanតាមគោលបំណងកម្ចី..........២៧
៣.២.២ អត្ថប្រយោជន៍ក្នុងការកំណត់ប្រភេទឥណទាន ..........២៨
៣.៣ ដំណើរការនៃការគ្រប់គ្រងឥណទាន ..........២៩
៣.៣.១ ការផ្សព្វផ្សាយ Promotion..........២៩
៣.៣.២ ការលំអិតព័ត៌មាន នឹងការបំពេញពាក្យស្នើសុំខ្ចីឥណទាន ..........៣០
៣.៣.២.១ លក្ខខណ្ឌទូទៅនៃឥណទាន ..........៣០
៣.៣.២.២ អត្រាការប្រាក់ប្រចាំខែ ..........៣០
៣.៣.២.៣ ការគណនាអត្រាការប្រាក់ ..........៣១
៣.៣.២.៤ រយៈពេលផ្តល់ឥណទាន..........៣១
៣.៣.២.៥ របៀបសងប្រាក់ ..........៣១
៣.៣.២.៦ រយៈពេលអនុគ្រោះ ..........៣១
៣.៣.២.៧ សោហ៊ុយឥណទាន Loan Fee..........៣២
៣.៣.២.៨ ការដាកពិន័យឥណទាន..........៣២
៣.៣.៣ ការចុះស៊ើបអង្កេត និងវាយតម្លៃអតិថិជន ..........៣៣
៣.៣.៣.១ ប្រភេទទ្រព្យដាក់បញ្ចាំ និងលក្ខខណ្ឌតម្រូវ ..........៣៦
៣.៣.៣.២ ការវាយតម្លៃនិងការធានាសុវត្ថិភាពទ្រព្យដាក់ធានា..........៣៨
៣.៣.៤ ការអនុម័តឥណទាន ..........៣៩
៣.៣.៤.១ កម្រិត និងសិទ្ធអនុវត្តឥណទាន..........៣៩

៣.៣.៤.២ មុខងាររបស់គណៈកម្មការឥណទាន ...............................................៣៩
៣.៣.៤.៣ លំហូរការងាររបស់គណៈកម្មាធិការឥណទាន.................................៤០
៣.៣.៤.៤ គណៈកម្មការឥណទាន ............................................................................៤០
៣.៣.៥ ការរៀបចំឯកសារមុនពេលបញ្ចេញឥណទាន ..............................................៤០
៣.៣.៦ ការបញ្ចេញឥណទាន........................................................................................៤១
៣.៣.៧ ការតាមដានអតិថិជន ......................................................................................៤១
៣.៣.៨ ការសងត្រឡប់មកវិញ .....................................................................................៤២
៣.៣.៩ ការសងផ្តាច់ ...................................................................................................៤២
៣.៣.១០ ការដោះស្រាយក្នុងការខកខានសងឥណទានរបស់អតិថិជន ...................៤៣
៣.៤ ការកាត់បន្ថយហានិភ័យលើការផ្តល់ឥណទាន ....................................................៤៣
៣.៤.១ និយមន័យហានិភ័យឥណទាន.........................................................................៤៣
៣.៤.២ វាស់វែងគុណភាពឥណទាន.............................................................................៤៤
៣.៤.៣ យុទ្ធសាស្ត្រក្នុងការកាត់បន្ថយហានិភ័យឥណទាន .......................................៤៥
៣.៤.៤ ការត្រួតពិនិត្យហានិភ័យឥណទាន ..................................................................៤៦

## ជំពូក ទី ៤

## ការវិភាគលើទិន្នន័យនៃការផ្តល់ឥណទានគ្រឹះស្ថានមីក្រូ ហត្ថាកសិករ

៤.១ ស្ថានភាពឥណទានរបស់គ្រឹះស្ថានហិរញ្ញវត្ថុ ហត្ថាកសិករ .....................................៤៨
៤.២ ការវិភាគលើការផ្តល់ឥណទាន SME គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ ............៥០
ចំណុចខ្លាំង ....................................................................................................៥០
ចំណុចខ្សោយ .................................................................................................៥០

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន ..................................................................................................៥២
២.ការផ្តល់អនុសាសន៍.....................................................................................................៥២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីតារាង


តារាងទី ១ : កម្ចីជាប្រាក់ដុល្លារ អាមេរិច ........................................................................ 35

តារាងទី ២ : កម្ចីជាប្រាក់បាត ថៃ ........................................................................ 35

តារាងទី ៣ : កម្ចីជាប្រាក់រៀល ខ្មែរ........................................................................ 35

តារាងទី 4 : ទំហំឥណទានក្នុងរយៈ ៣ឆ្នាំ ចុងក្រោយ ២០១៦ ២០១៧ ២០១៨ .......................... 59

តារាងទី ៥ : ចំនួនអតិថិជនក្នុងរយៈ ៣ឆ្នាំ ចុងក្រោយ ២០១៦ ២០១៧ ២០១៨.......................... 60

## បញ្ជីក្រាភិច


ក្រាបហ្វិចទី I : ក្រាភិចសំរាប់ការចូនរួមទុន

ក្រាបហ្វិចទី II : ក្រាភិចបង្ហាញពីទំហំឥណទានដែលបានបញ្ចេញ

ក្រាបហ្វិចទី III : ចំនួនអតិថិជនដែលទទួលបានឥណទានឆ្នាំ ២០១៦ រហូតដល់ ២០១៨

ក្រាបហ្វិចទី IV : ក្រាភិចបង្ហាញពីទំហំឥណទានដែលបានបញ្ចេញ

# បញ្ជីអក្សរកាត់

- CBC = Credit Bureau Cambodia.
- MFI = Micro Finance Institute.
- MUFG = Mitsubishi UFJ Financial Group.
- BM = Branch Manager
- CCU = Chief of Credit Unit
- HKL = HATTHA KAKSEKAR LIMITED
- IRC = Internal Risk Control
- MCC = Management credit committee
- BCB = Board credit committee
- ICR = Independent Credit Review
- IA = internal Audit
- SME = Small and medium-sized enterprises
- CAMPADRIC = Characteristic; Ability; Margin; Purpose Amount; Document; Risk; Insurer; Collateral
- REALTOR = Right; Estimate; Value; Ability; Location; Type; Ownership, Risk

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហា

ទោះបីជាអតីតកាលរបស់ប្រទេសកម្ពុជា ជាប្រទេសមួយដែលពោរពេញទៅដោយប្រវត្តិកំសត់ដោយសារការឆ្លងកាត់នូវសង្គ្រាមជាច្រើនឆ្នាំ ហើយវាពិតជាបានធ្វើឱ្យប្រទេសមួយនេះធ្លាក់ចុះទៅដល់ចំណុចសូន្យ ពីព្រោះអ្វីៗទាំងអស់ត្រូវបានបំផ្លាញស្ទើរតែទាំងស្រុង។អស់រយៈកាលជាច្រើនឆ្នាំមកនេះយើងសង្កេតឃើញថា សន្តិភាព ស្ថេរភាព ហាក់បីដូចជាបានធ្វើឲ្យដែនដីសុវណ្ណភូមិមួយនេះចាប់ផ្ដើមកែប្រែនូវមុខមាត់ថ្មី ដោយរាជរដ្ឋាភិបាលបានដាក់ចេញនូវយុត្តិសាស្ត្រជាច្រើននៅក្នុងការដឹកនាំធ្វើយ៉ាងណាស្ដារឡើងវិញនូវរាល់វិស័យចម្បងៗ ដើម្បីធ្វើឲ្យមានកំណើនសេដ្ឋកិច្ច។ទន្ទឹមនឹងនេះផងដែរ ការគៀនគរនូវរាល់វិនិយោគិនជាតិ និងអន្តរជាតិឱ្យមកធ្វើការបណ្ដាក់ទុនទៅលើគ្រប់វិស័យរួមមានកសិកម្ម ឧស្សាហកម្ម សេវាកម្ម ទេសចរណ៍ជាពិសេសវិស័យហិរញ្ញវត្ថុ (ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ) និងវិស័យផ្សេងៗទៀតនៅទូទាំងប្រទេសកម្ពុជា។ ក្នុងនោះវិស័យហិរញ្ញវត្ថុ គឺពិតជាមានការរីកចម្រើនគួរឱ្យកត់សំគាល់មិនថាជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងស្រុក ឬជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលជាការវិនិយោគមកពីក្រៅប្រទេសនោះទេ គឺយើងបានមើលឃើញតាមរយៈការរីកដុះដាល ព្រមជាមួយនិងការពង្រីកវិសាលភាពយ៉ាងច្រើនតាមទីជនបទដាច់ស្រយាល ក៏ដូចជារាជធានីភ្នំពេញ ដើម្បីអាចបានផ្ដល់សេវាកម្មហិរញ្ញវត្ថុទៅដល់ដៃប្រជាពលរដ្ឋ ដែលជាអតិថិជននៅទូទាំងប្រទេសកម្ពុជា ក្នុងគោលបំណងដើម្បីជួយឱ្យប្រជាជនកម្ពុជាមានជីវភាពកាន់តែប្រសើរជាងមុនទៀត។

តបតាមការកើនឡើងនៃសេដ្ឋកិច្ចកម្ពុជា ៧% ដោយមានផលិតផលក្នុងស្រុកសរុប (GDP) នៅក្នុងប្រទេសកម្ពុជាបានកើនឡើង 6,90 ភាគរយក្នុងឆ្នាំ 2017 ធៀបនឹងឆ្នាំមុន។[1]កំណើនមួយនេះហើយដែលបានកែប្រែមុខមាត់ប្រទេសកម្ពុជាពីប្រទេសដែលប្រជាជនមានចំណូលទាបកម្រិតខ្ពស់ទៅជាប្រទេសដែលប្រជាជនមានចំណូលមធ្យមកម្រិតទាប។ ក្នុងការរួមចំណែកនៃការរីកចម្រើនឥតឈប់ឈរនេះវិស័យហិរញ្ញវត្ថុបានដើរតួរនាទី និងចូលរួមយ៉ាងសំខាន់ក្នុងការជួយឱ្យប្រទេសកម្ពុជាយើងមានការរីកចម្រើន ជាពិសេសនោះគឺគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលបានជួយកែប្រែជីវភាពប្រជាជនតាមទីជនបទ ពោលគឺជាការផ្ដល់កម្ចីទៅឱ្យពួកគាត់ដើម្បីបំពេញសេចក្ដីត្រូវការនិង ទិញឧបករណ៍ប្រើប្រាស់ផ្សេងៗដែលបម្រើនូវក្នុងវិស័យកសិកម្ម ឧស្សាហកម្មនិងអាជីវកម្មជាដើម។

## ២. ចំណោទបញ្ហា

យើងដឹងហើយថាប្រទេសកម្ពុជាយើងជាប្រទេសមួយ ដែលបានអនុវត្តន៍នូវគោលការណ៍ទីផ្សារសេរីដែលបានផ្ដល់នូវការវិនិយោគដល់អ្នក ដែលមានបំណងចង់មកវិនិយោគនូវកម្ពុជាឱ្យមានភាពងាយស្រួល។ ក្នុងហេតុផលនេះហើយដែលធ្វើឱ្យវិស័យហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា

[1] https://tradingeconomics.com/cambodia/gdp-growth-annual

យើងមានការប្រកួតប្រជែងគ្នាខ្លាំង ពោលគឺមានស្ថាប័នហិរញ្ញវត្ថុជាច្រើនដែលកំពុងតែដណ្ដើមចំណែកទីផ្សារនៅក្នុងប្រទេសកម្ពុជា។ នេះហើយជាមូលហេតុសំខាន់បំផុតដែលបានធ្វើឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីតខិតខំប្រឹងប្រែងអភិវឌ្ឍន៍សមត្ថភាពរបស់ខ្លួនពីមួយថ្ងៃទៅមួយថ្ងៃ ក្នុងគោលបំណងរក្សាអតិថិជនចាស់របស់ខ្លួននិងរិះរកនូវអ្វីដែលថ្មីៗ ដូចជាផ្នែកសេវាកម្ម ផលិតផល ដើម្បីបំពេញតម្រូវការអតិថិជននៅទូទាំងប្រទេសដើម្បីឱ្យប្រជាពលរដ្ឋមានជីវភាពធូរធារ និងជាផ្នែកសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ក្នុងនោះផងដែរការគ្រប់គ្រងទៅលើការផ្តល់ឥណទានបើកអាជីវកម្មខ្នាតតូច និងមធ្យមរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីតក៏មានការប្រកួតប្រជែងខ្លាំង ពីសំណាក់ដៃគូប្រកួតប្រជែងជាច្រើន។ តើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីតមានគោលការណ៍និងនិតិវិធីយ៉ាងណាដើម្បីធ្វើឱ្យផលិតផលឥណទានអាជីវកម្មខ្នាតតូច និងមធ្យមរបស់ខ្លួនទទួលបាននូវការគាំទ្រពីសំណាក់ប្រជាជនទូទៅ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ហេតុផលក្នុងការសិក្សាស្រាវជ្រាវនេះ គឺចង់ទទួលបានចំណេះដឹងបន្ថែមពីលើការសិក្សានៅក្នុងសាលាដោយផ្តោតសំខាន់ទៅលើការគ្រប់គ្រងឥណទាន ទៅលើការបើកអាជីវកម្មខ្នាតតូច និងមធ្យមរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត។ បន្ថែមពីនេះទៅទៀតក៏សិក្សាស្រាវជ្រាវអំពី៖

- ស្ថានភាពទូទៅនិងទីតាំងភូមិសាស្ត្ររបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ
- ដឹងអំពីប្រវត្តិនៃការចាប់ផ្តើមរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ
- គោលការណ៍ និងទ្រឹស្តីទូទៅនូវក្នុងការផ្តល់ឥណទានអាជីវកម្មខ្នាតតូច និងមធ្យម
- ដំណើរការនៃការផ្តល់ឥណទានរបស់ហត្ថាកសិករ

## ៤. វិធីសាស្ត្រនៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទនេះ ដែលជាការបញ្ចូលគ្នារវាងការអនុវត្តផ្ទាល់ជាមួយទ្រឹស្តីក្នុងគោលបំណងធ្វើឱ្យការសិក្សាស្រាវជ្រាវនេះមាន លក្ខណៈល្អប្រសើរក្រុមរបស់យើងខ្ញុំបានប្រើវិធីសាស្ត្រពីរយ៉ាងក្នុងការប្រមូលទិន្នន័យ៖

- **ទិន្នន័យចម្បង (Primary Data)**

គឺជាប្រភពទិន្នន័យចម្បងដែលសំខាន់សំរាប់ការសរសេររបាយការណ៍កម្មសិក្សា ហើយនិងទទួលបានការបង្ហាត់បង្ហាញ ណែនាំ ពីសំណាក់លោកប្រធានសាខា ប្រធានផ្នែកឥណទាននិងបុគ្គលិកប្រចាំសាខារបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ សាខាបឹងកេងកងពីរ។

- **ទិន្នន័យបន្ទាប់បន្សំ (Secondary Data)**

គឺបានមកពីការប្រមូលឯកសារនានានិងភ្ជាប់ទៅលើទ្រឹស្តីដែលបានសិក្សា ៖

ឯកសារមេរៀននិងទទួលបានពីសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

- របាយការណ៍កម្មសិក្សារៀមច្បងជំនាន់មុន។

- ឯកសារពាក់ព័ន្ធទៅនឹងគោលការណ៍ឥណទាន នីតិវិធីផ្តល់ឥណទានដែលបានមកពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហាត្ថាកសិករ នាយកដ្ឋានអនុម័តឥណទាន និងសាខាបឹងកេងកងទីពីរ។
- សៀវភៅគ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- ឯកសារបានមកពីការស្រាវជ្រាវតាមប្រព័ន្ធអ៊ីនធឺណែត។

## ៥. ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ

ឆ្លងកាត់តាមការទទួលបានយោបល់ពីសំណាក់លោកសាស្ត្រាចារ្យ និងការពិភាក្សាក្រុមរបស់ខ្ញុំបាទបានធ្វើការសម្រេចចិត្តកំណត់នូវដែនកំណត់សំរាប់ការស្រាវជ្រាវ គឺធ្វើការស្រាវជ្រាវឥណទានសហគ្រាសខ្នាតតូចនិងមធ្យមរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សាខាបឹងកេងកងទីពីរ រយៈពេលបីឆ្នាំចុងក្រោយ ( ២០១៦ ២០១៧ ២០១៨ ) មកធ្វើការស្រាវជ្រាវពីព្រោះពេលវេលានៃការស្រាវជ្រាវមានកំណត់ ម៉្យាងវិញទៀតវាបង្ករលក្ខណៈងាយស្រួលនូវក្នុងការស្រាវជ្រាវចំពោះក្រុមរបស់ខ្ញុំទទួលបានប្រសិទ្ធភាពខ្ពស់ក្នុងការប្រមូលទិន្នន័យ តាមរយៈការទទួលបានព័ត៌មានពិតទិន្នន័យពិតប្រាកដ ត្រឹមត្រូវ ហើយជាក់លាក់។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

យើងខ្ញុំបាទសង្ឃឹមថាការស្រាវជ្រាវទៅលើប្រធានបទមួយនេះ ពិតជាមានសារៈសំខាន់ខ្លាំង និងអាចផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដូចជា៖

- ពង្រឹងបន្ថែមនូវចំណេះដឹងដែលបានសិក្សារួច ក៏ដូចជាពង្រីកចំណេះដឹងការទទួលបាននូវបទពិសោធន៍ថ្មីៗ ទាក់ទងទៅនឹងការអនុវត្តជាក់ស្តែងនៃ ការផ្តល់ឥណទានខ្នាតតូច និងមធ្យម។
- ស្វែងយល់អំពីដំណើរការផ្តល់ឥណទានរបស់ ហាត្ថាកសិករ។
- បានស្វែងយល់ពីសារៈសំខាន់នៃគ្រឹះស្ថានមីក្រូ ការផ្តល់កម្ចីពិតជាចាំបាច់បំផុតសំរាប់ប្រជាជនកម្ពុជានៅក្នុងការលើកស្ទួយជីវភាពរស់នៅប្រចាំថ្ងៃ។
- សារៈសំខាន់នៃការផ្តល់កម្ចីទៅដល់ប្រជាជន សហគ្រាសខ្នាតតូចនិងមធ្យមដែលជាកត្តាលីករនៅក្នុងការជំរុញឲ្យមានការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសកម្ពុជាផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

គំនូសបំព្រួញនៃការបង្ហាញពីរចនាសម្ព័ន្ធការស្រាវជ្រាវ

**សេចក្ដីផ្ដើម**

↓

**ជំពូកទី ១**
**រំលឹកទ្រឹស្ដី**

↓

**ជំពូកទី ២**
**ស្ថានភាពទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ**

↓

**ជំពូកទី ៣**
**ការគ្រប់គ្រងឥណទានសហគ្រាសខ្នាតតូចនិងមធ្យមរបស់ហត្ថាកសិករ**

↓

**ជំពូកទី ៤**
**ការវិភាគលើទិន្នន័យឥណទានSME**

↓

**សេចក្ដីសន្និដ្ឋាន និងអនុសាសន៍**

# ជំពូកទី ១
# ទ្រឹស្តីគោល

## ១.១ ស្ថាប័នមីក្រូហិរញ្ញវត្ថុ

### ១.១.១ និយមន័យ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ [2] ៖ គឺជាគ្រឹះស្ថានដែលមានឯកទេសក្នុងការផ្តល់សេវាហិរញ្ញវត្ថុ ដូចជាផ្តល់កម្ចីនិងទទួលប្រាក់បញ្ញើ សម្រាប់ក្រុមឬបុគ្គលក្រីក្រនិងមានចំណូលទាបនិងសហគ្រាសធន់តូច។ យោងតាមធនាគារពិភពលោកប្រជាជនប្រមាណ 2 ពាន់លាននាក់នៅទូទាំងពិភពលោកខ្វះលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុពីធនាគារ ឬធនាគារពានិជ្ជ។ហេតុដូចនេះហើយទើបបានជាមានការបង្កើត គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលផ្តល់ប្រាក់កម្ចីខ្នាតតូច ដល់មនុស្សដែលមិនមានលទ្ធភាពទទួលបានឥណទានពីធនាគារ។[3]

### ១.១.២ តួនាទីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានដើរតួរជាផ្នែកមួយយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍប្រទេសជាតិតាមរយៈការបម្រើសេវាផ្នែកហិរញ្ញវត្ថុទៅឱ្យប្រជាជនទូទៅ ក្នុងគោលបំណងធ្វើឱ្យអ្នកដែលជាអតិថិជនទទួលបានជីវភាពកាន់តែល្អប្រសើរពីមួយថ្ងៃទៅមួយថ្ងៃ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានតួនាទី ៖[4]

- តួនាទីអន្តរការី(The Intermediation role)

ការដើរតួនាទីធ្វើជាអាជ្ញាកណ្តាល ដោយបានជួយសម្រួលដល់គ្រួសារ ឬអ្នកដែលមានគោលបំណងយកប្រាក់មកផ្ញើរ និងបង្វែរប្រាក់របស់ពួកគេទៅជាការផ្តល់ឥណទានទៅឱ្យគ្រួសារ និងបុគ្គលដែលត្រូវការខ្ចីប្រាក់ ដើម្បីធ្វើការវិនិយោគជាមួយនឹងគោលដៅបង្កើតប្រាក់ចំណេញ ឬលើកកម្ពស់ជីវភាពរស់នៅរបស់ខ្លួន។

- តួនាទីជាអ្នកអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ត្រូវអនុវត្តតាមគោលនយោបាយសេដ្ឋកិច្ចរបស់រដ្ឋាភិបាល ដោយចូលរួមចំណែកនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ជាពិសេសការអភិវឌ្ឍសេដ្ឋកិច្ចតាមទីជនបទឲ្យបានរីកចម្រើន និងបង្កើនស្តង់ដារនៃការរស់នៅរបស់ពលរដ្ឋនៅក្នុងសង្គម។

- តួនាទីអភិវឌ្ឍន៍ជនបទ(Role of Rural Development)

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានតួនាទីយ៉ាងសំខាន់ ដើម្បីជួយកាត់បន្ថយភាពក្រីក្រនិងបង្កើនជីវភាពរស់នៅរបស់ប្រជាពលរដ្ឋតាមរយៈការផ្តល់កម្ចី ការបណ្តុះបណ្តាលវិជ្ជាជីវៈពិសេសសេវាធានារ៉ាប់រង និងសេវាកម្មផ្សេងៗទៀត។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានចូលរួមនៅក្នុងនាមជាការអភិវឌ្ឍជនបទដូចជា ៖

[2] (https://www.nbc.org.kh/about_the_bank/banking_terms.php)
[3] https://www.calvertimpactcapital.org/blog/683-intro-to-mfis
[4] (https://khemsarith.wordpress.com/blog/page/3/)

- ផ្តល់កម្ចីដល់កសិករទាំងឡាយសម្រាប់ ទិញឧបករណ៍ និងមធ្យោបាយកសិកម្ម។

- អ្នកផ្តល់កម្ចីឲ្យកសិករអាចរក្សាទុក និងអាចលក់ផលិតផលរបស់ពួកគេនៅពេលណាដែលមានតម្លៃសមរម្យ។

- អ្នកផ្តល់កម្ចីសម្រាប់ បង្កើត ពង្រីកនិងកែលម្អរមុខរបររបស់កសិករឲ្យបានប្រសើរឡើង។

- ជួយកាត់បន្ថយការប្រើប្រាស់កម្ចីដែលមានអត្រាការប្រាក់ខ្ពស់ហួសហេតុ (តុងទីន និងការចងការប្រាក់) ដែលធ្វើអោយប៉ះពាល់ដល់ជីវភាពការរស់នៅរបស់ប្រជាជន ។

- ជួយបង្កើនផលិតផលក្នុងស្រុកតាមរយៈការផ្តល់សេវាហិរញ្ញវត្ថុ ដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ចតាមទីជនបទ។ សេវាមីក្រូហិរញ្ញវត្ថុនៅកម្ពុជាក្នុងពេលបច្ចុប្បន្ន នេះរួមមាន សេវាឥណទាន ការសន្សំប្រាក់ និងផ្តល់យោបល់ជូនអ្នកខ្ចីប្រាក់ ដើម្បីឲ្យការប្រើប្រាស់ឥណទានបានត្រឹមត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

### ១.១.៣ ផលិតផល និងសេវាកម្ម របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ស្ថាប័នមីក្រូហិរញ្ញវត្ថុទាំងអស់អាចបង្កើតផលិតផល សេវាកម្មរបស់ខ្លួនបាន លុះត្រាតែបានទទួលបានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា។ ការទទួលបានអាជ្ញាប័ណ្ណអាស្រ័យទៅលើដើមទុនដែលបានតំកល់នៅធនាគារជាតិ និងលក្ខខណ្ឌជាច្រើនទៀត។បច្ចុប្បន្ននេះយើងសង្កេតឃើញថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមាននូវផលិតផលដូចជា កម្ចី បញ្ញើសន្សំ សេវាកម្មទូទាត់ សេវាធានារ៉ាប់រង និងសេវាកម្មហិរញ្ញវត្ថុផ្សេងៗទៀត ។

## ១.២ ឥណទាន

### ១.២.១ និយមន័យ

ឥណទានគឺជាការព្រមព្រៀងរវាងភាគីម្ចាស់បំណុលផ្តល់កម្ចីទៅឲ្យភាគីកូនបំណុល ហើយកូនបំណុលមានកាតព្វកិច្ចត្រូវទូទាត់ប្រាក់ដើមជាមួយការប្រាក់ នៅពេលកំណត់ណាមួយនាពេលអនាគត។ ប្រតិបត្តិការឥណទានគឺជាប្រតិបត្តិការទាំងឡាយណាដែលធ្វើឡើងរវាងម្ចាស់បំណុល និងកូនបំណុល ដែលក្នុងនោះត្រូវមានកាតព្វកិច្ចសងទាំងដើម ទាំងការទៅម្ចាស់បំណុលទៅតាមការកំណត់ច្បាស់លាស់ដែលមានចែងនូវក្នុងកិច្ចសន្យាខ្ចីប្រាក់ ។

លក្ខណៈសំខាន់របស់ឥណទានមាន ៣ គឺ ៖

- ពេលវេលា (TIME) ៖ ជាដែនកំណត់មួយយ៉ាងសំខាន់ ដែលអាចកំណត់ពីទំហំនៃការសងត្រលប់វិញ និងកំណត់ពីកម្រិតហានិភ័យឥណទាន ដែលអាចកើតមានឡើង។

- ការទុកចិត្ត (CONFIDENCE) ៖ ក្នុងការផ្តល់កម្ចីទៅឱ្យអតិថិជន ដែលតម្រូវឱ្យមានទំនុកចិត្ត រវាងគ្នានិងគ្នា ជាពិសេសម្ចាស់បំណុល មុននិងការផ្តល់កម្ចីតម្រូវឱ្យមានការស៊ើបសួរព័ត៌មានអោយបានច្បាស់លាស់ពីអតិថិជន ជៀសវាងមានហានិភ័យណាមួយកើតឡើង។

- ហានិភ័យ (RISK) ៖ ហានិភ័យក្នុងការផ្តល់ឥណទាន គឺអ្នកខ្ចីមិនមានលទ្ធភាពក្នុងការសងបំណុលត្រឡប់មកវិញ ដូចនេះទើបត្រូវឱ្យមានការកំណត់ឥណទានអោយបានច្បាស់លាស់មុន និងសម្រេចចិត្តក្នុងការបញ្ចេញឥណទាន។

### ១.២.២ ប្រភេទនៃឥណទាន

ឥណទានចែកចេញជាពីរប្រភេទ៖

#### ១.២.២.១ ឥណទានឯកជន

ឥណទានឯកជនគឺ ជាប្រភេទឥណទានដែលប្រើសំរាប់បុគ្គល និងសំរាប់អាជីវកម្មដែលត្រូវបានចែកចេញជា៖

➢ ឥណទានសម្រាប់អ្នកប្រើប្រាស់

- ឥណទានរាយ (Retail Credit) ជាប្រភេទឥណទានដែលអ្នកប្រើប្រាស់ទិញទំនិញសម្រេច និងសេវាកម្មដោយផ្ទាល់ពីអ្នកលក់ដោយប្រើប្រាស់ឥណទានបង្វិល កិច្ចសន្យាសងរំលស់ឬឥណទានសេវាកម្ម។

- ឥណទានសាច់ប្រាក់( Cash Credit) ជាឥណទានដែលអ្នកខ្ចីទទួលមូលនិធិពីអ្នកផ្គត់ផ្គង់កម្ចីដោយដោះដូរជាមួយ និងកិច្ចព្រមព្រៀងសងត្រឡប់វិញរួមជាមួយការប្រាក់ឬបន្ទុកហិរញ្ញវត្ថុ។ អតិថិជនច្រើនប្រើមូលនិធិនោះសំរាប់គោលបំណងដូចជាវិស្សមកាល អាពាហ៍ពិពាហ៍ ឬកិច្ចការបន្ទាន់ដែលជាតម្រូវការចាំបាច់ផ្សេងៗ។

- ឥណទានអចលនទ្រព្យ(Real Estate Credit) ជាប្រភេទទីបីនៃឥណទានសំរាប់អ្នកប្រើប្រាស់ក្នុងការទិញអចលនទ្រព្យ ឬបំណងផ្សេងៗដែលក្នុងនោះមូលនិធិដែលផ្តល់ឱ្យអ្នកខ្ចីត្រូវធានាដោយអចលនទ្រព្យដាក់បញ្ចាំសម្រាប់កម្ចី។

➢ ឥណទានអាជីវកម្ម

- ឥណទានសម្រាប់លក់(Merchandise Credit) ជាប្រភេទឥណទានសម្រាប់ទិញទំនិញ វត្ថុធាតុដើម និងសារពើភណ្ឌសំរាប់លក់បន្ត។ ជាទូទៅអតិថិជនទទួលបានទំនិញ ហើយយល់ព្រមទូទាត់តាមលក្ខខណ្ឌលក់និងអនុញ្ញាតឱ្យអតិថិជនទូទាត់តាមពេលវេលាកំណត់។

- មូលនិធិហិរញ្ញវត្ថុសម្រាប់ចាប់ផ្តើមប្រតិបត្តិការអាជីវកម្ម(Financial Capital for Operations) ជាតម្រូវការចាំបាច់សម្រាប់ការចាប់ផ្តើមប្រតិបត្តិការអាជីវកម្មព្រមទាំងពង្រីកវិសាលភាពអាជីវកម្មដែលមានស្រាប់ ។

#### ១.២.២.២ ឥណទានសាធារណៈ

ជាប្រភេទកម្ចីកម្រិតរដ្ឋាភិបាលសម្រាប់ធ្វើហិរញ្ញប្បទាន(ខ្ចីប្រាក់) ទិញទំនិញសេវាកម្ម និងកម្មវិធីសុខុមាលភាពការសង្គ្រោះដល់ប្រជាពលរដ្ឋរបស់ពួកគេ ក៏ដូចជាប្រជាពលរដ្ឋនៅទូទាំងប្រទេសផងដែរ។

### ១.២.៣ តួនាទីរបស់ឥណទាន

ឥណទានមានតួនាទីសំខាន់ៗដូចជា៖

➢ មធ្យោបាយក្នុងការទូទាត់

ប្រព័ន្ធឥណទានដែលប្រើប្រាស់ឧបករណ៍ឥណទានដូចជាកាតឥណទាន (Credit card & master card ) ត្រូវបានប្រើនៅក្នុងសង្គមសម័យទំនើបជំនួសលើការប្រើប្រាស់លុយ។ ដូចគ្នានេះ

ការប្រើប្រាស់កាតឥណទានបានកាត់បន្ថយលើហានិភ័យនៃការបាត់បង់ និងភាពមិនងាយស្រួលដែលពាក់ព័ន្ធនឹងប្រតិបត្តិការទូទាត់ និងលំហូរសាច់ប្រាក់។ ជួយកាត់បន្ថយ ប្រតិបត្តិការសាច់ប្រាក់ និងធ្វើឱ្យវិសាលភាពនៃលំហូរសាច់ប្រាក់អោយកាន់តែទូលំទូលាយ ។

➢ ផ្តល់ជាដើមទុនដល់វិនិយោគគិន

ការផ្តល់ឥណទានដល់វិនិយោគគិន គឺជាការជំរុញអោយមានការធ្វើហិរញ្ញប្បទានក្នុងការផលិតតាមតម្រូវការទីផ្សារជាក់ស្តែង។ សព្វថ្ងៃនេះអ្នកផលិតភាគច្រើនទទួលបានឥណទានពីធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដើម្បីចាប់ផ្តើមនិងពង្រីកប្រតិបត្តិការរបស់ពួកគេ។ សូម្បីតែកសិករ សិប្បករ ពាណិជ្ជករក៏ពឹងផ្អែកលើឥណទានរបស់ធនាគារឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុសម្រាប់ផលិតកម្ម អាជីវកម្មផងដែរ។

➢ ឥណទានពាណិជ្ជកម្មបរទេស

ការទូទាត់នៅក្នុងការជំនួញនៃពាណិជ្ជកម្មទាំងខាងក្នុងនិងខាងក្រៅ ខណៈពេលដែលការទូទាត់ការធ្វើជំនួញនេះអាច ធ្វើឡើងដោយគ្មានការផ្ទេរសាច់ប្រាក់។ ពោលគឺឥណទានពាណិជ្ជកម្មអនុញ្ញាតឱ្យអ្នកទិញធ្វើការទូទាត់ទៅឱ្យអ្នកលក់ សម្រាប់តម្លៃនៃជំនួញ នៅពេលវេលាបន្ទាប់បានដោយគ្រាន់តែមានកិច្ចសន្យាបំណុលរបស់អ្នកទិញជាមួយនិងធនាគារ។

➢ ការផ្តល់ឥណទានពីធនាគារទៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ឥណទានអនុញ្ញាតឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បង្កើតដើមទុនបន្ថែម សម្រាប់ផ្តល់កម្ចីទៅឱ្យអតិថិជនតាមរយៈការខ្ចីប្រាក់ពីធនាគារ នេះក៏ជាហេតុផលមួយជួយឱ្យវិស័យហិរញ្ញវត្ថុមានការរីកចម្រើនផងដែរ។

➢ ការរក្សាស្ថេរភាពហិរញ្ញវត្ថុដល់សហគ្រាសខ្នាតតូច និងមធ្យម

សហគ្រាសខ្នាតតូច និងមធ្យមនិងទទួលបានឥណទានរយៈពេលខ្លីពីធនាគារពាណិជ្ជ ឬគ្រឹះស្ថានមីក្រូហើយទទួលបានឥណទានរយៈពេលវែងពីធនាគារអភិវឌ្ឍន៍។ នេះធ្វើឱ្យពួកគេមិនត្រឹមតែអាចទប់ទល់ នឹងភាពតានតឹងផ្នែកហិរញ្ញវត្ថុបណ្តោះអាសន្នប៉ុណ្ណោះទេ ថែមទាំងដើម្បីរក្សាបាននូវសកម្មភាពអាជីវកម្មរបស់ខ្លួនបន្តទៀត។

➢ ការផ្តល់ឥណទានរបស់ធនាគារដល់រដ្ឋាភិបាល

ការផ្តល់ឥណទានដល់រដ្ឋាភិបាល អាចជួយឱ្យរដ្ឋាភិបាលបំពេញនូវតម្រូវការចាំបាច់និងចាំបាច់សម្រាប់ការផ្គត់ផ្គង់ ក៏ដូចជាការសាងសង់នូវហេដ្ឋារចនាសម្ព័ន្ធក្នុងប្រទេស ដើម្បីធ្វើឱ្យប្រទេសមានការរីកចម្រើន ។

### ១.២.៤ ការគ្រប់គ្រងឥណទាន

ការគ្រប់គ្រងឥណទានគឺជាដំណាក់ការមួយយ៉ាងសំខាន់ ព្រោះវាអាចធ្វើឱ្យមានផលប៉ះពាល់ទៅដល់គ្រឹះស្ថានហិរញ្ញវត្ថុខ្លួនឯង នឹងអតិថិជនដែលមកទទួលកម្ចីហេតុនេះការផ្តល់ឥណទានមួយ ត្រូវតែមានប្រសិទ្ធភាពខ្ពស់ និងមានហានិភ័យទាប។ គ្រឹះស្ថាននីមួយៗត្រូវអនុវត្តន៍តាមនីតិវិធីដូចខាងក្រោមៈ

- **ការផ្សព្វផ្សាយ Promotion**

- ធ្វើការណែនាំអតិថិជន អំពីផលិតផល ក្នុងគោលបំណង់អោយអតិថិជន បានស្គាល់និងបានប្រើប្រាស់ ផលិតផល និង សេវាកម្មរបស់ខ្លួន

- ធ្វើការប្រមូលព័ត៌មានពីអតិថិជន

- ធ្វើការផ្តល់សេវាកម្មជូនអតិថិជនទៅតាមតម្រូវការដែលគាត់ត្រូវការ

- **ការបំពេញពាក្យស្នើសុំខ្ចីឥណទាន**

- រៀបចំបំពេញជូនអតិថិជន(បំពេញចូលទម្រង់ទាំងអស់)

- ថតចំលងអត្តសញ្ញាណប័ណ្ណ និងឯកសារផ្សេងៗ

- ទំនាក់ទំនងសួរភ្នាក់ងារឥណទាន ក្នុងការកំណត់កាលជួបអតិថិជន

- កំណត់ពេលវេលាជួបអតិថិជនទៅដល់លំនៅដ្ឋាន រឺកន្លែងអាជីវកម្មរបស់គាត់។

- **ការចុះស៊ើបអង្កេត និងវាយតម្លៃអតិថិជន**

- វាគឺជាសកម្មភាពយ៉ាងសំខាន់នៅក្នុងការប្រមូលនូវរាល់ព័ត៌មានសំខាន់ ដើម្បីធ្វើការសម្រេចចិត្តថាគួរផ្តល់ឫមិនផ្តល់ឥណទាន។វិធីសាស្ត្រនៅក្នុងការស៊ើបអង្កេត ៖

  - ធ្វើការសាកសួរអ្នករស់នៅជិតខាងពីប្រវត្តិខ្លះៗរបស់អតិថិជន ដោយមិនបង្ហាញពីគោលបំណង ឫសមាសភាពពិតប្រាកដក្នុងគោលបំណងទទួលបានព័ត៌មានពីអតិថិជន។
  - ជម្រើសមួយដែលមានប្រសិទ្ធិភាព គឺភ្នាក់ងារអាចធ្វើការត្រួតពិនិត្យប្រវត្តិរបស់អតិថិជនតាមរយៈប្រព័ន្ធរបស់ក្រុមហ៊ុន Credit Bureau Cambodia (CBC)។

- **ការអនុម័តឥណទាន**

- បន្ទាប់ពីបានធ្វើការស៊ើបអង្កេតបានរួចរាល់ ហើយធានាថាអតិថិជនមានលទ្ធភាពគ្រប់គ្រាន់នៅក្នុងការទទួលបានឥណទាន ភ្នាក់ងារត្រូវធ្វើការរៀបរាប់ទៅកាន់គណៈគ្រប់គ្រង ដើម្បីឱ្យគាត់ធ្វើការពិនិត្យ និងសម្រេចថាគួរផ្តល់ឥណទានដែលរឺទេ?

- ប្រសិនបើឥណទានមិនអាចធ្វើការសម្រេចត្រឹមសាខានោះទេ គាត់ត្រូវធ្វើការបញ្ជូនឯកសារទៅកាន់គណៈកម្មធិការឥណទាន ពីព្រោះឥណទានមួយចំនួនមានទំហំធំ ហើយមានការពាក់ព័ន្ធទៅនឹងហានិភ័យ។

- **ការរៀបចំឯកសារមុនពេលបញ្ចេញឥណទាន**

- រៀបចំឯកសារខ្ចីប្រាក់ និងឯកសារដាក់បញ្ចាំទ្រព្យកម្មសិទ្ធដោយអាននិងពន្យល់ជូនអតិថិជនឱ្យច្បាស់លាស់។

- រៀបចំឱ្យអតិថិជននិងអ្នកធានាផ្តិតមេដៃលើកិច្ចសន្យាជាមួយ និងអត្តសញ្ញាណប័ណ្ណថតចំលងឯកសារត្រូវតែមានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន។

- បន្ទាប់ពីប្រធានសាខាបានពិនិត្យ ផ្ទៀងផ្ទាត់រួចហើយ នោះភ្នាក់ងារត្រូវរៀបចំឯកសារ (តារាងសងរំលោះប្រាក់ និងសៀវភៅតាមដានសងរំលោះប្រាក់) ឱ្យបានរួចរាល់និងកំណត់ពេលវេលា និងទីកន្លែងបញ្ចេញសាច់ប្រាក់។

➢ **ការបញ្ចេញឥណទាន**

- កំណត់និងផ្ទៀងផ្ទាត់អត្តសញ្ញាណអតិថិជនដែលមកទទួលសាច់ប្រាក់
- ពន្យល់ពីតារាងសងប្រាក់ អត្ថប្រយោជន៍ផ្សេងៗ និងគណនាតារាងសងប្រាក់
- បញ្ចេញសាច់ប្រាក់ជូនអតិថិជន
- ថ្លែងអំណរគុណទៅកាន់អតិថិជនចំពោះការប្រើប្រាស់សេវាកម្ម

➢ **ការតាមដានអតិថិជន**

- ភ្នាក់ងារឥណទានត្រូវចុះសួរសុខទុក្ខអតិថិជនយ៉ាងតិចមួយសប្តាហ៍ម្តងក្នុងមួយខែ ក្នុងគោលបំណងសាកសួរពីការវិវត្តមុខរបរ និងសង្កេតមើលការប្រើប្រាស់ឥណទានរបស់គាត់ដើម្បីសរសេររបាយការណ៍ជូនប្រធានសាខា

- ប្រសិនបើអតិថិជនប្រើប្រាស់ឥណទានខុសគោលដៅ នោះភ្នាក់ងារមានសិទ្ធទារបំណុលទាំងអស់ត្រឡប់មកវិញ

➢ **ការសងត្រឡប់មកវិញ**

- ករណីអតិថិជនមកសងត្រឡប់
  - ពិនិត្យសៀវភៅតាមដានការសងប្រាក់ និងកត់ត្រាចំនួនសងក្នុងសៀវភៅឥណទាន
  - ទទួលប្រាក់និងចេញប័ណ្ណជូនអតិថិជន ដោយរំលឹកអតិថិជននូវថ្ងៃសងប្រាក់នៅខែបន្ទាប់
- ករណីអតិថិជនសងយឺត រឺមិនសងត្រឡប់
  - ចុះជួបអតិថិជន សាកសួរពីមូលហេតុដែលមិនមកទូទាត់ប្រាក់ និងបញ្ជាក់ពីគោលការណ៍ករណីអតិថិជនខកខាននៅក្នុងការសងប្រាក់
  - ស្នើសុំឱ្យអតិថិជនរកជំនួយសាច់ប្រាក់ពីសាច់ញាតិ រឺអ្នកធានានិងការលកអចលនទ្រព្យនានា

## ១.២.៥ គុណសម្បត្តិ និងគុណវិបត្តិ នៃការផ្តល់ឥណទាន

### ១.២.៥.១ គុណសម្បត្តិនៃការផ្តល់ឥណទាន

➢ ផ្តល់ភាពងាយស្រួលនិងបង្កើនជីវភាពរស់នៅ:

ការរស់នៅប្រចាំថ្ងៃតែងតែមាននូវតំរូវការទៅលើរបស់ប្រើប្រាស់ ទំនិញ សេវាកម្មជាច្រើនប្រភេទដូច្នេះការទទួលយកកម្ចីជាគន្លឹះមួយដើម្បីឱ្យពួកគេបំពេញសេចក្តីត្រូវការប្រចាំថ្ងៃ។

➢ ដំណោះស្រាយពេលមានអាសន្ន:

នៅពេលដែលពួកគាត់មានបញ្ហាពាក់ព័ន្ធជម្ងឺ ឬអាសន្នផ្សេងៗដែលទាមទារឱ្យប្រើប្រាស់ថវិកា ប្រសិនបើគាត់មិនមានថវិកាគ្រប់គ្រាន់គាត់អាចប្រើប្រាស់ឥណទានក្នុងការដោះស្រាយជាបណ្តោះអាសន្នបាន។

➢ ចំពោះអាជីវកម្ម:

ឥណទានជាជំនួយមួយយ៉ាងសំខាន់សម្រាប់អាជីវកម្មគ្រប់ប្រភេទ ដែលនិយោជិកអាចប្រើប្រាស់ធ្វើជាទុននៅក្នុងការពង្រីកអាជីវកម្ម ការទិញវត្ថុធាតុដើម ឧបករណ៍សម្រាប់ផលិត ការថែរក្សានូវប្រតិបត្តិការអាជីវកម្ម។

➢ ចំពោះសង្គម:

ឥណទានជាប្រេងលំអិលសំរាប់ក្បាលម៉ាស៊ីនសេដ្ឋកិច្ច។ ឥណទានបង្កើតបានជាចលនាសាច់ប្រាក់ និងជាផ្នែកនៃផលិតកម្មនៅក្នុងការជម្រុញកំណើនសេដ្ឋកិច្ច។ ឥណទានតែងផ្តល់នូវមធ្យោបាយ ដើម្បីរក្សាស្ថេរភាពដល់កម្រិតសកម្មភាពសេដ្ឋកិច្ច ដោយធ្វើការកំណត់កម្រិតបន្ទុកហិរញ្ញវត្ថុ(អត្រាការប្រាក់)ខុសៗគ្នា។ ម្យ៉ាងវិញទៀតតួនាទីរបស់ឥណទានមានសារៈសំខាន់ជាពិសេសនៅក្នុងគោលនយោបាយរូបិយវត្ថុដែលមានឥទ្ធិពលលើការចំណាយនិងធ្វើការត្រួតពិនិត្យអត្រាការប្រាក់។ ជាទូទៅយើងហៅថាឥទ្ធិពលម៉ាក្រូសេដ្ឋកិច្ច។

### **១.២.៥.២ គុណវិបត្តិនៃការផ្តល់ឥណទាន**

នៅក្នុងពិភពលោកជាក់ស្តែងឥណទានអាចនាំមកនូវផលអាក្រក់ នៅពេលដែលយើងប្រើប្រាស់វាមិនបានត្រឹមត្រូវ ហើយវាក៏បានចោទជាបញ្ហាជាច្រើនសំរាប់អ្នកប្រើប្រាស់ អាជីវកម្ម និងសង្គមទាំងមូលផងដែរ។

- ចំពោះអ្នកប្រើប្រាស់ ៖ អាចប្រឈមនឹងការបាត់បង់នូវកេរ្តិ៍ឈ្មោះនៅក្នុងការខ្ចីឥណទាន ការបាត់បង់នូវទ្រព្យដាក់បញ្ចាំ ប៉ះពាល់ទៅដល់ការចំណាយប្រចាំថ្ងៃ។

- ចំពោះអាជីវកម្ម ៖ អាចប្រឈមនឹងបំណុលយ៉ាងធ្ងន់ធ្ងរ ប្រសិនបើអាជីវករប្រើប្រាស់ឥណទានមិនបានចំគោលដៅ ជាពិសេសពួកគាត់អាចប្រឈមនឹងការបាត់បង់មុខជំនួញ ពីព្រោះនៅពេលដែលគាត់យកឥណទានទៅប្រើប្រាស់ត្រូវទូទាត់ត្រឡប់មកវិញទាំងការប្រាក់និងប្រាក់ដើម។

- ចំពោះសង្គម ៖ ក៏អាចជួបនិងវិបត្តិហិរញ្ញវត្ថុដែលអាចបណ្តាលឱ្យកើតមានវិបត្តិសេដ្ឋកិច្ចចំពោះប្រទេសផងដែរ ប្រសិនបើរដ្ឋាភិបាលមិនបានយកចិត្តទុកដាក់ទៅលើការប្រើប្រាស់ឥណទាន ឬមិនមានវិធានការណ៍ចំពោះបម្រើបម្រាស់ឥណទាននៅក្នុងប្រទេសទាំងមូល។

## **១.២.៦ ហានិភ័យ**

ហានិភ័យឥណទាន គឺជាហានិភ័យមួយក្នុងចំណោមហានិភ័យនានាដែលមានឥទ្ធិពលទៅដល់ដំណើរការប្រតិបត្តិការ ប្រព្រឹត្តិទៅរបស់គ្រឹះស្ថានមីក្រូដែលវាកើតឡើងដោយអ្នកខ្ចីមិនសងលុយរួមមានប្រាក់ដើម និងការប្រាក់ទៅគ្រឹះស្ថានតាមការកំណត់។ ហានិភ័យឥណទានជាហានិភ័យមួយដែលគ្រឹះស្ថានយកចិត្តទុកដាក់ជាងគេ ព្រោះហានិភ័យនេះអាចជួយជំរុញឱ្យគ្រឹះស្ថានក្ស័យធន។ ដូចនេះមុននឹងសម្រេចចិត្តផ្តល់ឥណទាន គ្រឹះស្ថានតែងតែសិក្សាទៅលើហានិភ័យឥណទានជាចំបង លុះត្រាតែគ្រឹះស្ថានឃើញថាគ្មានហានិភ័យឬហានិភ័យទាបទើបគ្រឹះស្ថានផ្តល់កម្ចីដល់អតិថិជន។

➢ មូលហេតុដែលបណ្តាលឱ្យមានហានិភ័យឥណទានមាន៤យ៉ាង៖

- **កត្តាអតិថិជន** ៖ អតិថិជនមិនបានអនុវត្តន៍តាមគោលការណ៍នៃកិច្ចសន្យាដែលបានកំណត់ដោយគ្រឹះស្ថានហិរញ្ញវត្ថុ ឬប្រើប្រាស់កម្ចីខុសគោលបំណង។

ឧទាហរណ៍៖ អតិថិជនបានខ្ចីប្រាក់ពីស្ថាប័ន ដោយក្នុងគោលបំណងយកទៅបង្កើតអាជីវកម្មរោងចក្រតម្បាញ តែអតិថិជនបែរជាយកលុយនោះទៅទិញរថយន្តសំរាប់ប្រើប្រាស់ផ្ទាល់ខ្លួនទៅវិញ ដែលជាហេតុធ្វើអោយអតិថិជនមិនមានលទ្ធភាពក្នុងសងបំណុល។

- **កត្តាគ្រឹះស្ថាន** ៖ បុគ្គលិកមិនបានអនុវត្តន៍ តាមគោលការណ៍របស់គ្រឹះស្ថានដែលកំណត់។

ឧទាហរណ៍៖ បុគ្គលិករបស់ស្ថាប័នបានក្លែងបន្លំឯកសារជាមួយស្ថាប័ន ដោយបានឃុបខិតជាមួយអតិថិជន ដើម្បីទទួលបានបុព្វលាភណាមួយពីអតិថិជន ឬ បុគ្គលិកផ្ទាល់មិនបំណង លួចបន្លំស្ថាប័នដោយការប្រើប្រាស់ឈ្មោះអតិថិជនក្លែងក្លាយមកខ្ចីប្រាក់។

- **កត្តាសង្គម** ៖ សន្តិភាព សន្តិសុខគឺជាកត្តាសំខាន់ចំពោះអតិថិជន និងគ្រឹះស្ថានផងដែរ ពីព្រោះពួកគាត់ទទួលយកកម្ចីដើម្បីរកស៊ី បើសង្គមនោះអសុវត្ថិភាព នោះប្រាកដជាប៉ះពាល់ទៅដល់ការរកចំណូលរបស់ពួកគាត់ ហើយក៏អាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅដល់កម្ចីរបស់គ្រឹះស្ថាន។

- **កត្តាធម្មជាតិ** ៖ ធម្មជាតិជាកត្តាមួយ ដែលមិនអាចកំណត់បានឡើយ ដែលបណ្តាលមកពីគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ។-ល-។

ឧទាហរណ៍៖ អតិថិជនបានខ្ចីឥណទានពីគ្រឹះស្ថាន យកទៅបង្កើតអាជីវកម្មបើកកសិដ្ឋានចិញ្ចឹមសត្វ សំរាប់លក់យកប្រាក់ចំណេញ តែចៃដន្យជួបគ្រោះធម្មជាតិ ដោយមាន ទឹកជំនន់ដែលបណ្តាលអោយលិចលង់កសិដ្ឋានទាំងអស់ និងបណ្តាលអោយជ្រូកទាំងអស់បានងាប់ អតិថិជនមិនមានលទ្ធភាពក្នុងការសង់បំណុល។

➢ យុទ្ធសាស្ត្រកាត់បន្ថយហានិភ័យឥណទានរួមមាន៖

- ចំពោះអតិថិជន
  - ធ្វើការវាយតម្លៃឱ្យបានត្រឹមត្រូវពីគោលបំណនៃការសុំខ្ចី
  - វិភាគលើរបាយការណ៍ហិរញ្ញវត្ថុរបស់អតិថិជន
  - ពិចារណាពីគោលជំហរនៃការសុំខ្ចី
  - ត្រូវមានវត្ថុបញ្ចាំ ឬអ្នកធានា
  - ផ្តល់យោបល់ក្នុងករណីដែលទាក់ទងនឹងការធ្វើអាជីវកម្មរបស់អតិថិជន
- ចំពោះគ្រឹះស្ថានហិរញ្ញវត្ថុ
  - ពង្រឹងសមត្ថភាពរបស់បុគ្គលិកតាមរយៈការបណ្តុះបណ្តាលទៅលើឥណទាន
  - លើកទឹកចិត្តទៅដល់បុគ្គលិក
  - ដាក់ពិន័យចំពោះបុគ្គលិកដែលមានកំហុស

## ១.៣ គោលការណ៍នៃការផ្តល់ឥណទានសហគ្រាសខ្នាតតូច និង មធ្យម

គោលការណ៍នៃការផ្តល់ឥណទានសហគ្រាសខ្នាតតូច និង មធ្យម គឺធ្វើឡើងដើម្បីធានាលើប្រសិទ្ធភាពក្នុងការផ្តល់ឥណទាន គឺតម្រូវឱ្យមានការសងត្រឡប់មកវិញទាំងដើមទាំងការហេតុនេះទើបតម្រូវឲ្យបង្កើតនូវគោលការណ៍ ដើម្បីធានាសុវត្ថិភាពលើទុនកុំឲ្យប្រឈមហានិភ័យខ្ពស់។

គោលការណ៍នៃឥណទានមាន៣សំខាន់ៗ ៖

- **គោលការណ៍ឲ្យខ្ចីមានគោលដៅកំណត់**

ក្នុងគោលការណ៍ឲ្យខ្ចីរបស់ស្ថាប័ននីមួយៗ គឺតម្រូវអោយសងទាំងដើមទាំងការមកវិញដើម្បីកាត់បន្ថយកុំអោយមានហានិភ័យ ស្ថាប័នបានបង្កើតគោលការណ៍ឲ្យខ្ចីមានគោលដៅដោយគោលការណ៍នេះ គឺតម្រូវឲ្យបុគ្គល គ្រួសារឬអាជីវកម្មដែលមានតម្រូវការប្រើប្រាស់ឥណទាន ដោយត្រូវរៀបរាប់ពីគោលបំណងទៅកាន់គ្រឹះស្ថានឥណទានតាមរយៈការធ្វើពាក្យសុំ ដោយបញ្ជាក់ឲ្យបានច្បាស់លាស់ពីគោលដៅ និងផែនការនៃការប្រើប្រាស់ឥណទាន ទំហំទឹកប្រាក់ និងរយៈពេលសងត្រឡប់ ។

- **គោលការណ៍ឲ្យខ្ចីដោយសងទាំងដើមទាំងការ**

នេះជាគោលការណ៍សំខាន់បំផុតសំរាប់ឥណទានសហគ្រាសខ្នាតតូច និង ធម្យម ដោយគោលការណ៍នេះ បង្ខំឲ្យអ្នកខ្ចីត្រូវគិតគូរពីការប្រើប្រាស់ទុនឲ្យមានប្រសិទ្ធភាពខ្ពស់ និងដើម្បីជំរុញអោយអាជីវកម្មរបស់ខ្លួនឆាប់ទទួល បានផលចំណេញទើបអាចមានលទ្ធភាពសងបំណុលទាំងដើមទាំងការបាន ។

- **គោលការណ៍ឲ្យខ្ចីដោយមានការធានា**

គោលការណ៍នេះតម្រូវឲ្យអ្នកខ្ចីត្រូវមានទ្រព្យសម្បត្តិ ដើម្បីដាក់ធានាដែលមានតំលៃអាចទូទាត់បានមុនពេលទទួលបានប្រាក់កម្ចី ឬត្រូវមានភាគីទី៣ធានាចេញមុខសងជំនួសនៅពេលភាគីខ្ចីខកខានមិនបានសង។ ការអនុវត្តគោលការណ៍នេះត្រូវមានលក្ខណៈសមស្របរវាងប្រាក់ដែលឲ្យខ្ចីទៅនិងតំលៃទ្រព្យដែលដាក់ធានា ។

# ជំពូកទី ២

# ស្ថានភាពទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត

## ២.១ ប្រវត្តិសង្ខេបរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ដំបូងឡើយនៅក្នុងឆ្នាំ ១៩៩៤ មានគំរោងសន្តិសុខស្បៀងមួយ ដែលត្រូវបានបង្កើតឡើងដោយ OCSD/OXFAM-Quebec ដែលជាអង្គការរបស់ ប្រទេសកាណាដាដែលបានផ្តល់ឥណទានខ្នាតតូចបំផុតដល់ប្រជាពលរដ្ឋនៅតាមតំបន់ជនបទក្នុងឃុំចំនួន ៩នៃខេត្តពោធិ៍សាត់។ បន្ទាប់មកក្នុងឆ្នាំ ១៩៩៦ គំរោងសន្តិសុខស្បៀងនេះបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា ជាអង្គការក្រៅរដ្ឋាភិបាល ដែលត្រូវបានគេផ្តល់ឈ្មោះថា "ហត្ថាកសិករ" ដែលមានន័យថា ដៃរបស់កសិករ ឬជាដៃសំរាប់ជួយកសិករ។នៅពេលនោះការិយាល័យកណ្តាលរបស់អង្គការ ហត្ថាកសិករ គឺស្ថិតនៅក្នុងខេត្តពោធិ៍សាត់។ ក្នុងឆ្នាំ២០០១ អង្គការហត្ថាកសិករ បានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មដោយមានដើមទុនសរុបចំនួន ៧៧,៨៥០ ដុល្លារអាមេរិក ដោយផ្លាស់ប្តូរស្ថានភាពរបស់ស្ថានប័នពីអង្គការក្រៅរដ្ឋាភិបាលទៅជាក្រុមហ៊ុនឯកជនទទួលខុសត្រូវ មានកំរិតដែលមានឈ្មោះថ្មីហៅថា "ហត្ថាកសិករ លីមីតធីត"។នៅក្នុងពេលជាមួយគ្នានោះដែរហត្ថាកសិករ លីមីតធីត បានទទួលអាជ្ញាប័ណ្ណរយៈពេល៣ ឆ្នាំពីធនាគារជាតិនៃកម្ពុជា ដើម្បីប្រតិបត្តិការសេវាកម្ម មីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា។ បន្ថែមពីនេះទៅទៀតនៅក្នុងឆ្នាំ ២០០៧ សេវាកម្មប្រាក់បញ្ញើសន្សំ និងប្រព័ន្ធព័ត៌មានវិទ្យាសំរាប់បំរើឲ្យសេវាកម្មនេះ ត្រូវបានគេដាក់ឲ្យប្រើប្រាស់ដើម្បីត្រួតពិនិត្យ និងគ្រប់គ្រងលើប្រតិបត្តិការ។ ទន្ទឹមនឹងគ្នានោះដែរហត្ថាកសិករបានបង្កើនដើមទុនរបស់ខ្លួនពី ២៥៧,៨៥០ រហូតដល់ ១,៣៣៩,៧០០ ដុល្លារអាមេរិក។ ដោយសារតែហត្ថាកសិករមាននិរន្តរភាព ផ្នែកប្រតិបត្តិការហិរញ្ញវត្ថុ និងអភិបាលកិច្ចល្អ ធនាគារជាតិនៃកម្ពុជាក៏បានផ្តល់អាជ្ញាប័ណ្ណគ្មានកាលកំណត់សំរាប់ប្រតិបត្តិការសេវាមីក្រូហិរញ្ញវត្ថុដល់ហត្ថាកសិករ ។

ឈានមកដល់ឆ្នាំ២០១០ ដោយសារតែហត្ថាកសិករ មាននិរន្តរភាពផ្នែកប្រតិបត្តិការ ធនាគារជាតិនៃកម្ពុជាបានសម្រេចផ្តល់អាជ្ញាប័ណ្ណ ប្រកបអាជីវកម្មទទួលប្រាក់បញ្ញើសន្សំពីសាធារណៈជន (MDI-License) ដល់ហត្ថាកសិករ លីមីតធីត។ ការទទួលអាជ្ញាប័ណ្ណនេះសរបញ្ជាក់ឲ្យឃើញ ពីភាពជោគជ័យមួយក្នុងចំណោមភាពជោគជ័យជាច្រើនរបស់ហត្ថាកសិករ លើការផ្តល់សេវាកម្មហិរញ្ញវត្ថុដល់អតិថិជនពិសេសអនុញ្ញាតឲ្យ ហត្ថាកសិករ គេណ្ឌប្រមូលប្រាក់សន្សំពីសាធារណជនជាផ្លូវការ។ លើសពីនេះផ្នែកព័ត៌មានវិទ្យាបាននឹងកំពុងសិក្សាលើការបំពាក់ឲ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងធនាគារថ្មី ដើម្បីធ្វើយ៉ាងណាឲ្យការបំរើសេវាកម្មអតិថិជន និងសកម្មភាពប្រតិបត្តិការកាន់តែមានប្រសិទ្ធភាពថែមទៀត ដែលទាំងអស់នេះឆ្លើយតបទៅនឹងយុទ្ធសាស្ត្ររបស់ក្រុមហ៊ុនក្នុងការកម្លាយ ខ្លួនជាធនាគារពាណិជ្ជនាពេលអនាគត។ នៅក្នុងឆ្នាំ២០១២ហត្ថាកសិករ លីមីតធីត បានដាក់ឲ្យប្រើប្រាស់បានយ៉ាងជោគជ័យនូវប្រព័ន្ធគ្រប់គ្រងធនាគារថ្មីនៅគ្រប់បណ្តាញការិយាល័យប្រតិបត្តិការទាំងអស់។ ប្រព័ន្ធគ្រប់គ្រងធនាគារថ្មីនេះបានបង្កើនប្រសិទ្ធភាព និងផលិត ភាពការងារអាជីវកម្មកាន់តែប្រសើរឡើងៗ។ បន្ថែមពីនេះ ហត្ថាកសិករ បានវិនិ

យោគជិត ២ លាន ដុល្លារអាមេរិកលើគំរោងបង្កើតឱ្យមានសេវាអេធីអឹម និងប្រព័ន្ធធនាគារចល័តសំរាប់អតិថិជន ។ ការវិនិយោគទៅលើបច្ចេកវិទ្យាទំនើបនេះ គឺដើម្បីឱ្យកាន់តែមានភាពសំបូរបែបនូវសេវាហិរញ្ញវត្ថុសំរាប់អតិថិជន និងដើម្បីបង្កើននូវប្រសិទ្ធភាពនៃការបំរើសេវា អតិថិជនឱ្យកាន់តែរហ័សទាន់ចិត្តនិងមានភាពងាយស្រួលក្នុងការធ្វើប្រតិបត្តិការសាច់ប្រាក់ តាមរយៈម៉ាស៊ីនអេធីអឹមដក-ដាក់ប្រាក់ និងសេវាធនាគារចល័តរបស់ហត្ថាកសិករ។ ជាមួយនឹងម៉ាស៊ីនអេធីអឹមដ៏ទំនើបដែលមិនធ្លាប់មាននិងប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា និងប្រព័ន្ធធនាគារចល័តអតិថិជនអាចធ្វើប្រតិបត្តិការហិរញ្ញវត្ថុបានច្រើនយ៉ាងដូចជា ដកប្រាក់ ដាក់ប្រាក់ ផ្ទេរប្រាក់ ប្តូរប្រាក់ ព្រមទាំងទិញកាតទូរស័ព្ទតាមតំរូវការ។ ម៉ាស៊ីនអេធីអឹមដ៏ទំនើបនេះ បានដាក់ឲ្យអតិថិជន និងសាធារណជនប្រើប្រាស់បានជាផ្លូវការនៅចុងឆ្នាំ ២០១២ កន្លងទៅនេះ។

រហូតមកដល់ឆ្នាំ២០១៦ហត្ថាកសិករ លីមីតធីត ក្លាយជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារក្រុងស្រី ដែលជាធនាគារធំជាងគេលំដាប់ទី៥ នៃព្រះរាជាណាចក្រថៃនិង ជាសមាជិកនៃសម្ព័ន្ធហិរញ្ញវត្ថុអន្តរជាតិ Mitsubishi UFJ Financial Group (MUFG) ដែលជាសម្ព័ន្ធក្រុមហ៊ុនផ្តល់សេវាកម្មហិរញ្ញវត្ថុធំបំផុតរបស់ប្រទេសជប៉ុននិងលើសកលលោក គ្រប់គ្រងក្រុមហ៊ុនបុត្រសម្ព័ន្ធជាធនាគារជាច្រើននៅទូទាំងពិភពលោក។ថ្មីៗនេះនៅក្នុងឆ្នាំ២០១៧ហត្ថាកសិករ លីមីតធីត ទទួលបានដើមទុនបន្ថែមថ្មីចំនួន១៥លានដុល្លារអាមេរិក ដែលធ្វើអោយមូលធនរបស់ភាគទុននិកសរុបកើនឡើងរហូតដល់ ៨៤,៧ លានដុល្លារអាមេរិកដែលក្នុងនោះមានដើមទុនចុះបញ្ជីជាមួយធនាគារជាតិនៃកម្ពុជាចំនួន ២១,៨ លានដុល្លារអាមេរិក ។

## ២.២ ទស្សនៈវិស័យ បេសកម្ម និងតម្លៃស្នូលរបស់ហត្ថាកសិករ លីមីតធីត

### ២.២.១ ទស្សនៈវិស័យ

ជាគ្រឹះស្ថានផ្តល់សេវាកម្មហិរញ្ញវត្ថុឈានមុខគេ និងមាននិរន្តរភាពក្នុងការជួយអតិថិជនឲ្យទទួលបានជោគជ័យក្នុងអាជីវកម្ម តាមរយៈការផ្តល់សេវាកម្មហិរញ្ញវត្ថុដ៏សមស្រប ដើម្បីរួមចំណែកអភិវឌ្ឍន៍ប្រទេសកម្ពុជា ។

### ២.២.២ បេសកកម្ម

ហត្ថាកសិករខិតខំរក្សានិរន្តរភាពយូរអង្វែងផ្នែកហិរញ្ញវត្ថុ និងសង្គមដោយធ្វើឲ្យប្រាក់ចំណូលរបស់អតិថិជនកាន់តែប្រសើរឡើង។ហត្ថាកសិករផ្តល់សេវាកម្មឥណទាន ប្រាក់សន្សំ និងសេវាហិរញ្ញវត្ថុផ្សេងៗជាច្រើនទៀត ជាពិសេសផ្តល់ជូនអតិថិជនជាស្ត្រី និងគ្រួសារដែលមានប្រាក់ចំណូលទាបនៅតាមជនបទទូទាំងប្រទេសកម្ពុជា ។

### ២.២.៣ តម្លៃស្នូល

តម្លៃស្នូលរបស់ ហត្ថាកសិករ លីមីតធីតត្រូវបានចែករំលែកទៅកាន់បុគ្គលិកទូទាំងប្រទេសដើម្បីឱ្យគ្រឹះស្ថានមានការរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃ។ តម្លៃស្នូលរបស់ហត្ថាកសិករគឺ HKL VALUE ដែរមានន័យថា ៖

- **H (Home) ទីលំនៅ**

មានន័យថារាល់បុគ្គលិកទាំងអស់ ដែលបានចូលបម្រើការនូវគ្រឹះស្ថានទាំងអស់ត្រូវចាត់ទុកហត្ថាកសិករជាលំនៅរបស់ខ្លួន ហើយយកចិត្តទុកដាក់លើលទ្ធផលរបស់ហត្ថាកសិករដោយសារលទ្ធផលរបស់គ្រឹះស្ថាន គឺជាលទ្ធផលរបស់យើងទាំងអស់គ្នា។

- **K (Knowledge) ចំណេះដឹង**

គ្រឹះស្ថានជឿជាក់ថា ចំណេះដឹង ការសិក្សាស្វែងយល់ និងការអភិវឌ្ឍខ្លួនឯងគួរតែត្រូវបានលើកទឹកចិត្តគ្រប់ដំណាក់កាលទាំងអស់នៃជីវិត។ ហើយយើងត្រូវតែមានចំនេះដឹង និងជំនាញលើអ្វីដែលយើងទទួលខុសត្រូវ។

- **L (Loyalty) ភាពស្មោះត្រង់**

ក្នុងនាមជាបុគ្គលិកត្រូវមានរបៀបរស់នៅមួយដោយមិនមានការកុហក ភូតភរ ការលួចបន្លំ និងការបោកបញ្ឆោត ឬបោកប្រាស់គ្រប់រូបភាពទាំងអស់ ពីព្រោះគ្រឹះស្ថានធ្វើអាជីវកម្មប្រកបទៅដោយតម្លាភាព ភាពទទួលខុសត្រូវចំពោះអតិថិជន ភាគទុនិក ក្រុមហ៊ុន សហគមន៍ និងអ្នកដែលពាក់ព័ន្ធផ្សេងៗទៀត។

- **V (Value) តម្លៃ**

យើងមានមោទនភាពបំផុតព្រោះយើង ជាផ្នែកមួយរបស់ហត្ថាកសិករ។យើងរីករាយចំពោះតម្លៃដែលហត្ថាកសិករផ្តល់ឱ្យយើងទៅតាមអ្វីដែលយើងលះបង់សម្រាប់ហត្ថាកសិករ ដូចជាពេលវេលា ការខិតខំប្រឹងប្រែង ជំនាញនិងចំណេះដឹង។

- **A (Activeness) ភាពសកម្ម**

ដើម្បីសម្រេចគោលបំណងរបស់គ្រឹះស្ថាន លុះត្រាតែរាល់បុគ្គលិកត្រូវបង្ហាញពីភាពសកម្មជា កំលាំង ចលករ ដ៏សំខាន់នៅក្នុងការជំរុញ និងពន្លឿនការអភិវឌ្ឍន៍ និងឱកាសស្វែងរកប្រាក់ចំណេញរបស់គ្រឹះស្ថាន។

- **L (Leading) ភាពនាំមុខគេ**

គឺជាទស្សនៈវិស័យរបស់យើងទាំងអស់គ្នា។ ទោះបីនៅក្នុងកាលទេសៈណាក៏ដោយយើងត្រូវតែជាអ្នកនាំមុខមួយនៅលើទីផ្សារ ដោយប្រើប្រាស់គ្រប់មធ្យោបាយទាំងអស់។

- **U (Unity& Equality) សាមគ្គីគ្នានិងភាពស្មើភាពគ្នា**

រាល់បុគ្គលិកអាចនិយាយដោយស្មើភាពគ្នា និងត្រូវបានគោរពដោយត្រឹមត្រូវ ដោយមិនមានការរើសអើង ឬប្រកាន់បក្ខពួកនោះទេ។គ្រឹះស្ថានឱ្យតម្លៃទៅលើគ្រប់យោបល់ទាំងអស់ ហើយតែងតែយល់ថាបុគ្គលិកម្នាក់ៗជា ផ្នែកមួយនៃប្រព័ន្ធរបស់ហត្ថាកសិករសម្រាប់ភាពរីកចម្រើន និងការអភិវឌ្ឍ។

- E (Effectiveness) **ប្រសិទ្ធភាព**

ទ្រព្យសម្បត្តិរបស់ហត្ថាកសិករ គឺជាទ្រព្យសម្បត្តិរបស់យើងទាំងអស់គ្នា។ យើងត្រូវតែយកចិត្តទុកដាក់ថែរក្សាទ្រព្យសម្បត្តិរបស់ហត្ថាកសិករ ហើយប្រើប្រាស់ទ្រព្យទាំងនោះឱ្យមានប្រសិទ្ធភាព ដើម្បីបង្កើតនូវលទ្ធផលដែលមានផ្លែផ្កា សម្រាប់ហត្ថាកសិករ។

## ២.៣ និមិត្តសញ្ញារបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត

HKL

កាន់តែទុកចិត្ត កាន់តែចំរើន

ហត្ថាកសិករ លីមីតធីត

HATTHA KAKSEKAR LIMITED

រង្វង់មូលដែលមានសញ្ញាព្រួញ តំណាងអោយប្រតិបត្តិការណ៍គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីតដែលកំពុងប្រតិបត្តិការណ៍ឥណទានជាមួយនិងសេវាកម្ម និងចរន្តលំហូរនៃសាច់ប្រាក់ដែលវិលជុំវិញប្រទេសកម្ពុជាយើង។

**"ហត្ថាកសិករ"** ដែលមានន័យថា ដៃរបស់កសិករ ឬជាដៃសំរាប់ជួយកសិករ។

HKL ជាអក្សរកាត់នៃឈ្មោះ**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត**

- **H: HATTHA**
- **K: KAKSEKAR**
- **L: LIMITED**

## ២.៤ ទីតាំងភូមិសាស្ត្រ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករលីមីតធីត

ទន្ទឹមនឹងសេដ្ឋកិច្ចដែលមានការរីកចម្រើន ឥតឈប់ឈរពីមួយថ្ងៃទៅមួយថ្ងៃដែលធ្វើឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត បានពង្រីកចំនួនការិយាល័យប្រតិបត្តិការរហូតដល់ ១៧៨សាខា ដែលមានចំនួនបុគ្គលិកបម្រើប្រតិបត្តិការណ៍សរុប ៣,៣៩៩នាក់(បុគ្គលិកភេទប្រុស២,៣២៩នាក់) ដែលបម្រើប្រតិបត្តិការណ៍ទៅដល់ប្រជាជនទូទាំងប្រទេសកម្ពុជា។[5]

- អាសយដ្ឋាន ៖ អគារលេខ ៦០៦ ផ្លូវលេខ២៧១ សង្កាត់បឹងទំពុនទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ប្រទេសកម្ពុជា ។
- ទូរស័ព្ទ:(៨៥៥) ២៣ ៩៩៩ ២៦៦,
  ២៣ ៩៩៤ ៣០៤
- អ៊ីម៉ែល: info@hkl.com.kh
- ប្រអប់សំបុត្រ: ២០២៤
- ការិយាល័យប្រតិបត្តិការ ១៧៨។**សូមមើលឧបសម្ព័នទី ១**




[5] https://www.hkl.com.kh/kh

- **សាខាខណ្ឌចំការមន សង្កាត់បឹងកេងកងទី២**

អាស័យដ្ឋាន: ផ្ទះលេខ៥២៩ ផ្លូវលេខ៩៣ សង្កាត់បឹងកេងកងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ

លេខទូរស័ព្ទ: 069 666 053 / 069 333 227

អ៊ីម៉ែល: 003.adm@hkl.com.kh

បើកបម្រើអតិថិជន: ថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ (Monday – Friday )

ម៉ោង ៧:៣០ព្រឹក ដល់ ៤ ៣០រសៀល ( 7:30 Am to 4 30 Pm)



- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករលីមីតធីតមានរចនាសម្ព័នបុគ្គលិក និងការគ្រប់គ្រង់យ៉ាងរឹងមាំ ដែរធ្វើអោយបុគ្គលិកទាំងអស់ មានទំនួលខុសនៅក្នុងការបំពេញភារកិច្ចតាមតួរនាទីរៀងៗខ្លួន។ បុគ្គលិកសាខាបឹងកេងកងទី២ មានមុខដំណែងដូចជា៖
  - នាយកសាខាសាខា
  - ប្រធានបេឡា
  - បេឡា
  - ប្រធានគណនេយ្យ
  - គណនេយ្យ

- ប្រធានសាខា
- មន្ត្រីឥណទាន
- ប្រធានផ្នែកលក់ឥណទាន
- មន្ត្រីលក់ឥណទាន
- ប្រធានរដ្ឋបាល។ **សូមមើលឧបសម្ព័ន្ធទី ២**

## ២.៥ ផលិតផល និងសេវាកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករលីមីធីត

### ២.៥.១ សេវាឥណទាន

- **ឥណទានទូទៅ**

ឥណទានទូទៅ គឺជាប្រភេទផលិតផលឥណទានសម្រាប់អតិថិជនជាលក្ខណៈបុគ្គល ឬសហគ្រាសខ្នាតតូចបំផុតនិងសហគ្រាសខ្នាតមធ្យម ដែលមានគោលបំណងប្រើប្រាស់ឥណទានច្បាស់លាស់ក្នុងការបង្កើត អាជីវកម្មថ្មី និង ពង្រីកអាជីវកម្មដែលមានស្រាប់។ អតិថិជននឹងទទួលបាននូវលក្ខខណ្ឌឥណទានយ៉ាងសមរម្យ ស្របតាមតម្រូវការ ខួបនៃអាជីវកម្ម។

- **ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន**

ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន គឺជាប្រភេទឥណទានផ្តល់ជូនអតិថិជនដែលមានតម្រូវការទិញសម្ភារៈប្រើប្រាស់ផ្សេងៗក្នុងគោលបំណងប្រើប្រាស់ផ្ទាល់ខ្លួន ឬប្រើប្រាស់ក្នុងគ្រួសារដើម្បីលើកកម្ពស់កម្រិតជីវភាពឲ្យកាន់ តែមានភាពរីកចម្រើនតាមរយៈមានសម្ភារៈប្រើប្រាស់សមរម្យ។ ឥណទាននេះត្រូវបានផ្តល់ជូនសម្រាប់អតិថិជនទូទៅជាមួយ នឹងអត្រាការប្រាក់និងរយៈពេលនៃកម្ចីសមរម្យ ។

- **ឥណទានគេហដ្ឋាន**

ឥណទានគេហដ្ឋាន ផ្តល់ចំពោះអតិថិជនដែលមានបំណងសាងសង់ ឬទិញគេហដ្ឋានថ្មីដើម្បីរស់នៅ។ អតិថិជនអាចមានជម្រើសជាច្រើននៅក្នុងការខ្ចីទៅតាមតម្រូវការរបស់អតិថិជន។

- **ឥណទានកែលម្អគេហដ្ឋាន**

ឥណទានកែលម្អគេហដ្ឋាន ផ្តល់ចំពោះការសាងសង់ដែលសំដៅលើការជួសជុលកែលម្អការស្តារប្រសើរឡើង ឬការសង់បំពេញបន្ថែមផ្នែកមួយចំនួននៃគេហដ្ឋានដូចជា សាងសង់ ឬការជួសជុលកែលម្អបន្ទប់មួយ ឬច្រើនដើម្បីសុវត្ថិភាពក្នុងផ្ទះ ការជួសជុលដំបូល ផ្លាស់ប្តូរកម្រាល (ឥដ្ឋ ការ៉ូ ឬចាក់ប្លង់សេ)ដែលមានគុណភាព។ជួសជុលឬសង់បង្គន់បន្ថែមដើម្បីបំពេញតម្រូវការអនាម័យជាដើម។

- **ឥណទានថែរក្សាអនាម័យ និងបរិស្ថាន**

ឥណទានបរិស្ថាននិងសង្គមផ្តោតសំខាន់លើអតិថិជន ដែលមានបំណងបង្កើនកម្រិតជីវភាពកាន់តែប្រសើរឡើងនិងចូលរួមចំណែកការងារបរិស្ថាន។ ឥណទាននេះមានគោលដៅផ្តល់ជូនអតិថិជនទាំងឡាយណាដែលមានបំណងសាងសង់ឡជីវឧស្ម័ន ទិញបន្ទះអគ្គិសនីសូឡាសាងសង់បន្ទប់ទឹក ទិញធុងចម្រោះទឹកស្អាត ជាដើម ។

- **ឥណទាននិស្សិតខ្មែរ**

ឥណទាននិស្សិតខ្មែរ ផ្តល់ជូនដល់អាណាព្យាបាល ឬសិស្សនិស្សិតនូវជំនួយផ្នែកហិរញ្ញវត្ថុសម្រាប់ការបន្តការសិក្សានៅកំរិតឧត្តមសិក្សាដូចជា បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ ឬជំនាញវិជ្ជាជីវៈ ហើយមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចំណាយទៅលើថ្លៃសាលា និងការចំណាយផ្សេងៗទៀតនៅក្នុងអំឡុងពេលនៃការសិក្សា។

- **ឥណទានកាតគ្រី**

កាតគ្រីជាផលិតផលឥណទានដែលផ្តល់កម្ចីឆាប់រហ័សបំផុត ជាមួយលក្ខខណ្ឌងាយៗដោយគ្រាន់តែដាក់តម្កល់ប័ណ្ណកម្មសិទ្ធិយានយន្តរបស់លោកអ្នកជាទ្រព្យបញ្ចាំ។ ផលិតផលឥណទាននេះផ្តល់ភាពងាយស្រួលនិងសេវាកាន់តែឆាប់រហ័ស ចំពោះដំណោះស្រាយហិរញ្ញវត្ថុបន្ទាន់របស់អតិថិជន។

### ២.៥.២ សេវាប្រាក់បញ្ញើសន្សំ

- **គណនីសន្សំផលច្រើនផលិតផលសន្សំផលច្រើន**

គណនីសន្សំផលច្រើនផលិតផលសន្សំផលច្រើន គឺជាប្រភេទគណនីដ៏ពិសេសមួយដែលបង្កើតឡើងសម្រាប់អតិថិជនរូបវន្តបុគ្គល ដែលកំពុងជួបប្រទះនូវការលំបាកក្នុងការស្វែងរកការដាក់ប្រាក់សន្សំមួយដែលទទួលបានទាំងការប្រាក់ខ្ពស់ និងងាយស្រួលដកប្រាក់ ក្នុងពេលវេលាដ៏ចាំបាច់ណាមួយភ្លាមៗ។ជាមួយផលិតផលនេះ អតិថិជននឹងទទួលបានអត្រាការប្រាក់ខ្ពស់ប្រហាក់ប្រហែលនឹងគណនីបញ្ញើមានកាលកំណត់អាស្រ័យ តាមសមតុល្យជាក់ស្តែងដែលអតិថិជនមានក្នុងគណនី ប្រចាំថ្ងៃ។ លើសពីនេះទៅទៀត អតិថិជនអាចដកប្រាក់បានយ៉ាងងាយស្រួលតាមរយៈការិយាល័យ ម៉ាស៊ីនអេធីអឹម និងសេវាធនាគារចល័ត របស់ ហត្ថាកសិករ លីមីតធីត។

- **គណនីប្រាក់បញ្ញើសន្សំ**
    - គណនីអ៊ីហ្ស៊ី Ezzy

គណនីអ៊ីហ្ស៊ីត្រូវបានបង្កើតឡើង ដើម្បីឆ្លើយតបក៏ដូចជាបំពេញ តម្រូវការរបស់អតិថិជននិងស្ថាប័នសំខាន់ៗ ដែលមាន បំណងចង់បាន អត្រាការប្រាក់ខ្ពស់ពីគណនីសន្សំរបស់ពួកគេ។ អតិថិជននឹងទទួលបានអត្ថប្រយោជន៍ពីសេវាកម្មធនាគារចល័ត និងសេវាអេធីអឹមដែលមានលក្ខណៈពិសេសដោយឥតគិតថ្លៃ។ ការបើកគណនីលើកដំបូងតម្រូវ ឱ្យអតិថិជនដាក់ប្រាក់តម្កល់ចំនួន ៥០ដុល្លារ ឬសមមូលនឹងរូបិយប័ណ្ណផ្សេង។

- គណនីស្មាត Smart

គណនីស្មាតផ្តល់នូវអត្រាការប្រាក់ខ្ពស់បំផុតសម្រាប់ទម្រង់សន្សំដោយស្ម័គ្រចិត្ត។អតិថិជនអាចប្រើប្រាស់សេវាកម្មធនាគារចល័ត និងសេវាអេធីអឹមដោយឥតគិតថ្លៃសម្រាប់ប្រតិបត្តិការហិរញ្ញវត្ថុប្រចាំថ្ងៃរបស់ពួកគេ។ អតិថិជនអាចបើកគណនីស្មាតដោយតម្កល់ទឹកប្រាក់ដំបូងក្នុងគណនីចំនួន ២៥០ដុល្លារឬសមាមាត្ររូបិយប័ណ្ណផ្សេង។

- គណនីនិស្សិត

គណនីនិស្សិតត្រូវបានបង្កើតឡើងជាពិសេសសម្រាប់និស្សិត ដែលកំពុងសិក្សានៅតាមគ្រឹះស្ថានអប់រំសាធារណៈនិងឯកជន។ អតិថិជនលើគម្រោងគណនីនេះមានលទ្ធភាពធ្វើប្រតិបត្តិការសាច់ប្រាក់និងសេវាហិរញ្ញវត្ថុផ្សេងៗទៀតយ៉ាងទូលំទូលាយ។

- គណនីសន្សំនីតិបុគ្គល (មិនមែនគ្រឹះស្ថានហិរញ្ញវត្ថុ)

គណនីសន្សំស្ថាប័នផ្តល់ជូននូវលទ្ធភាពរបស់ក្រុមហ៊ុន ដើម្បីអនុវត្តប្រតិបត្តិការហិរញ្ញវត្ថុសម្រាប់អាជីវកម្មរបស់ខ្លួននៅទូទាំង ២៥ ខេត្តក្រុងទូទាំងប្រទេស ។

- **គណនីបញ្ញើកើនចំណូល**

គណនីបញ្ញើកើនចំណូល ជាប្រភេទគណនីបង្កើតឡើងសំរាប់អតិថិជនដែលចង់បានភាពងាយស្រួលក្នុងការដកការប្រាក់មក ប្រើប្រាស់ក្នុងកំឡុងពេលដាក់ប្រាក់សន្សំមានកាលកំណត់។ ជាមួយប្រភេទគណនីនេះអតិថិជនអាចដកការប្រាក់បានរៀងរាល់ខែនីមួយៗ ដោយមិនផ្តោតលើរយៈពេលសន្សំឡើយ។ ដើម្បីបើកគណនីនេះ អតិថិជនត្រូវមានសាច់ប្រាក់នៅក្នុងគណនី ៥០ ដុល្លារ ឬសមាមាត្រនឹងរូបិយប័ណ្ណផ្សេង ហើយអាចជ្រើសរើសរយៈពេលពី ១ខែ ទៅ ៣៦ ខែ។

- **គណនីបញ្ញើកើនទ្រព្យ**

គណនីបញ្ញើកើនទ្រព្យ ត្រូវបានបង្កើតឡើងសំរាប់អតិថិជនដែលមានសាច់ប្រាក់ទំនេរច្រើនហើយចង់ទទួល បាននូវអត្រាការ ប្រាក់ខ្ពស់ត្រលប់ទៅវិញលើការសន្សំ។ ជាភាពងាយស្រួលអតិថិជនអាចធ្វើការដកការប្រាក់នៅចុងបញ្ចប់វគ្គ។ ការបើកគណនីនេះ អតិថិជនគ្រាន់តែមានប្រាក់នៅក្នុងគណនី ៥០ដុល្លារឬសមមាត្រនឹងរូបិយប័ណ្ណផ្សេង ហើយជ្រើសរើសរយៈពេលនៃការបញ្ញើចាប់ពី ១ខែ ទៅ ៣៦ខែ ។

### ២.៥.៣ សេវាផ្ទេរប្រាក់ក្នុងស្រុក

ហត្ថាកសិករផ្តល់ជូនដំណោះស្រាយ ដ៏ប្រសើរបំផុតសម្រាប់អតិថិជនដែលមានបំណងផ្ទេរប្រាក់ទៅកាន់ទីកន្លែងនានាក្នុងប្រទេសកម្ពុជា។ ជាមួយភាពជឿជាក់មានសុវត្ថិភាព និងសេវាកម្មរហ័សទាន់ចិត្ត អតិថិជននឹងទទួលបានភាពកាន់តែងាយស្រួលក្នុងការទំនាក់ទំនងសាច់ប្រាក់ទៅកាន់សាច់ញាតិ បងប្អូន ដៃគូអាជីវកម្ម ព្រមទាំងអ្នកជាទីស្រលាញ់ផ្សេងៗទៀត តាមរយៈបណ្តាញការិយាល័យប្រតិបត្តិការទីតាំងអេធីអឹម និងប្រពន្ធ័ធនាគារចល័ត នៅទូទាំង២៥ខេត្ត-រាជធានី។

### ២.៥.៤ សេវាម៉ាយអេធីអឹម

ម៉ាស៊ីនអេធីអឹមដ៏ទំនើបរបស់ហត្ថាកសិករផ្តល់ជូនសេវាកម្មសម្បូរបែប ត្រូវបានដាក់បម្រើការទូទាំងផ្ទៃប្រទេសដើម្បីសម្រួលដល់ ប្រតិបត្តិការហិរញ្ញវត្ថុប្រចាំថ្ងៃប្រកបដោយភាពងាយស្រួលតាមបណ្តាញម៉ាស៊ីនអេធីអឹមដែលនៅមានទីតាំងជិត លោក អ្នកបំផុត។ អតិថិជនអាចធ្វើប្រតិបត្តិការដូចជា ដាក់ប្រាក់ ដកប្រាក់ ផ្ទេរប្រាក់ ប្តូរប្រាក់ ទិញកាតទូរសព្ទ ពិនិត្យសមតុល្យសាច់ប្រាក់ ពិនិត្យរបាយការណ៍សង្ខេប និងប្រតិបត្តិការហិរញ្ញវត្ថុតាមតម្រូវការ ជាមួយម៉ាស៊ីនអេធីអឹមនៅពេញផ្ទៃប្រទេស។

មុខងារសំខាន់៖

- មុខងារប្រតិបត្តិការហិរញ្ញវត្ថុមានដូចជា ដាក់ប្រាក់ ដាក់ប្រាក់ដោយមិនប្រើកាត ដកប្រាក់ ផ្ទេរប្រាក់ ទូទាត់វិក្កយបត្រ ទិញកាតទូរស័ព្ទ ទូទាត់សងឥណទាន និងប្រតិបត្តិការផ្សេងៗទៀត ។

- មុខងារមិនមែនប្រតិបត្តិការហិរញ្ញវត្ថុមានដូចជា ត្រួតពិនិត្យរបាយការណ៍សង្ខេប ទីតាំងអេធីអឹម សមតុល្យគណនី ពិនិត្យអត្រាការប្រាក់ ព័ត៌មានឥណទានការរំលឹកពីការសងឥណទាន និងប្រតិបត្តិការផ្សេងៗទៀត។

### ២.៥.៥ សេវាធនាគារចល័ត

ហត្ថាកសិករ ផ្តល់ជូនសេវាកម្មហិរញ្ញវត្ថុដ៏ទំនើបចុងក្រោយ ដែលអនុញ្ញាតអោយអតិថិជនធ្វើប្រតិបត្តិការ ហិរញ្ញវត្ថុរបស់ពួកគេ គ្រប់ពេលវេលា និងគ្រប់ទីកន្លែងតាមរយៈទូរស័ព្ទដៃ។ តាមរយៈសេវាកម្មនេះអតិថិជន អាចត្រួតពិនិត្យរបាយការណ៍សង្ខេប ទីតាំងអេធីអឹម សមតុល្យគណនី ផ្ទេរប្រាក់ ទទួលប្រាក់ ទិញកាតទូរស័ព្ទ ពិនិត្យអត្រាការប្រាក់ ព័ត៌មានឥណទានការរំលឹកពីការសងឥណទាននិងធ្វើប្រតិបត្តិការហិរញ្ញវត្ថុផ្សេងៗទៀត។

អត្ថប្រយោជន៍សម្រាប់អតិថិជន៖

- ផ្ទេរប្រាក់ពីគណនីទៅគណនី ដោយមិនគិតថ្លៃ
- ផ្ទេរប្រាក់ទៅលេខទូរសព្ទ ដោយមិនគិតថ្លៃ
- ទូទាត់វិក្កយបត្រ ដោយមិនគិតថ្លៃ
- ទិញកាតទូរសព្ទ ដោយមិនគិតថ្លៃ
- ទូទាត់សងឥណទាន ដោយមិនគិតថ្លៃ
- ប្រតិបត្តិការផ្សេងៗ ដោយមិនគិតថ្លៃ

### ២.៥.៦ សេវាបើកប្រាក់បៀវត្សរ៍

ហត្ថាកសិករបង្កើតនិងបម្រើសេវាបើកប្រាក់បៀវត្សរ៍ចំពោះសហគ្រាស អង្គការក្រុមហ៊ុនឯកជននិងស្ថាប័នរដ្ឋផ្សេងៗក្នុងការ ជួយសម្រួលដល់ការបើកបៀវត្សរ៍ជូនបុគ្គលិកប្រកបដោយភាពរលូននិងមានភាពងាយស្រួលដោយគ្រាន់តែមានគណនី ជាមួយហត្ថាកសិករលើមីធីត កម្រៃសេវាទាបបំផុតត្រឹមតែ ០,២៥ ដុល្លាអាមេរិកចំពោះបុគ្គលិកម្នាក់។

### ២.៥.៧ សេវាទូទាត់រហ័ស

សេវាទូទាត់រហ័ស ជាសេវាផ្ទេរប្រាក់ថ្មីដែលបានផ្តួចផ្តើមដោយធនាគារជាតិនៃកម្ពុជា និងចូលរួមសហការដោយធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដើម្បីផ្តល់ភាពងាយស្រួលដល់អតិថិជន ក្នុងការផ្ទេរឬទូទាត់ប្រាក់រៀលឆ្លងបណ្តាធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលជាដៃគូ។

# ជំពូក ទី៣

# ការគ្រប់គ្រងជាក់ស្តែងទៅលើឥណទានខ្នាតតូច និងមធ្យមរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត

## ៣.១ គោលការណ៍ឥណទានសហគ្រាសខ្នាតតូច និងមធ្យម

### ៣.១.១ និយមន័យ

ឥណទានសហគ្រាសខ្នាតតូចនិងមធ្យម ឬឥណទានខ្នាតតូចនិងមធ្យមជាប្រភេទឥណទានអាជីវកម្មផ្តល់ជូនអតិថិជនគោលដៅដែលជាប្រភេទឯកត្តបុគ្គល ដែលមានអាជីវកម្មជាលក្ខណៈគ្រួសារ ទ្រង់ទ្រាយមធ្យមនិងជានីតិបុគ្គលដែលមានអាជីវកម្ម រឺក្រុមហ៊ុនខ្នាតតូចនិងមធ្យម ដែលមានតម្រូវការប្រើប្រាស់ប្រាក់យកទៅពង្រីកលើអាជីវកម្ម រឺសហគ្រាសនោះដែលកំពុងមានប្រតិបត្តិការស្របតាមច្បាប់ប្រទេសកម្ពុជា និងអន្តរជាតិ។

សហគ្រាសខ្នាតតូចៈ គឺជាសហគ្រាសអាជីវកម្មទាំងឡាយណាដែលមានកម្មករពី 10 ទៅ 50 នាក់និងមានដើមទុនចាប់ផ្តើមឬទ្រព្យសកម្មសរុប (មិនរាប់បញ្ចូលទ្រព្យសម្បត្តិដីធ្លីនិងមិនវិនិយោគក្នុងអាជីវកម្ម) មានចាប់ពី 500,000 ដុល្លារដល់តិចជាង 250,000 ដុល្លារឬសមមូលទៅនឹងរូបិយប័ណ្ណផ្សេងទៀត។

សហគ្រាសខ្នាតមធ្យមៈ គឺជាសហគ្រាសអាជីវកម្មទាំងឡាយណាដែលមានបុគ្គលិកចាប់ពី 50 ទៅ 100 នាក់និងជាមួយដើមទុនចាប់ផ្តើមឬទ្រព្យសកម្មសរុប (មិនរាប់បញ្ចូលទ្រព្យសម្បត្តិដីធ្លីនិងមិនវិនិយោគក្នុងអាជីវកម្ម)មានចាប់ពី 250.000 ដុល្លារទៅ 500.000 ដុល្លារឬសមមូលទៅនឹងរូបិយប័ណ្ណផ្សេងទៀត។[6]

### ៣.១.២ លក្ខណៈសម្បត្តិរបស់អតិថិជន

សម្រាប់អតិថិជនដែលមានបំណងប្រើប្រាស់ឥណទានសហគ្រាសខ្នាតតូច នឹងមធ្យមគឺអនុញ្ញាតអោយប្រជាជនកម្ពុជាគ្រប់រូបដែលមានអាយុចាប់ពី 18ឆ្នាំដល់60ឆ្នាំមានលក្ខណៈសម្បត្តិដូចខាងក្រោម ៖

- មានប្រវត្តិល្អ អត្តចរិកល្អ នឹងដែលអាចជឿទុកចិត្តបាន។
- ធានាថាព័ត៌មានដែលផ្តល់ជូនហត្ថាកសិករមានភាពត្រឹមត្រូវទាន់ពេលវេលានិង ច្បាស់លាស់។
- មិនពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មណាមួយ។
- មានអាស័យដ្ឋានអចិន្ត្រៃយ៍ស្ថិតនៅក្នុងតំបន់ប្រតិបត្តិការរបស់ហត្ថាកសិករ។
- តម្លៃវត្ថុបញ្ចាំត្រូវបានគ្របដណ្តប់លើចំនួនប្រាក់កម្ចី។

[6] សៀវភៅគោលការណ៍ឥណទានសហគ្រាសខ្នាតតូចនិងមធ្យមរបស់ហត្ថាកសិករ ឆ្នាំ២០១៧

**៣.១.៣ លក្ខខណ្ឌនៃអាជីវកម្មដែលសុំបើក**

- ត្រូវមានអាជ្ញាប័ណ្ណបើកអាជីវកម្មប៉ាតង់និង ឯកសារដែលមានលក្ខណៈពាក់ព័ន្ធត្រូវបានទាមទារ (លើកលែងតែអាជីវកម្មគ្រួសារ) ។
- មុខរបរឬអាជីវកម្មបច្ចុប្បន្នមានបេសកម្ម និងដំណើការស្របតាមច្បាប់រដ្ឋនិងអន្តរជាតិ
- ត្រូវធ្វើរបាយការណ៍បង្ហាញពីលំហូរសាច់ប្រាក់ និងប្រាក់ចំណេញប្រចាំខែ។
- របាយការណ៍សវនកម្មផ្ទៃក្នុងនិងខាងក្រៅត្រូវបានតម្រូវប្រសិនបើមាន។
- អាជីវកម្មនេះនឹងបង្កើតប្រាក់ចំណេញគ្រប់គ្រាន់ដើម្បីសងប្រាក់កម្ចី។

**៣.១.៤ ការហាមឃាត់អាជីវកម្មនិងអតិថិជន**

ជាអនីតិជន ជាជនពិការពិការសតិ និងអ្នកដែលជាប់ពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌ សកម្មភាពនិងការអនុវត្តអាជីវកម្មដែលមានការហាមឃាត់ដោយច្បាប់រួមមាន៖

- អាជីវកម្មដែលប្រើពលកម្មកុមារឬពាក់ព័ន្ធនឹងការជួញដូរមនុស្ស។
- អាជីវកម្មដែលពាក់ព័ន្ធនឹងផលិតកម្ម ឬការជួញដូរអាវុធឬគ្រឿងផ្ទុះក្នុងគោលបំណងគំរាមកំហែងដល់សន្តិសុខសង្គម។
- អាជីវកម្មដែលពាក់ព័ន្ធនឹងសកម្មភាពជួញដូរសត្វព្រៃដែរខុសទៅនឹងច្បាប់ជាតិ។
- អាជីវកម្មដែលពាក់ព័ន្ធនឹងពាណិជ្ជកម្មនិងផលិតសម្ភារៈវិទ្យុសកម្ម។
- សកម្មភាពពាណិជ្ជកម្មឬផលិតផល ដែលមានគ្រោះថ្នាក់ដល់បរិស្ថាននិងប្រឆាំងនឹងច្បាប់ជាតិឬ ច្បាប់អន្តរជាតិ។
- អាជីវកម្មណាដំណើរការឬការជួញដូរណាដែលប្រឆាំងនឹងច្បាប់ជាតិឬអន្តរជាតិ។

**សូមមើលឧបសម្ព័នទី ៣**

**៣.១.៥ តម្រូវការពីអតិថិជន**

អតិថិជនត្រូវយល់ច្បាស់លាស់អំពី លក្ខខណ្ឌគោលនយោបាយឥណទានសហគ្រាសធុនតូចនិងមធ្យមតាមរយៈការពន្យល់ពីមន្ត្រីឥណទាននិងបុគ្គលិកពាក់ព័ន្ធផ្សេងទៀត។

- ប្រសិនបើអាជីវកម្មនេះគឺជាអាជីវកម្មដែលគ្រប់គ្រង ដោយគ្រួសារឬក្រុមហ៊ុន ហត្ថាកសិករតម្រូវអោយមានការយល់ស្របក្នុងចំណោមសមាជិកគ្រួសារ ឬថ្នាក់ដឹកនាំទាំងអស់ដែលពាក់ព័ន្ធ។
- ប្រសិនបើអាជីវកម្មនេះគឺជានីតិបុគ្គលដែលបានចុះបញ្ជី ហត្ថាកសិករត្រូវការ ការមូលមតិគ្នាពីក្រុមប្រឹក្សាភិបាល។
- អ្នកខ្ចីសំខាន់ៗត្រូវបានគេតម្រូវឱ្យថតចម្លងកាតអត្តសញ្ញាណប័ណ្ណ ឬសំបុត្រកំណើតនិងសៀវភៅគ្រួសារ (សំបុត្រអាពាពិពាហ៍ និងលិខិតបញ្ជាកើការស្នាក់នៅ)។
- អ្នកខ្ចីត្រូវមានភស្តុតាងទាក់ទងទៅនឹង សិទ្ធទទួលបានអាជីវកម្មដូចជា លិខិតចុះបញ្ជីពាណិជ្ជកម្ម អាជីវកម្ម នៃក្រុមហ៊ុនឬឯកសារពាក់ព័ន្ធដទៃទៀត។

- អ្នកខ្ចីត្រូវផ្តល់ព័ត៌មានច្បាស់លាស់និងខ្លីៗទាក់ទង នឹងការពិពណ៌នាអំពីអាជីវកម្ម គោលបំណងប្រាក់កម្ចីការទស្សន៍ទាយ និងព័ត៌មានផ្សេងៗដែលតម្រូវដោយអ្នកខ្ចីត្រូវអនុលោមតាមលក្ខខណ្ឌនិងឯកសារដែលមានចែងក្នុងឯកសារកម្ចី និងកិច្ចសន្យារបស់ហត្ថាកសិករ និងផ្តិតស្នាមមេដៃលើឯកសារឥណទាននៅមុខមន្រ្តីឥណទាន។ ប្រសិនបើអ្នកខ្ចីមិនមានមេដៃស្តាំទេមេដៃឆ្វេងអាចប្រើបាន។ ប្រសិនបើអតិថិជនគ្មានមេដៃម្រាមដៃបន្ទាប់អាចប្រើផងដែរ។

- ក្នុងករណីដែលអ្នកខ្ចីគ្មានម្រាមដៃពួកគេគួរតែជាអ្នកចុះហត្ថលេខា ដើម្បីឱ្យច្បាស់លាស់ថាអ្នកខ្ចីត្រូវតែយល់ព្រមទូទាត់សងប្រាក់ នៅការិយាល័យរបស់ហត្ថាកសិករតាមកាលវិភាគសងបំណុល។

- អ្នកខ្ចីត្រូវបានតម្រូវឱ្យដាក់ការទូទាត់ ទៅក្នុងគណនីទូទាត់ហើយត្រូវយល់ព្រមផ្តិតស្នាមមេដៃលើប័ណ្ណដាក់ប្រាក់នីមួយៗ អ្នកខ្ចីត្រូវតែមានលទ្ធភាពសងប្រាក់កម្ចី។

- ត្រូវមានសមត្ថភាពគ្រប់គ្រាន់ក្នុងការសងបំណុលដែលត្រូវបាន កំណត់ដោយសមាមាត្រប្រាក់ចំណេញសរុបត្រូវស្ថិតចន្លោះពី 1,5 ទៅ 3ដង ធៀបទៅនឹងប្រាក់សំណងសរុបទាំងប្រាក់ដើមនឹងការប្រាក់ ដែលបានទូទាត់អោយលើកដំបូងមកស្ថាប័ន។ បើផលធៀបនេះកាន់តែធំមានន័យថាអតិថិជនមានសមត្ថភាពខ្ពស់ក្នុងការទូទាត់សងទាន់ពេលវេលា។

- អាចតម្រូវឱ្យមានអ្នកធានាបំណុល ដោយធានាទៅលើវិសាលភាពហានិភ័យដែលត្រូវបានវិភាគដោយមន្រ្តីឥណទាននិងអ្នកគ្រប់គ្រងសាខា។ អ្នកធានាត្រូវតែមានចំណូលច្រើនជាងអ្នកខ្ចី ឬប្រហាក់ប្រហែលអ្នកខ្ចី។ អ្នកធានាត្រូវមានកាតព្វកិច្ចទូទាត់បំណុលប្រចាំខែជំនួសឱ្យអ្នកខ្ចីក្នុងករណីអ្នកខ្ចីមិនអាចសងបំណុល។

- អ្នកខ្ចីត្រូវយល់ព្រមអនុញ្ញាតឱ្យបុគ្គលិកហត្ថាកសិករ ត្រួតពិនិត្យប្រតិបត្តិការអាជីវកម្មឬយល់ព្រមផ្តល់របាយការណ៍ហិរញ្ញវត្ថុបច្ចុប្បន្នដល់បុគ្គលិកហត្ថាកសិករ ដើម្បីតាមដានស្ថេរភាពនិងនិរន្តរភាពនៃអាជីវកម្មនិងវាស់វែងពីសុខុមាលភាពនៃប្រាក់កម្ចីដែលបានផ្តល់។

### ៣.១.៦ ការរួមចំណែកដើមទុន

- ការចូលរួមចំណែកដើមទុនរបស់របស់ហត្ថាកសិករជាមួយ នឹងអ្នកខ្ចីទាំងអស់ដែលបានស្នើសុំកម្ចីសហគ្រាសធុនតូចនិងមធ្យមក្នុងគោលបំណងក្នុងការទ្រទ្រង់ នឹងពង្រីកអាជីវកម្មដែលមានស្រាប់ត្រូវតែអនុវត្ត តាមលក្ខខណ្ឌគោលការណ៍នៃទ្រព្យសម្បត្តិសរុប ឬដើមទុនចាប់ផ្តើមដូចដែលមាននៅក្នុងនិយមន័យសហគ្រាសធុនតូច និងមធ្យម ។

- អ្នកខ្ចីទាំងអស់ដែលស្នើសុំកម្ចីសហគ្រាសធុនតូច និងមធ្យមក្នុងគោលបំណងក្នុងការទ្រទ្រង់នឹងពង្រីកអាជីវកម្ម គឺហត្ថាកសិករតម្រូវអោយអតិថិជនមានទុនចូលរួមយ៉ាងតិច ៣០% នៃគំរោងវិនិយោគសរុប។



## ៣.២ ការបែងចែកនៃប្រភេទឥណទានសហគ្រាសខ្នាតតូច និង មធ្យម

កម្ចីអាជីវកម្មខ្នាតតូចនិងមធ្យម គឺជាផ្តល់ប្រាក់កម្ចីជូនអតិថិជនណាដែលមានតម្រូវការកម្ចី ក្នុងគោលបំណងដើម្បីបង្កើតអាជីវកម្មមួយដែលស្របតាមច្បាប់ ឬពង្រីកអាជីវកម្មដែលមានស្រាប់ដើម្បីបង្កើនប្រាក់ចំណេញ។

### ៣.២.១ ការបែងចែកប្រភេទ SME Loan តាមគោលបំណងកម្ចី

➢ **កម្ចីពាណិជ្ជកម្ម / ពាណិជ្ជកម្ម**

អតិថិជនទាំងឡាយណាដែលមានគោលបំណងប្រើប្រាស់កម្ចី ក្នុងគោលបំណងប្រកបរបរអាជីវកម្ម ឬជាការធ្វើពានិជ្ជកម្ម ( ទិញចូល លក់ចេញ ដើម្បីចំណេញ) ឬជាការទិញសម្ភារៈផ្សេងៗ (អង្ករ ផ្លែឈើ ចំណីសត្វ គ្រឿងទេស គ្រឿងសំណង់ បន្លែត្រី អាជីវកម្មប្តូរប្រាក់ ពង្រីកស្តុក ឬ ទុនបង្វិលនៅក្នុងអាជីវកម្ម) សម្រាប់ផ្គត់ផ្គងនិងប្រើប្រាស់លើអាជីវកម្មរបស់ខ្លួនក្នុងគោលបំណងទទួលយកផលចំណេញពីការជួញដូរនោះ។

➢ **កសិកម្ម**

អតិថិជនទាំងឡាយដែលមិនទាន់មានឧបករណ៍ប្រើប្រាស់ សម្រាប់វិស័យកសិកម្ម Agriculture production គ្រប់គ្រាន់។ហេតុកសិករបានផ្តល់ឥណទានទៅលើវិស័យនេះតាមរយៈការផ្តល់កម្ចីទៅដល់កសិករគ្រប់រូប ដែលមានការខ្វះខាតថវិការប្រាក់ដើម្បីទិញគ្រាប់ពូជ (ស្រូវ ដំឡូងជ្វា កៅស៊ូ ពោត សណ្តែក) ឧបករណ៍កសិកម្មនានា (ដំឡើងរោងម៉ាស៊ីនកិនស្រូវទិញម៉ាស៊ីនប្រមូលផល ឬត្រាក់ទ័រ) ក៏ដូចជាកម្ចីក្នុងការចិញ្ចឹមសត្វផងដែរ(ជីកស្រះ ដាក់ទ្រុង ទិញចំណី ឬធ្វើនេសាទ)។

➢ **សេវាកម្ម**

សម្រាប់អ្នកខ្ចីប្រាក់ដែលយកទៅប្រើប្រាស់ប្រាក់ក្នុងគោលបំណងបង្កើត ឬពង្រីកក្រុមហ៊ុនផ្តល់សេវាកម្មផ្សេងៗ (ក្រុមហ៊ុនទេសចរណ៍ និងដឹកជញ្ជូន ពង្រីកឬបង្កើតក្រុមហ៊ុនសេវាកម្ម សាងសង់ឬពង្រីកផ្ទះសំណាក់ សណ្ឋាគារ សម្រាប់ការជួសជុលរថយន្ត ឬអាជីវកម្មជួលរថយន្ត អាជីវកម្មផ្ទេរប្រាក់ ឬជាការទិញម៉ាស៊ីនប្រមូលផល ឬត្រាក់ទ័រសម្រាប់គោលបំណងជួសជុលជាដើម) ។

➢ **ការដឹកជញ្ជូន**

សម្រាប់អ្នកខ្ចីដែលប្រើប្រាស់ប្រាក់កម្ចីនេះ ដើម្បីវិនិយោគនៅក្នុងមធ្យោបាយដឹកជញ្ជូន (សំរាប់ការដឹកជញ្ជូនផលិតផល ដូចជាការជួលរថយន្តដឹកទំនិញពីវាលទៅរោងចក្រឬពីកន្លែងមួយទៅកន្លែងមួយផ្សេងទៀតសម្រាប់គោលបំណងអាជីវកម្ម) ឬដើម្បីគាំទ្រដល់ប្រតិបត្តិការអាជីវកម្មរបស់ខ្លួននឹងដឹកជញ្ជូនផលិតផល និងសម្ភារៈនៅក្នុងមុខជំនួញជូនអតិថិជន(សម្រាប់ការទិញមធ្យោបាយដឹកជញ្ជូនដូចជារថយន្តនិងម៉ូតូអាជីវកម្ម) ឬយកប្រាក់កម្ចីទៅគាំទ្រសម្រាប់ការពង្រីកអាជីវកម្មដឹកជញ្ជូនរបស់ខ្លួន ។

➢ **សំណង់**

សម្រាប់អតិថិជនដែលកម្ចីប្រាក់ក្នុងគោលបំណងសម្រាប់សាងសង់ផ្ទះសម្រាប់លក់ ឬជាសកម្មភាពនិង ដំណើរការសាងសង់អ្វីមួយ សំរាប់លក់បង្កើនប្រាក់ចំណូល។

- យកកម្ចីទៅប្រើលើរបរ សាងសង់អាគារ និងផ្ទះសម្រាប់លក់
- ប្រាក់កម្ចីដែលប្រើប្រាស់សម្រាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធដូចជាស្ពានផ្លូវថ្នល់។
- ប្រាក់កម្ចីដែលប្រើសម្រាប់ទិញសម្ភារៈសំណង់ ឬបើកប្រាក់ខែដល់កម្មករនិងសម្រាប់ការចំណាយផ្សេងនៃអាជីវកម្មខាងលើ។

➢ **ផលិតកម្ម**

សម្រាប់អតិថិជនដែលខ្ចីយកទៅប្រើប្រាស់ប្រាក់កម្ចីដើម្បីវិនិយោគលើការកែច្នៃវត្ថុធាតុដើម ឬផលិតផលពាក់កណ្ដាលសម្រេចក្នុងគោលបំណងបង្កើតទៅជាទំនិញសម្រេចដូចខាងក្រោម ៖

- ប្រាក់កម្ចីដែលបានប្រើសម្រាប់ផលិតកម្មកែច្នៃកសិកម្ម។
- ប្រាក់កម្ចីដែលប្រើសម្រាប់ផលិតឥដ្ឋឬក្បឿងល្អនិងទឹកសុទ្ធជាដើម។
- ប្រាក់កម្ចីដែលត្រូវបានប្រើសម្រាប់ផលិតសូត្រឬក្រណាត់។ ល។
- ដែលបានប្រើសម្រាប់ផលិតម៉ាស៊ីនកែច្នៃឡើងវិញ។ ល។
- បានប្រើសម្រាប់ផលិតកម្មឬសិប្បកម្មគ្រឿងសង្ហារឹម។
- ប្រាក់កម្ចីដែលប្រើប្រាស់សម្រាប់ផលិតម៉ាស៊ីនកិនស្រូវនិងផលិតកម្មផ្សេងៗ។ល។

**សូមមើលឧបសម្ព័នទី ៤។**

### ៣.២.២ អត្ថប្រយោជន៍ក្នុងការកំណត់ប្រភេទឥណទាន

- ជួយឱ្យប្រតិបត្តិករហិរញ្ញវត្ថុទាំងអស់ យល់ច្បាស់អំពីដំណើរការណ៍កំណត់ចំណាត់ថ្នាក់ប្រភេទមុខរបររបស់អតិថិជនឱ្យបានត្រឹមត្រូវ។
- ជាបទដ្ឋានរួមក្នុងការធ្វើចំណាត់ថ្នាក់ប្រភេទមុខរបរអតិថិជនរបស់ស្ថាប័ននីមួយៗ
- ផ្ដល់ភាពងាយស្រួលដល់ប្រតិបត្តិករក្នុងការកំណត់ និងតាមដានប្រភេទមុខរបរឬអាជីវកម្មណាដែលមានហានិភ័យខ្ពស់។
- ប្រតិបត្តិករអាចធ្វើការគ្រប់គ្រង ឬទប់ស្កាត់ហានិភ័យឥណទានដែលអាចកើតមានឡើងលើឥណទានថ្មីទាន់ពេលវេលា។
- ប្រតិបត្តិករអាចធ្វើការគ្រប់គ្រង ឬទប់ស្កាត់ហានិភ័យពាក់ព័ន្ធនឹងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មបានទាន់ពេលវេលា។
- ជួយជំរុញឱ្យការវាយតម្លៃឥណទាន កាន់តែមានប្រសិទ្ធភាពដោយផ្ដល់ឥណទានជូនអតិថិជនមានប្រភេទមុខរបរ ឬអជីវកម្មដែលមានហានិភ័យទាប។
- ប្រតិបត្តិករអាចកាត់បន្ថយហានិភ័យប្រមូលផ្ដុំ តាមរយៈការកំណត់ផលប័ត្រកម្ចីដែលផ្ដល់ឱ្យអតិថិជនតាមប្រភេទមុខរបរ ឬអាជីវកម្មនីមួយៗ។

## ៣.៣ ដំណើរការនៃការគ្រប់គ្រងឥណទាន

ការផ្តល់ឥណទាន ជូនអតិថិជនគឺដំណើរការមួយយ៉ាងសំខាន់ដែលគ្រប់ស្ថាប័ន មិនអាចមើលរំលងបាន ព្រោះការផ្តល់ឥណទាន ជាប្រភពចំណូលមួយភាគធំរបស់ស្ថាប័ន ដូចនេះការផ្តល់ឥណទាន ត្រូវមានគោលការណ៍កំណត់ឱ្យបានច្បាស់លាស់។ ដូចនេះហត្ថាកសិករលីមីតធីត បានអនុវត្តនូវគោលការណ៍ដូចជា៖

### ៣.៣.១ ការផ្សព្វផ្សាយ Promotion

ដើម្បីឱ្យអតិថិជនបានស្គាល់អំពីផលិតផលឥណទានរបស់ខ្លួន ក្នុងគោលបំណងធ្វើឱ្យកាន់តែមានប្រសិទ្ធិភាពអំពីការផ្សព្វផ្សាយរបស់ខ្លួន ជាពិសេសឥណទានសហគ្រាស ខ្នាតតូច និងមធ្យម គ្រឹះស្ថានបានការកំណត់យ៉ាងច្បាស់លាស់ទៅលើ ទីតាំង ពេលវេលា ចំនួនបុគ្គលិក និងធ្វើការប្រមូលព័ត៌មានត្រឡប់មកវិញ គឺធ្វើយ៉ាងណាឱ្យការផ្សព្វផ្សាយនេះមានប្រសិទ្ធិភាពដែលនេះជាយុទ្ធសាស្ត្រក្នុងការប្រកួតប្រជែងជាមួយដៃគូរបស់ខ្លួន។

- **អតិថិជនគោលដៅ**

ប្រាក់កម្ចីសហគ្រាសធុនតូច និងមធ្យមត្រូវបានរៀបចំឡើងសម្រាប់អតិថិជនដែលជាឯកត្តកម្មីបុគ្គលដែលមានអាជីវកម្មប្រភេទគ្រួសារ ឬអាជីវកម្មខ្នាតតូចនិងមធ្យមដែលគោលបំណងរក្សានិរន្តរភាពឬកំណើនរបស់ពួកគេ។ កម្ចីនេះនឹងផ្តល់ដើមទុនបន្ថែមដល់សហគ្រាសធុនតូចនិងមធ្យមដែលស្របតាមច្បាប់ ដែលមានប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា។

- **ការផ្សព្វផ្សាយដោយផ្ទាល់**

ភ្នាក់ងារដែលពាក់ព័ន្ធមានដូចជា មន្ត្រីឥណទាន មន្ត្រីផ្នែកលក់ មន្ត្រីផ្នែកទីផ្សារចុះទៅធ្វើការផ្សព្វផ្សាយទៅដល់លំនៅដ្ឋាន ទីតាំងផ្ទាល់ ណែនាំអតិថិជន ជាពិសេសឥណទានគោលដៅឱ្យបានយល់ជ្រួតជ្រាបអំពី គោលការណ៍ នីតិវិធី និងអត្ថប្រយោជន៍នៃឥណទានខ្នាតតូចនិងមធ្យម ដោយភ្ជាប់ជាមួយឯកសារមានដូចជាសន្លឹកប័ណ្ណផ្សព្វផ្សាយពីផលិតផល និងសេវាកម្មទម្រង់សំណួរខ្លះៗដើម្បីសួរអតិថិជន និងភ្ជាប់ជាមួយនាមប័ណ្ណរបស់ប្រតិបត្តិករ។

- **ការផ្សព្វផ្សាយដោយប្រយោល**

បន្ថែមពីលើការផ្សព្វផ្សាយដោយផ្ទាល់ ហត្ថាកសិករបានយកវិធីសាស្ត្រផ្សព្វផ្សាយដោយប្រយោល គឺធ្វើយ៉ាងណាអោយអតិថិជនគោលដៅនៅទូទាំងប្រទេសកម្ពុជាបានស្វែងយល់ឱ្យបានច្បាស់ពីផលិតផលតាមរយៈ៖

- ទូរទស្សន៍
- គេហទំព័រផ្លូវការរបស់ខ្លួន
- បណ្តាញសង្គម ដូចជា Facebook/ Istagram
- ទីផ្សារសាធារណៈ ( ផ្ទាំងប៉ាណូតូច ធំ ផ្ទាំងបដារ………..)
- ឧបករណ៍ផ្សព្វផ្សាយ ( ធ័ត្រ មួកសុវត្ថិភាព អាវយឺត កែវទឹក ប៊ិច ………)

## ៣.៣.២ ការលំអិតពត៌មាន នឹងការបំពេញពាក្យស្នើសុំខ្ចីឥណទាន

### ៣.៣.២.១ លក្ខខណ្ឌទូទៅនៃឥណទាន

ការផ្តល់ឥណទានសំរាប់ឥណទានខ្នាតតូចនិងប្រាក់កម្ចីខ្នាតមធ្យមត្រូវបានរៀបចំឡើង ដើម្បីបំពេញនូវការពេញចិត្តរបស់អ្នកខ្ចីដោយផ្តល់រូបិយប័ណ្ណចំនួនបីប្រភេទផ្សេងគ្នា (ប្រាក់បាត រៀល និងដុល្លារ) ក្នុងចំនួនទឹកប្រាក់ពី 50.000 ដុល្លារដល់ 200.000 ដុល្លារឬសមមូលជារូបិយប័ណ្ណផ្សេងទៀត។

- រូបិយប័ណ្ណដុល្លារ អាមេរិច (តារាងទី១ កម្ចីជាប្រាក់ដុល្លារ អាមេរិច)

| ចំនួនប្រាក់កម្ចីសហគ្រាសខ្នាតតូចនិងមធ្យម | ត្រាការប្រាក់ប្រចាំខែ | រយៈពេល |
|---|---|---|
| ឥណទានចាប់ពី$ 50kដល់ $ 100k | 1,1% -1,4% | 5-6 ឆ្នាំ |
| ឥណទានចាប់ពី$100kទៅ $ 200k | 1% -1,1% | 5-6 ឆ្នាំ |

- រូបិយប័ណ្ណបាត ថៃ (តារាងទី២ កម្ចីជាប្រាក់បាត ថៃ)

| ចំនួនប្រាក់កម្ចីសហគ្រាសខ្នាតតូចនិងមធ្យម | អត្រាការប្រាក់ប្រចាំខែ | រយៈពេល |
|---|---|---|
| ប្រាក់កម្ចីពី 2 ដល់ 4លានបាត | 1,5% -1,9% | 5-6ឆ្នាំ |
| ប្រាក់កម្ចីច្រើនជាង 4 ដល់ 8 លានបាត | 1,4% -1,5% | ≤ 7ឆ្នាំ |

- រូបិយប័ណ្ណរៀល ខ្មែរ (តារាងទី៣ កម្ចីជាប្រាក់រៀល ខ្មែរ)

| ចំនួនប្រាក់កម្ចីសហគ្រាសខ្នាតតូចនិងមធ្យម | អត្រាការប្រាក់ប្រចាំខែ | រយៈពេល |
|---|---|---|
| ប្រាក់កម្ចីខ្ពស់ជាង 200ដល់ 400 លានរៀល | 1,7% -2,3% | 5-6 ឆ្នាំ |
| ប្រាក់កម្ចីខ្ពស់ជាង 400ដល់ 800លានរៀល | 1,4% -1,6% | ≤ 7ឆ្នាំ |

### ៣.៣.២.២ អត្រាការប្រាក់ប្រចាំខែ

គ្រឹះស្ថានហត្ថាកសិករលីមីតធីត បានកំណត់អត្រាការប្រាក់ប្រចាំខែនឹងកំណត់អត្រាការប្រាក់កម្ចីសហគ្រាសធុនតូចនិងមធ្យមចាប់ពី 1% ទៅ 1,4% អាស្រ័យទៅលើចំនួនប្រាក់កម្ចីនិងហានិភ័យនៃឥណទាន។

អត្រាការប្រាក់ប្រចាំខែនិងការគណនាត្រូវតែមានតម្លាភាពហើយអ្នកខ្ចី នឹងត្រូវបានទទួលការពន្យល់លម្អិតអំពីរបៀបគណនាការប្រាក់មុនពេលផ្តល់ប្រាក់កម្ចី។ ដើម្បីបង្កើនតម្លាភាពប្រាក់

កម្ចីអត្រាការប្រាក់ និងការទូទាត់ការប្រាក់ក៏ដូចជាប្រាក់ដើមត្រូវបានបង្ហាញយ៉ាងច្បាស់នៅក្នុងកាលវិភាគសងប្រាក់កម្ចីរបស់ គ្រឹះស្ថានហត្ថាកសិករលីមីតធីត។

### ៣.៣.២.៣ ការគណនាអត្រាការប្រាក់

ការប្រាក់ត្រូវបានគណនាក្នុងសមតុល្យប្រចាំថ្ងៃ ជាមូលដ្ឋានដោយប្រើយកទំហំឥណទានដែលនៅសល់ចាប់ផ្តើមពី កាលបរិច្ឆេទផ្តល់ប្រាក់កម្ចីដល់កាលបរិច្ឆេទសង។ យោងតាមការអនុវត្តជាក់ស្តែងនិងវិធីសាស្ត្រ នៃការទូទាត់សងការប្រាក់ត្រូវបានគណនាជាមធ្យម 30 ថ្ងៃក្នុងមួយខែ និង 360 ថ្ងៃក្នុងមួយឆ្នាំ។ ការគណនាត្រូវបានអនុលោមតាមរូបមន្តដូចខាងក្រោម:

$$\text{ការប្រាក់ប្រចាំខែ} = \frac{\text{សមតុល្យប្រាក់ដើមនៅជំពាក់} * \text{អត្រាការប្រាក់ប្រចាំខែ} * \text{ចំនួនថ្ងៃប្រើប្រាស់ឥណទាន}}{\text{៣០ ថ្ងៃជាមធ្យមក្នុងមួយខែ}}$$

### ៣.៣.២.៤ រយៈពេលផ្តល់ឥណទាន

ដើម្បីបំពេញតម្រូវការរបស់អតិថិជន និងផ្អែកតាមលំហូរសាច់ប្រាក់នៃការធ្វើអាជីវកម្មរបស់អតិថិជនឥណទានសហគ្រាសធន់តូច និងមធ្យមរបស់គ្រឹះស្ថានហត្ថាកសិករលីមីតធីត បានធ្វើការកំណត់រយៈពេលនៃការប្រើប្រាស់ឥណទាន ដោយផ្អែកទៅតាមទំហំឥណទានដែលបានស្នើសុំ។ ទំហំនៃការផ្តលឥណទានអាចមានរយៈពេលវែងបំផុតត្រឹមរយៈពេល ៧ឆ្នាំ។

### ៣.៣.២.៥ របៀបសងប្រាក់

របៀបសងឥណទានរបស់ហត្ថាកសិករបានធ្វើការបែងចែកជា៣ក្រុមដូចខាងក្រោម៖

- សងការប្រាក់ និងប្រាក់ដើមប្រចាំខែ (Monthly Repayment Method )
- សងការប្រាក់និងប្រាក់ដើមតាមកាលកំណត់ (Balloon Repayment Method)
- សងការប្រាក់ និងប្រាក់ដើមចុងវគ្គ (Bullet Repayment Method)

### ៣.៣.២.៦ រយៈពេលអនុគ្រោះ

រយៈពេលអនុគ្រោះត្រូវបានកំណត់យ៉ាងយូរត្រឹម៩ខែ។ ហត្ថាកសិករបានកំណត់ផ្តល់ការអនុគ្រោះតែលើការបងប្រាក់ដើមតែប៉ុណ្ណោះ មានន័យថាអតិថិជនត្រូវបង់សងការប្រាក់ប្រាចាំខែ ក្នុងរយៈពេលអនុគ្រោះដែលបានព្រមព្រៀងនោះ។ បន្ទាប់ពីផុតរយៈពេលអនុគ្រោះប្រាក់ដើម និងការប្រាក់ត្រូវបង់សងឬរំលោះជាប្រចាំខែ ទៅតាមចំនួនខែដែលនៅសល់ ដោយអនុវត្តសម្រាបតែរបៀបសង ៖

- Declining Repayment Method
- Annuity Repayment Method

**៣.៣.២.៧ សោហ៊ុយឥណទាន** Loan Fee

សោហ៊ុយឥណទាន ត្រូវបានបង្កើតឡើងក្នុងន័យជួយកាត់បន្ថយ នូវការចំណាយប្រើប្រតិបត្តិការរបស់ស្ថាប័ននឹងផ្តល់ភាពងាយស្រួលទៅដល់អតិថិជនក្នុងការទៅជួយ ឬបំពេញឯកសារឥណទានជាមួយអាជ្ញាធរមានសមត្ថកិច្ចស្រប ទៅតាមលក្ខខណ្ឌតម្រូវនៃគោលនយោបាយឥណទានសហគ្រាសធន់តូច និងមធ្យមរបស់ស្ថាប័ន។ សាហ៊ុយឥណទានត្រូវបានបែងចែកជា ៤ ប្រភេទខុសគ្នាៗតាមការគណនាដូចខាងក្រោមហើយត្រូវកត់ត្រាជាចំណូលផ្សេងៗនៃឥណទាន។

- កម្រៃសេវាឥណទាន Loan Fee ជាកម្រៃសេវាកម្មក្នុងការរៀបចំ ឥណទានជូនអតិថិជន។ កម្រៃនេះត្រូវបានគិតពីអតិថិជន លុះត្រាតែបានអនុម័តឥណទាន ហើយត្រូវគិតអត្រា 0.6 %ទៅ 1 % ធៀបទៅនិងទំហំឥណទានដែលបានអនុម័តនោះ។ កម្រៃនេះត្រូវធ្វើការកាត់ចេញពីលើទឹកប្រាក់នៃកម្ចីដែលបានអនុម័ត។

- កម្រៃសេវាកម្មចូលព័ត៌មានបំណុលក្នុងប្រព័ន្ធក្រេឌីតប្យូរ៉ូកម្ពុជា (Credit Check/ Enquiry through CBC ) នេះជាកម្រៃសេវាដែលហត្ថាកសិករ ត្រូវបង់ទៅស្ថាប័ន ក្រេឌីតប្យូរ៉ូកម្ពុជា ដូចនេះកម្រៃដែលបានពីអតិថិជនគឺស្មើនិងកម្រៃ ១០០% ដែលគិតដោយក្រេឌីតប្យូរ៉ូកម្ពុជា។

- កម្រៃរៀបចំឯកសារសងប្រាក់ថ្មីអនុវត្តសម្រាប់តែឥណទានទំហំចាប់ពី ១០០០ ដុល្លារ ឬសមមូលនឹងរូបិយប័ណ្ណផ្សេងសម្រាប់ការស្នើសុំរៀបចំតារាងសងប្រាក់ ដែលមានតម្លៃ ១០ ដុល្លារ អតិថិជនតម្រូវឱ្យធ្វើតារាងសងប្រាក់ថ្មីបានតែចំនួន ៣ដងទេ។ ក្នុងករណីលើស ៣ដង តម្រូវអោយបងតម្លៃសេវា ២០ ដុល្លារអាមេរិច។

- កម្រៃរត់ការឯកសារឥណទាន Arrangement Fee គឺកម្រៃលើការចំណាយសម្រាប់សេវាកម្មរត់ការឯកសារ ឥណទានទៅដល់អាជ្ញាធរ ទៅតាមគោលការណ៍តម្រូវនៃឥណទានដែលបានកំណត់។ ឯកសារដែលឥណទានដែលតម្រូវឱ្យធ្វើការរត់ការមាន កិច្ចសន្យាដាក់ទ្រព្យបញ្ចាំ ការចុះបន្ទុកទ្រព្យដាក់បញ្ចាំ និងកិច្ចសន្យាផ្សេងៗទៀត។

**`៣.៣.២.៨ ការផាកពិន័យឥណទាន**

ការផាកពិន័យ ត្រូវបានបង្កើតឡើងដើម្បីជំរុញលើប្រសិទ្ធភាពនៃប្រតិបត្តិការឥណទានសម្រាប់សហគ្រាសខ្នាតតូច និងមធ្យមពិសេសរាល់លក្ខខណ្ឌព្រមព្រៀងដូចមានចែងក្នុងកិច្ចសន្យារវាងស្ថាប័ន ជាមួយនិងអតិថិជនមុនពេលផ្តល់ឥណទាននិងទទួលឥណទាន។ ដូចនេះដើម្បីឱ្យមានតម្លាភាពទាមទារឱ្យមានភាគីនៃកិច្ចសន្យា ត្រូវយល់ដឹងពីចំណុចដូចខាងក្រោម ៖

- មុនពេលផ្តល់ឥណទានជូនអតិថិជន លក្ខខណ្ឌពិន័យត្រូវបានចែងក្នុងកិច្ចសន្យាខ្ចីប្រាក់ត្រូវជម្រាបជូន និងពន្យល់យ៉ាងច្បាស់ដល់អតិថិជន។

- លក្ខខណ្ឌចំពោះអតិជនត្រូវផាកពិន័យមាន ៖

- អតិថិជនមានលទ្ធភាពបង់សង តែបែរជាបង់យឺតយ៉ាវឆ្លងខែជាប្រចាំដោយគ្មានមូលហេតុ។

- អតិថិជនមានលទ្ធភាពបង់សង តែមានបំណង់ក្នុងការគេចវេសដោយប្រើសម្ដីនិងកាយវិការមិនសមរម្យ ។

- នាយកសាខាមានសិទ្ធសម្រេចថាគួរបន្ធូរបន្ថយកម្រិតផាកពិន័យ ឬលើកលែងតែត្រូវកំណត់មូលហេតុ ឬចំណារពីលើអំពីមូលហេតុច្បាស់លាស់និងពិតប្រាកដក្នុងលក្ខខណ្ឌជាគោលការណ៍ផាកពិន័យខាងលើ។

**ប្រាក់ពិន័យត្រូវគណនាតាមរូបមន្ត ៖**

$$\boldsymbol{P = O * (i * 2) * \frac{N}{30}}$$

P = Penalty (ចំនួនទឹកប្រាក់ត្រូវពិន័យសរុប)

O = Overdue (ប្រាក់ដើម និងការប្រាក់ដែលបានយឺតយ៉ាវ)

I = Interest (អត្រាការប្រាក់)

N = ចំនួនថ្ងៃដែលយឺត

30 = ចំនួនថ្ងៃជាមធ្យមក្នុងមួយខែ

- ប្រាក់ពិន័យបានត្រូវធ្វើការកត់ត្រាជាចំណូលផ្សេងៗបានពីឥណទានសម្រាប់សហគ្រាសធុនតូច និងមធ្យម។**សូមមើលឧបសម្ព័ន្ធទី ៥** ។

- បន្ទាប់ពីអតិថិជនបានយល់អំពីគោលការណ៍ ក្នុងការផ្ដល់ឥណទានរបស់ហាត្ថាកសិករលីមីតធីត រួចហើយអតិថិជនត្រូវបំពេញទម្រង់ ពាក្យស្នើសុំខ្ចីប្រាក់ និងបើកគណនីសន្សំសំចៃសម្រាប់ទូទាត់។ **សូមមើលនៅឧបសម្ព័នទី៦។**

### ៣.៣.៣ ការចុះស៊ើបអង្កេត និងវាយតម្លៃអតិថិជន

បន្ទាប់ពីភ្នាក់ងារឥណទានបានចុះទៅបំពេញ និងប្រមូលឯកសារជាមួយអតិថិជនរួចរាល់ហើយ បើយោងទៅលើគោលការណ៍របស់ ហាត្ថាកសិករ ព័តមានឯកសាររបស់អតិថិជននោះត្រូវយកមកធ្វើការស៊ើបអង្កេត និងវាយតម្លៃយ៉ាងលំអិតតាមរយៈវិធីសាស្ត្រមួយដែលអោយឈ្មោះថា CAMPADRIC ដែលមានន័យដូចខាងក្រោម ៖

- **អត្តចរិត Characteristic**

វាជាចំណុចមួយដែលអាចប្រាប់ពីលក្ខណៈសម្បត្តិ នៃការរស់នៅរបស់អតិថិជនម្នាក់នោះថាតើ អាកប្បកិរិយា សំដីសំដៅ ឫកពារមាយាទ ស្ថានភាពនៃការស់នៅ ស្ថានភាពគ្រួសារ លំនឹងនៃការតាំងទីលំនៅ ការរស់នៅប្រចាំថ្ងៃរបស់គាត់ ការទំនាក់ទំនងនៅក្នុងសហគមន៍យ៉ាងម៉េចដែរ និងចង់ដឹងពីប្រវត្តិនៃកម្ចីរបស់អតិថិជន (ការសងបំណុលធ្លាប់យឺតយ៉ាវដែររឺទេ)។

➢ **សមត្ថភាព Ability**

គឺការពិនិត្យទៅលើលទ្ធភាពនៃការសងបំណុលត្រឡប់មកវិញរបស់អតិថិជន នៅពេលដែលគាត់ទទួលបានឥណទានពីស្ថាប័នរបស់យើង ហត្ថាកសិករក៏បានផ្តោតសំខាន់ទៅលើចំណេះជំនាញ បទពិសោធន៍ ជោគជ័យនៅក្នុងមុខរបរជាមួយនិងលទ្ធភាពបង្កើនចំណូលរបស់អតិថិជន ។

➢ **ប្រាក់ចំណេញ Margin**

ចំណុចសំខាន់ក្នុងធ្វើអាជីវកម្មរបស់ស្ថាប័នទាំងអស់រមែងទាមទារមកវិញ នូវប្រាក់ចំណេញជាក់ស្តែងហត្ថាកសិករក៏បានគិតគូរពីការចំណេញរបស់ខ្លួនដែលបានមកពីការវិភាគលើ អត្រាការប្រាក់ ចំណូលពីការប្រាក់ ពេលវេលាថាតើអាចនឹងសមាមាត្រទៅលើការចំណាយរបស់ស្ថាប័នដែលរឺទេមុននឹងសម្រេចចិត្តបញ្ចេញឥណទានសហគ្រាសខ្នាតតូចនិងមធ្យមទៅកាន់អតិថិជន។

➢ **គោលបំណង Purpose**

មុននឹងធ្វើការផ្តល់ឥណទាន ជូនអតិថិជន ហត្ថាកសិករបានកំណត់នូវគោលការណ៍មួយចំនួនចំពោះអតិថិជន ក្នុងនោះក៏បានកំណត់យ៉ាងច្បាស់លាស់អំពីគោលបំណងរបស់អតិថិជនថាតើគាត់បានយកកម្ចី របស់យើងទៅប្រើប្រាស់ចំគោលដៅដែរឬទេ? គោលការណ៍នៃការកំណត់គោលបំណងនេះ ធ្វើឡើងដើម្បីកាត់បន្ថយហានិភ័យចំពោះការប្រើប្រាស់កម្ចីរបស់អតិថិជន និងក៏ជួយផ្តល់ជាយោបល់ចំពោះគំនិតក្នុងការបង្កើតអាជីវកម្មថ្មីដែរព្រោះបង្កើតអាជីវកម្មថ្មី គឺមានហានិភ័យជាងអាជីវកម្មដែលមានស្រាប់។ ក្នុងគោលបំណងមួយទៀត គឺជាការកាត់បន្ថយនៃផលប៉ះពាល់អវិជ្ជមានរបស់អាជីវកម្មរបស់គាត់ទៅលើ បរិស្ថាន និងសង្គម។**សូមមើលនៅឧបសម្ព័ន្ធទី៧។**

➢ **ទំហំឥណទាន Amount**

គ្រប់គ្រឹះស្ថានទាំងអស់ តែងតែចង់បានអោយកម្ចីរបស់ស្ថាប័ន ខ្លួនមានទំហំកម្ចីច្រើនតាមដែលអាចធ្វើទៅបាន ប៉ុន្តែយើងមិនអាចកំណត់ពីវិសាលភាពរបស់គ្រឹះស្ថាននៅលើតែទំហំកម្ចីនេះបានទេ យើងត្រូវមើលលើលទ្ធភាពនៃការសងត្រលប់របស់អតិថិជន និងផ្អែកទៅតាមទីផ្សារគោលដៅដែលបានកំណត់ទៅតាមផែនការរបស់ខ្លួនឯងផ្ទាល់។

➢ **ឯកសារ Document**

ឯកសារសំខាន់ៗជាច្រើន ត្រូវបានប្រើប្រាស់ក្នុងដំណើរការនៃឥណទានដែលមានដូចជាលិខិតសំគាល់ប្លង់កម្មសិទ្ធលើ ចលនៈទ្រព្យ និង អចលនៈទ្រព្យ អត្តសញ្ញាញប័ណ្ណ និងរាយការណ៍លំហូរសាច់ប្រាក់ ឯកសារសំខាន់ៗផ្សេងទៀត ដោយឡែកនៅក្នុងប្រតិបត្តិការឥណទាន និងការសរសេររបាយការណ៍ ទាំងអស់ត្រូវបានកត់ត្រាជាលាយល័ក្ខអក្សរដោយមន្ត្រីឥណទាន ត្រូវតែមានភាពច្បាស់លាស់ និងស្របតាមច្បាប់។មន្ត្រីឥណទានត្រូវបំពេញទម្រង់នៃឥណទានឱ្យបានត្រឹមត្រូវ ជៀសវាងការបង្កើតអោយមានកំហុសដដែលៗ ដែលអាចបង្កើតបានទៅជាហានិភ័យផ្សេងៗបាន។ គ្រប់ឯកសារឥណទានទាំងអស់ត្រូវបានធ្វើការពិនិត្យម្តងទៀតពីសំណាក់ប្រធានឥណទាន( Chief of credit)និងពីសំណាក់ ប្រធានសាខា(Branch Manager)។

➢ **ហានិភ័យ Risk**

មុនឈានទៅដល់ការសម្រេចក្នុងការផ្តល់ឥណទាន ប្រតិបត្តិករឥណទានបានធ្វើការវិភាគយ៉ាងច្បាស់ ពីកម្រិតនៃហានិភ័យដែលអាចនឹងកើតមានឡើង ដោយផ្អែកទៅលើហានិភ័យអតិថិជន មុខរបរឬអាជីកម្ម ទ្រព្យធានា រយៈពេល ការប្រែប្រួលនៃសេដ្ឋកិច្ច និងនយោបាយ។ ការកំណត់ហានិភ័យនេះត្រូវបានធ្វើឡើង តាមគោលការណ៍របស់ហត្ថាកសិករដែលបានកំណត់យ៉ាងច្បាស់លាស់ ។**សូមមើលនៅឧបសម្ព័ន្ធទី៨។**

➢ **អ្នកធានា Insurer**

លក្ខខណ្ឌ និងតម្រូវការផ្សេងៗត្រូវបានកំណត់តាមគោលការណ៍នៃការផ្តល់ឥណទានរបស់ហត្ថាកសិករយ៉ាងច្បាស់លាស់ ដោយទាមទារអោយអតិថិជនស្វែងរកអ្នកធានាអាចជា សាច់ញាតិ បងប្អូន ដែលអាចមានលទ្ធភាពក្នុងការទូទាត់សងបំណុលជំនួសខ្លួនករណីដែលខ្លួនមិនមានលទ្ធភាពក្នុការសងបំណុល ជូនហត្ថាកសិករតាមការកំណត់វិញបានទេ។

➢ **ទ្រព្យដាក់ធានា Collateral**

ដើម្បីកាត់ហានិភ័យនៃឥណទានក្នុងករណីដែលអតិថិជន ឬអាជីវកម្មរបស់អ្នកមានហានិភ័យខ្ពស់ដែលធ្វើអោយគាត់ពុំមានលទ្ធភាពក្នុងការសងត្រលប់ ហើយអ្នកធានាក៏មិនមានលទ្ធភាពសងដូចគ្នាទើបហត្ថាកសិករតម្រូវឱ្យមានការយកទ្រព្យសម្បត្តិ (ចលនទ្រព្យ និងអចលនទ្រព្យ)មកធ្វើជាវត្ថុធានា។ ហត្ថាបានប្រើប្រាស់វិធីសាស្ត្រក្នុងការសិក្សាលើទ្រព្យដាក់ធានាតាមវិធី **REALTOR** ដែលមានន័យដូចខាងក្រោម ៖

- R : Right ភាពត្រឹមត្រូវ

ដើម្បីឱ្យមានហានិភ័យតិចក្នុងការផ្តល់ឥណទាន មន្ត្រីឥណទានត្រូវពិនិត្យឱ្យបានត្រឹមត្រូវទៅលើប្រភេទឯកសារសំគាល់ទ្រព្យដែលដាក់បញ្ចាំ ថាតើមានឯកសារសំគាល់ទ្រព្យត្រឹមត្រូវ ឬជាច្បាប់ថតចម្លង? ថាតើឯកសារសំគាល់មានតែមួយ ឬមានច្រើនទៀត? ហើយដើម្បីកុំឱ្យមានកំហុស ប្រតិបត្តិករត្រូវពិនិត្យទៅដល់ទីតាំងទ្រព្យដាក់បញ្ចាំនោះ ។

- E : Estimate Value ប៉ាន់ស្មានតម្លៃទ្រព្យ

ការវាយតម្លៃលើទ្រព្យបញ្ចាំត្រូវបានធ្វើឡើងដោយ ប្រតិបត្តិករឥណទានដោយយកតម្លៃទៅតាមទីផ្សារជាក់ស្តែង(ឬវាយតម្លៃអោយទាបជាងទីផ្សារបន្តិច ដើម្បីកុំឱ្យមានហានិភ័យករណីទីផ្សារមានការប្រែប្រួល)។ ការវាយតម្លៃនេះត្រូវធ្វើអោយបានគ្រប់ជ្រុងជ្រោយ តាមរយៈការសួរនាំព័ត៌មាន អ្នករស់នៅជិតខាង អាជ្ញាធរ និងឈ្មួញទិញ លក់ដីជាដើម។ដោយតម្លៃនៃទ្រព្យបញ្ចាំត្រូវមាន តម្លៃយ៉ាងទាបបំផុត ១៥០% នៃកម្ចី ដោយយោងតាមគោលការណ៍របស់ហត្ថាកសិករលីមីតធីត។

- A : Ability To sale លទ្ធភាពដែលអាចលក់បាន

ប្រតិបត្តិករត្រូវសិក្សាពីតម្រូវការនៅលើទីផ្សារនៃទ្រព្យបញ្ចាំ ថាតើទ្រព្យនោះមានតម្រូវការច្រើនឬទេ។ដោយមិនយកទ្រព្យណាដែលមានតម្លៃខ្ពស់ខ្លាំងពេកទេ (តម្លៃចាប់ពី ១៥០% ដល់ ៣០០% នៃតម្លៃទ្រព្យបញ្ចាំនោះ) ។ ធ្វើបែបនេះដើម្បីអាចកំណត់មុនថា តើអាចលក់បានរហ័សដែរឬទេក្នុងករណីត្រូវការលក់បន្ទាន់។

- L : Location ទីតាំងទ្រព្យ

ទន្ទឹមនឹងការសិក្សាលើលទ្ធភាពដែលអាចលក់បាន ការសិក្សាលើទីតាំងភូមិសាស្ត្រក៏សំខាន់ណាស់ដែលដោយយើងធ្វើការសិក្សារកទីតាំងណាដែលល្អ (មានទីតាំងល្អ ជាប់ផ្លូវជាតិ ឬផ្លូវលំ ឬក្បែរសាលារៀន មន្ទីរពេទ្យ វត្តអារាម........) ។

- T : Type ប្រភេទទ្រព្យបញ្ចាំ

ការសិក្សាទៅលើប្រភេទនៃទ្រព្យបញ្ចាំ សំដៅទៅដីដែលជាប្រភេទដីស្រែចំការ ឬជាប្រភេទដីភូមិ (ដីអាចសាងសង់ផ្ទះ) ដែលអាចជាភាពងាយស្រួលក្នុងការវាយតម្លៃពីកម្រិត ហានិភ័យ ក៏ដូចជាងាយស្រួលក្នុងការសិក្សាពីតម្លៃលើទីផ្សារ ដើម្បីលក់ និងដោះដូរក្នុងករណីប្រសិនបើអតិថិជនគាត់ពុំមានលទ្ធភាពក្នុងការសងបំណុលនោះទេ។

- O : Ownership ភាពជាកម្មសិទ្ធ

ភាពជាម្ចាស់កម្មសិទ្ធសំដៅទៅលើភាពជាម្ចាស់ ក្នុងការកាន់កាប់លើទ្រព្យសម្បត្តិដោយស្របតាមច្បាប់នៃព្រះជាណាចក្រកម្ពុជា។ ដូចនេះដើម្បីការពារហានិភ័យប្រតិបត្តិករឥណទានត្រូវដឹងច្បាស់អំពីប្រវត្តរបស់អតិថិជនយកមកដាក់បញ្ចាំ ថាតើទ្រព្យនោះជាកម្មសិទ្ធរបស់ ឪពុកម្តាយ បងប្អូន ជីដូន ជីតា មីងមា ឬអ្នកជិតខាងជាដើម។ក្នុងករណីអ្នកដែលកាន់កាប់ដីជា ភាគីនៃដីគោត នោះបុគ្គលដែលកាន់កាប់នោះមិនមានសិទ្ធក្នុងការលក់ដូរ នឹងផ្ទេរសិទ្ធឬ ធ្វើមរតកបាននោះទេ។

- R : Risk ហានិភ័យ

ហានិភ័យរបស់ទ្រព្យបញ្ចាំជាបញ្ហាមួយដ៏សំខាន់ ដែលទាក់ទងទៅលើកំរិតនៃហានិភ័យនៃឥណទានទាំងមូល។ដូចនេះយើងត្រូវធ្វើការពិចារណា នឹងត្រួតពិនិត្យឱ្យបានម៉ត់ចត់ទៅលើថាតើដីដែលយកមកដាក់បញ្ចាំនោះ ជាប្រភេទដីកំពុងមានជម្លោះដែរពុំទាន់ដោះស្រាយចប់ ឬជាដីឯកជនរបស់រដ្ឋ ឬជាដីសាធារណៈរបស់រដ្ឋ។យើងត្រូវពិចារណាថា បើយើងទទួលយកដីនោះមកធ្វើជាវត្ថុបញ្ចាំ តើវាអាចនឹងមានបញ្ហាអ្វីកើតឡើងខ្លះ? នៅពេលមានបញ្ហាកើតឡើង តើយើងអាចដោះស្រាយ ឬលក់បានដែរឬទេ។តើទ្រព្យនោះពិតជាមានសុពលភាពផ្លូវច្បាប់ ដែលអាចយកមកដាក់បានឬយ៉ាងណា។**សូមមើលនៅឧបសម្ព័នទី៩។**

### ៣.៣.៣.១ ប្រភេទទ្រព្យដាក់បញ្ចាំ និង លក្ខខណ្ឌតម្រូវ

ទាក់ទងនឹងវត្ថុបញ្ចាំនិងតម្រូវការដីធ្លី លំនៅដ្ឋាន ឬអគារគឺជាទ្រព្យសម្បត្តិអាទិភាពសម្រាប់ការបញ្ចាំ។ ក្នុងករណីដែលតម្លៃនៃប្រភេទវត្ថុបញ្ចាំទាំងនេះមិនគ្រប់គ្រាន់ដូចគោលនយោបាយ

របស់ហត្ថាកសិករអ្នកខ្ចីអាចត្រូវបានតម្រូវឱ្យបញ្ចូលវត្ថុបញ្ចាំផ្សេងទៀតដើម្បីដាក់បញ្ចាំអោយបានគ្រប់គ្រាន់។ ប្រភេទនិងតម្រូវការនៃវត្ថុបញ្ចាំត្រូវបានរៀបរាប់លំអិតដូចខាងក្រោម ៖

**ក. ដាក់បញ្ចាំទឹកប្រាក់គណនី**

ប្រាក់បញ្ញើមានកាលកំណត់ត្រូវមានយ៉ាងហោចណាស់ចំនួន 133%នៃចំនួនប្រាក់កម្ចីសរុបដែលបានស្នើសុំ។ រយៈពេលនៃប្រាក់កម្ចីមិនលើសពីរយៈពេលដែលនៅសល់នៃប្រាក់ បញ្ញើមានកាលកំណត់ ឬអតិថិជនអាចពន្យារពេលបន្ថែមទៅប្រាក់បញ្ញើបានដើម្បីអោយស្របតាមរយៈពេលនៃការប្រើប្រាស់ឥណទាន។ ដើម្បីកំណត់លំអិតសូមមើលឧបសម្ព័ន្ធទី 2 ។

**ខ. ការដាក់បញ្ចាំដី ផ្ទះនិង អាគារ**

ការដាក់បញ្ចាំដី ផ្ទះនិង អាគារដោយប្រើប្លង់គឺតម្រូវអោយតម្លៃនៃវត្ថុបញ្ចាំនោះមានតម្លៃយ៉ាងហោចណាស់ 150% នៃចំនួនប្រាក់កម្ចីសរុបដែលបានផ្តល់។

➢ **ប្រភេទឯកសារទ្រព្យដាក់បញ្ចាំ និងលក្ខខណ្ឌតម្រូវ**

ដោយសារតែរាជរដ្ឋាភិបាលកម្ពុជាយើងមិនទាន់បានផ្តល់ ឬចេញឯកសារសំគាល់ម្ចាស់កម្មសិទ្ធដែលមានទម្រង់ដូចគ្នាតែមួយសម្រាប់ អោយប្រជាពលរដ្ឋគ្រប់រូបនៅទូទាំងប្រទេសកម្ពុជាដែលមានសិទ្ធពាក់ព័ន្ធទៅនឹងការកាន់កាប់ ដី ផ្ទះរឺអគារ ដូច្នេះហត្ថាកសិករបានគោលការណ៍ ក្នុងការធ្វើយ៉ាងណា ដើម្បីធានាឱ្យមានសុវត្ថិភាពលើឥណទាន ស្ថាប័នបានទទួលយកសំរាប់ការដាក់បញ្ចាំគឺជាប្រភេទប្លង់រឹង ( Hard Title ) និងប្លង់ទន់ ( Soft Title )យកមកធ្វើជាវត្ថុធានាឥណទាន ៖

- ប្រភេទប្លង់រឹង( Hard Title ): ជាប្រភេទឯកសារដែលចេញនិងគ្រប់គ្រងដោយការិយាល័យសុរិយោដីថ្នាក់ ស្រុក/ខណ្ឌ ខេត្ត/ក្រុង ហេតុដូច្នេះឯកសារមានតែមួយសន្លឹកសំរាប់ម្ចាស់កម្មសិទ្ធនិង ជាឯកសារដែលមានសិទ្ធនិងអាទិភាពទីមួយសម្រាប់ឯកសារបញ្ចាំ។

- វិញ្ញាបនប័ត្របញ្ជាក់កម្មសិទ្ធលើអចលនវត្ថុ ចេញចាប់ពីឆ្នាំ២០០៨
- ប័ណ្ណសំគាល់សិទ្ធកាន់កាប់អចនៈទ្រព្យ (កម្មសិទ្ធលើដី)
- វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលៈទ្រព្យ (គំរូកម្មសិទ្ធផ្ទះ)
- ប័ណ្ណសំគាល់សិទ្ធកាន់កាប់អចនវត្ថុ ចេញក្រោយឆ្នាំ១៩៨៩ ( កម្មសិទ្ធដី)
- ប័ណ្ណសំគាល់សិទ្ធកាន់កាប់ដីធ្លី (ដីគោគ) ចេញដំបូងថ្ងៃទី ២២ ខែមេសា ឆ្នាំ ១៩៨៩ ដល់ឆ្នាំ ១៩៩៨។

- ប្រភេទប្លង់ទន់ ( Soft Title ) : ត្រូវបានចេញដោយអាជ្ញាធរមូលដ្ឋាន ដូចជាប្រធានភូមិមេឃុំឬអភិបាលខេត្តដើម្បីបញ្ជាក់ពីសិទ្ធិ របស់ប្រជាពលរដ្ឋក្នុងការកាន់កាប់ និងអាស្រ័យផលលើទ្រព្យសម្បត្តិនោះ។ឯកសារនេះមានច្រើនសន្លឹក និងអាចត្រូវចេញច្រើនដងពីអាជ្ញាធរមូលដ្ឋាន។ ដូច្នេះវាត្រូវបានចាត់ទុកថាជាអាទិភាពចុងក្រោយសម្រាប់ការដាក់បញ្ចាំលើកម្ចីនៅហត្ថាកសិករ។ យោងទៅលើហានិភ័យឥណទាននៃកម្ចីទាំងអស់ដែលត្រូវដែលបានខ្ចីដោយប្រើប័ណ្ណទន់ ត្រូវបានកំណត់ថាជាឥណទានគ្មានសុវត្ថិភាព។ ឆ្លងតាមការអនុវត្តកន្លងមករបស់ប្រតិបត្តិករ ហត្ថាកសិករទទួលបានជោគជ័យ ដោយមានការតម្រូវឱ្យមន្ត្រីឥណទាន ធ្វើការសិក្សាបន្ថែមយ៉ាងស៊ី

ជម្រៅទៅលើការវិភាគរបស់ប្រតិបត្តិករ ទៅលើភាពត្រឹមត្រូវនៃឯកសារធានា និងសមត្ថភាពរបស់អ្នកខ្ចីមុននឹងផ្តល់ប្រាក់កម្ចី ហើយប្រតិបត្តិករ ត្រូវមានទំនាក់ទំនងល្អជាមួយអាជ្ញាធរមូលដ្ឋាននៅក្នុងតំបន់នៃប្រតិបត្តិការរបស់ពួកគេ។

ដើម្បីទទួលបានប្រាក់កម្ចី ហត្ថាកសិករបានកំណត់លក្ខខណ្ឌដល់សហគ្រាសធុនតូចនិងមធ្យម គឺតម្រូវអោយមានឯកសារបញ្ជាក់ពាក់ព័ន្ធនឹងទំហំឥណទានដែលស្នើសុំ។ **សូមមើលនៅឧបសម្ព័នទី ១០។**

### ៣.៣.៣.២ ការវាយតម្លៃនិង ការធានាសុវត្ថិភាពទ្រព្យដាក់បញ្ចាំ

ដើម្បីឱ្យការវាយតម្លៃលើទ្រព្យដាក់បញ្ចាំមានតុល្យភាពរវាង ស្ថាប័ន និងអតិថិជន។ ហត្ថាកសិករបានប្រើប្រាស់គោលការណ៍ មួយចំនួនដូចជា៖

- សម្រាប់ឥណទានសហគ្រាសធុនតូចនិងមធ្យមចាប់ពី 50.000ដុល្លារ ដល់100.000ដុល្លារ ឬសមមូលជារូបិយប័ណ្ណផ្សេងទៀត អ្នកវាយតំលៃទ្រព្យសម្បត្តិយ៉ាងហោចណាស់មានពីរនាក់ជាបុគ្គលិកហត្ថាកសិករ ត្រូវធ្វើការវាយតម្លៃវត្ថុបញ្ចាំរបស់អ្នកខ្ចីប្រាក់។ អ្នកវាយតំលៃទ្រព្យសម្បត្តិមានដូចជាមន្រ្តីឥណទានសហគ្រាសធុនតូច និង មធ្យមជាមួយប្រធានសាខាឬអនុប្រធានប្រធានផ្នែកឥណទានឬអនុប្រធានសាខាឥណទាន។
- សម្រាប់ក្រុមហ៊ុនសហគ្រាសធុនតូច និងមធ្យមចង់ខ្ចីច្រើនជាង $100,000 ទៅ $ 200,000 ឬសមមូលទៅនឹងរូបិយប័ណ្ណផ្សេងទៀតត្រូវបានតម្រូវឱ្យធ្វើការវាយតំលៃវត្ថុបញ្ចាំរបស់អតិថិជនដោយត្រូវជួលក្រុមហ៊ុនអចលនទ្រព្យ។ អ្នកខ្ចីត្រូវទទួលខុសត្រូវក្នុងការបង់ថ្លៃឈ្នួលដែលជាប់ពាក់ព័ន្ធជាមួយនឹងការវាយតម្លៃទ្រព្យធានា ជាមួយក្រុមហ៊ុនអចលនទ្រព្យក្នុងការវាយតម្លៃ។ ហត្ថាកសិករមានភារកិច្ចទទួលខុសត្រូវទំនាក់ទំនងជាមួយក្រុមហ៊ុនអចលនទ្រព្យដើម្បីពន្លឿនដំណើរការនៃការវាយតម្លៃ។ ទោះបីជាវត្ថុបញ្ចាំរបស់អ្នកខ្ចី ត្រូវបានវាយតម្លៃដោយភ្នាក់ងារឯករាជ្យក៏ដោយ ក៏ហត្ថាកសិករនឹងនៅតែតម្រូវឱ្យមាន បុគ្គលិកពីរនាក់បន្ថែមទៀតដើម្បីធ្វើការវាយតម្លៃឡើងវិញហើយត្រូវប្រាកដថាការវាយតម្លៃដែលទទួលបាននោះគឺត្រឹមត្រូវ។
- ការវាយតម្លៃទ្រព្យបញ្ចាំត្រូវតែធ្វើឡើងរៀងរាល់វគ្គឥណទានខ្ចីរបស់អតិថិជន។
- ប្រាក់កម្ចីពី 50.000 ដុល្លារដល់ 100.000 ដុល្លារឬសមមូលជារូបិយប័ណ្ណផ្សេងទៀត។ ក្នុងករណីដែលតម្លៃដីមិនគ្រប់គ្រាន់ដើម្បីខ្ចីប្រាក់ រឺក៏ស្ថានភាពដីមានភាពស្មុគស្មាញនិងមិនអនុលោមតាមកម្ចីខ្នាតតូចនិងមធ្យម អតិថិជនអាចយកផ្ទះ ទៅដាក់បញ្ចាំបន្ថែមបាន ដោយតម្រូវអោយអតិថិជនទិញធានារ៉ាបរង់ ឬប្រសិនបើផ្ទះស្ថិតនៅទីតាំងដែលមានគ្រោះថ្នាក់ដូចជានៅជិតស្ថានីយ៍ប្រេងឥន្ទនៈ ឬការអភិវឌ្ឍរបស់រដ្ឋាភិបាលជាដើម។ ការធានារ៉ាប់រងត្រូវតែទិញយ៉ាងហោចណាស់បីឆ្នាំ។
- សម្រាប់ប្រាក់កម្ចីសហគ្រាសធុនតូចនិងមធ្យមមានចំនួនច្រើនជាង 100.000ដុល្លារដល់ 200.000 ដុល្លារឬសមមូលជារូបិយប័ណ្ណផ្សេងទៀត ដោយយកផ្ទះទៅដាក់បញ្ចាំគឺត្រូវបានតម្រូវឱ្យទិញធានារ៉ាប់រងលើផ្ទះយ៉ាងហោចណាស់បីឆ្នាំ។

### ៣.៣.៤ ការអនុម័តឥណទាន

BM/CCU/IRC ត្រូវធ្វើការត្រួតពិនិត្យឯកសារឥណទានដែរស្នើរដោយមន្ត្រីឥណទាននិងចុះទៅត្រួតពិនិត្យ និងអង្កេតឡើងវិញដោយប្រៀបធៀបព័ត៌មានដែលចុះអង្កេតជាមួយ ព័ត៌មានដែលផ្តល់ដោយមន្ត្រីឥណទាន។ ពេលចុះអង្កេតលើកទី២ BM/CCU/IRC តម្រូវពិនិត្យនិងផ្ទៀងផ្ទាត់ព័ត៌មានរបស់អតិថិជនដែរមានលើពាក្យស្នើសុំ ទម្រង់គម្រោងជំនួញរបស់អតិថិជន។ BM/CCU/IRC អាចសាកសួរបន្ថែមក្នុងករណីដែលព័ត៌មានមួយចំនួនមិនច្បាស់លាស់ ហើយត្រូវការពន្យល់បន្ថែមពីគម្រោងចំណាយ ឬព័ត៌មានមួយចំនួនដែលបណ្តាលអោយមានការពិបាកសម្រេចចិត្ត។ បន្ទាប់ពី BM/CCU/IRC បានចុះពិនិត្យមើលនិង ប្រមូលពត៌មានបានច្បាស់លាស់អស់ហើយ និងតម្រូវអោយមានការបញ្ជូនព័ត៌មានបន្តទៅកាន់ នាយកដ្ឋានឥណទាននៅការិយាល័យកណ្តាលដើម្បីគណៈកម្មការធ្វើការប្រជុំសម្រេច។

#### ៣.៣.៤.១ កម្រិត និងសិទ្ធិអនុវត្តឥណទាន

គណៈកម្មាធិការឥណទានក្រុមប្រឹក្សាភិបាល (Board credit committee)

- មានសិទ្ធិអនុម័តលើទំហំឥណទាន >៨០ ពាន់ដុល្លារសមមូលនឹងរូបិយប័ណ្ណផ្សេងៗ
- វាយតំលៃនិងអនុម័តលើពាក្យស្នើរសុំឥណទានដែលមានលក្ខខណ្ឌមិនស្ថិតអំណាចរបស់ (MCC)
- ត្រួតពិនិត្យនិងផ្តល់សិទ្ធិអនុម័តឥណទានមកគណៈកម្មាធិការឥណទានថ្នាក់គ្រប់គ្រង (MCC)

គណៈកម្មាធិការឥណទានថ្នាក់គ្រប់គ្រង( Management credit committee)

គណៈកម្មាធិការឥណទានថ្នាក់គ្រប់គ្រងសមាសភាព(MCC) មាន៣រូបគឺ ៖

១. អនុប្រធានអគ្គនាយក និងជាអគ្គនាយកអនុម័តឥណទាន (ប្រធាន)

២. នាយកនាយកដ្ឋានអនុម័តឥណទាន (សមាជិក)

៣. នាយកនាយកដ្ឋានគ្រប់គ្រងហានិភ័យ (សមាជិក)

#### ៣.៣.៤.២ មុខងាររបស់គណៈកម្មការឥណទាន

- វាយតម្លៃផែនការអាជីវកម្មរបស់អ្នកខ្ចីប្រាក់ តាមរយៈការវាយតម្លៃនិង វិភាគព័ត៌មានទាំងអស់ដែលប្រមូលដោយមន្ត្រីឥណទានរបស់សហគ្រាសធុនតូចនិងមធ្យម។
- វាយតម្លៃប្រាក់កម្ចីឡើងវិញដើម្បីធានាថាវាអាចជឿទុកចិត្តបាន និងមានភាពត្រឹមត្រូវ។
- ផ្ទៀងផ្ទាត់លក្ខខណ្ឌនៃអ្នកខ្ចីតាមនីតិវិធី និងគោលការណ៍ឥណទានរបស់សហគ្រាសធុនតូចនិងមធ្យម។
- អនុម័តពន្យារពេលក្នុងការកែសម្រួល និងបដិសេធការខ្ចីប្រាក់របស់អ្នកខ្ចី។
- អនុម័តករណីពិសេសមួយចំនួនដូចមានចែង ក្នុងគោលនយោបាយនិងនីតិវិធីឥណទានរបស់សហគ្រាសធុនតូចនិងមធ្យម។

**៣.៣.៤.៣ លំហូរការងាររបស់គណៈកម្មាធិការឥណទាន**

គណៈកម្មាធិការឥណទានការិយាល័យកណ្តាល

- សេចក្តីសម្រេចចិត្តនៃការអនុម័តត្រូវតែ អាស្រ័យលើការសម្រេចចិត្តរបស់ គណៈកម្មាធិការឥណទានភាគច្រើនមិនមែនគ្រាន់តែជាឋានៈខ្ពស់បំផុតនោះទេ។

- ការិយាល័យអ្នកវិភាគប្រាក់កម្ចីរបស់សហគ្រាសធុនតូច និងមធ្យមត្រូវវិភាគប្រាក់កម្ចីភ្លាមៗបន្ទាប់ពីទទួលបានពីសាខា ហើយហៅទូរស័ព្ទទៅមន្ត្រីឥណទាន របស់សហគ្រាសធុនតូច និងមធ្យមនិងបុគ្គលិកពាក់ព័ន្ធទាំងអស់តាមទូរស័ព្ទដើម្បីសួរសំណួរ។

- បន្ទាប់ពីការវិភាគប្រាក់កម្ចីនិងការរៀបចំឯកសារ អ្នកវិភាគប្រាក់កម្ចីរបស់សហគ្រាសធុនតូច និងមធ្យមត្រូវទទួលខុសត្រូវចំពោះការដាក់ស្នើឯកសារចាំបាច់ទៅការិយាល័យកណ្តាលរបស់ធនាគារដើម្បីសុំការអនុម័ត។ ឯកសារត្រូវបញ្ជូនទៅកាន់នាយកដ្ឋានប្រតិបត្តិការណ៍មុនគេ។

- ដំណើរការអនុម័តត្រូវបានធ្វើឡើងដោយការធ្វើចរាចរឯកសារ ចេញពីនាយកដ្ឋានប្រតិបត្តិការណ៍ ទៅនាយកដ្ឋានគ្រប់គ្រងហានិភ័យ និងបន្តទៅកាន់ជំនួយការអគ្គនាយក។ សមាជិកនៃគណៈកម្មាធិការអាចប្រជុំគ្នាសម្រេចតែម្តងតាមស្ថានភាពការងារ។ ការអនុម័តរបស់គណៈកម្មការឥណទាន តម្រូវឱ្យមានការបញ្ជាក់បន្ថែម "ការអនុម័ត" ដើម្បីអាចប្រើការបាន។

**៣.៣.៤.៤ គណៈកម្មការឥណទាន**

- បន្ទាប់ពីទទួលបានទទួលឯកសារប្រាក់កម្ចី ដែលតម្រូវឱ្យមានការអនុម័តពីគណៈកម្មាធិការឥណរទានរួច ក្រុមការងារនាយកនាយកដ្ឋានឥណទានរបស់សហគ្រាសធុនតូចនិងមធ្យមទទួលខុសត្រូវក្នុងការវិភាគ និងរៀបចំសំណើប្រាក់កម្ចីជាភាសាអង់គ្លេសដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលដើម្បីធ្វើការអនុម័តតាមអ៊ីម៉ែល។

- សេចក្តីសម្រេចចិត្តនៃការអនុម័តត្រូវតែអាស្រ័យការសម្រេចចិត្តរបស់ គណៈកម្មាធិការឥណទានភាគច្រើនមិនមែនគ្រាន់តែជាឋានៈខ្ពស់នោះទេ។

- គ្រប់ក្រុមប្រឹក្សាគណនេយ្យទាំងអស់តំរូវឆ្លើយតប ឬធ្វើរការសំរេចចិត្តអនុម័តតាមអ៊ីម៉ែលទៅកាន់នាយកនាយកដ្ឋានឥណទានសហគ្រាសធុនតូចនិងមធ្យម។ ដើម្បីបញ្ជាក់ពីការអនុម័តនាយកនាយកដ្ឋានឥណទានសហគ្រាសធុនតូច និងមធ្យមអាចធ្វើការបោះពុម្ភសេចក្តីអនុម័តទាំងស្រុងពីសារអេឡិចត្រូនិច ដើម្បីបញ្ជាក់ជាមួយឯកសារឥណទាន ដើម្បីបញ្ជាក់ពីការអនុម័តឥណទាននិងដើម្បីឱ្យលេខាធិការក្រុមប្រឹក្សាឥណទានធ្វើជាកំណត់ហេតុសង្ខេបឥណទានបញ្ជាក់ពីការអនុម័ត និងដើម្បីឱ្យសមាជិកក្រុមប្រឹក្សាភិបាលដែលបានអនុម័តទាំងអស់បានចុះហត្ថាលេខា។**សូមមើលនៅឧបសម្ព័ន្ធទី១១។**

**៣.៣.៥ ការរៀបចំឯកសារមុនពេលបញ្ចេញឥណទាន**

ក្រោយពីឥណទានត្រូវបានអនុម័ត ក៏ដូចជាអតិថិជនព្រមព្រៀងទទួលយកប្រាក់កម្ចីតាមការអនុម័ត ភ្នាក់ងារឥណទានត្រូវទទួលខុសត្រូវ៖

- រៀបចំឯកសារមួយចំនួនដូចជា កិច្ចសន្យាដាក់បញ្ចាំ ខ្ចីចងការប្រាក់ ឯកសារបើកគណនីសន្សំ។

- ត្រូវធ្វើការណាត់ជួបអតិថិជន ដើម្បីធ្វើការផ្តិតមេដៃ ប៉ុន្តែមុននិងធ្វើការផ្តិតមេដៃ ភ្នាក់ងារឥណទានត្រូវតែអាន និងពន្យល់បកស្រាយឱ្យបានច្បាស់លាស់ពីខ្លឹមសារ ការទទួលខុសត្រូវ ជាពិសេសពន្យល់ពីចំនួនទឹកប្រាក់ដែលបានខ្ចី ចំនួនត្រូវសងប្រហាក់ប្រហែលក្នុងមួយខែ អត្រាប្រាក់ប្រចាំខែ ទ្រព្យធានា ទីកន្លែងបង់ប្រាក់ ពេលវេលាបង់ប្រាក់ វិន័យផ្សេងៗដូចជាការយឺតត្រូវមានការផាកពិន័យ និងចុះតាមដានដល់ផ្ទះ។

- ឯកសារឥណទាននានាមិនត្រូវមានការកោសលុប ឬប្រើទឹកលុប ហើយការផ្តិតមេដៃត្រូវតែច្បាស់និងងាយស្រួលកំណត់ខ្ទៅដៃ។

- កិច្ចសន្យាដាក់បញ្ចាំតម្រូវឱ្យចុះហត្ថលេខា និងបោះត្រាអ្នកតំណាងហត្ថាកសិករមុននិងផ្តល់អតិថិជនយកទៅរត់ការ។

- ណាត់ពេលវេលាអតិថិជនមកបើកប្រាក់ និងពន្យល់ណែនាំអំពីការឯកសារនានាពេលបើកប្រាក់។

- នៅពេលដែលអតិថិជនមកបើកប្រាក់ និងភ្ជាប់ជាមួយឯកសារ គណនេយ្យករធ្វើការពិនិត្យថាតើ ត្រឹមត្រូវ គ្រប់គ្រាន់ ហើយបោះពុម្ពនូវតារាងកាលវិភាគសងប្រាក់ សក្ខីប័ត្របញ្ចេញសាច់ប្រាក់។ប្រសិនបើឯកសារត្រឹមត្រូវ រដ្ឋបាលត្រូវបញ្ជូនឯកសារទៅនាយកសាខា ដើម្បីត្រួតពិនិត្យចុះហត្ថាលេខា និងប្រថាប់ត្រាលើឯកសារឥណទាន ដើម្បីឯកភាពបញ្ចេញសាច់ប្រាក់។

### ៣.៣.៦ ការបញ្ចេញឥណទាន

បេឡាករត្រូវត្រួតពិនិត្យភាពគ្រប់គ្រាន់នៃឯកសារតម្រូវ ទៅតាមគោលនយោបាយឥណទានទូទៅរបស់ហត្ថាកសិករ រួមទាំងបណ្ណ័ធានារ៉ាប់រង(បើមាន)។ ករណីមានលក្ខណៈត្រឹមត្រូវគ្រប់គ្រាន់អស់ហើយ ដំណើរបញ្ចេញប្រាក់ត្រូវអនុវត្តតាមនីតិវិធីអនុវត្តបច្ចុប្បន្នរបស់ហត្ថាកសិករដូចមានចែងក្នុងគោលការណ៍ប្រតិបត្តិឥណទានទូទៅ។

- មុនពេលបើកប្រាក់ ៖ ត្រួតពិនិត្យថាតើអតិថិជនជាប្រភេទ Loan top upឬRefinance other bank អតិថិជនទាំងអស់ត្រូវមកបើកប្រាក់នៅសាខាដែលខ្លួនស្នើខ្ចីហើយភ្ជាប់មកនូវកិច្ចសន្យាបង្កើតហ៊ីប៉ូតែក កិច្ចសន្យាធានា និងឯកសារផ្សេងៗទៀតបើមាន ។

- ពេលបើកប្រាក់

- រំលឹកវិន័យឥណទាន និង ធានាថាអតិថិជនបានយល់ច្បាស់

- ពន្យល់ប្រាប់អតិថិជនអំពីសាច់ប្រាក់ដែលបានខ្ចី និងរាប់ឲ្យបានច្បាស់

### ៣.៣.៧ ការតាមដានអតិថិជន

ដើម្បីឱ្យប្រាកដថាឥណទានដែលបញ្ចេញជូនអតិថិជនទាំងអស់ មិនមានហានិភ័យ ហត្ថាកសិករលីមីតធីតបានកំណត់គោលការណ៍យ៉ាងច្បាស់ ដើម្បីឱ្យមន្ត្រីឥណទានក្នុងការអនុវត្ត ក៏ដូចជាធ្វើការតាមដានទៅអតិថិជនដើម្បីជៀសវាងហានិភ័យណាមួយកើតឡើង។ដោយតម្រូវអោ

យគ្រប់ការតាមដានទាំងអស់មានជារបាយការណ៏ និងរក្សាទុកក្នុងឯកសារឥណទាន រួចរៀបចំឯកសារឥណទានបញ្ជូនទៅកាន់នាយកដ្ឋានផ្នែកលក់ឥណទាន។

### ៣.៣.៨ ការសងត្រឡប់មកវិញ

របៀបសងឥណទានរបស់ហត្ថាកសិករបាន ធ្វើការបែងចែកជា ៣ ក្រុមដូចខាងក្រោម៖

➢ សងការប្រាក់ និងប្រាក់ដើមប្រចាំខែ (Monthly Repayment Method )

- សង់រំលោះប្រាក់ដើម និងការប្រាក់ប្រចាំខែ (Declining Repayment)
- សងរំលោះប្រាក់ដើម និងការប្រាក់ថេរប្រចាំខែ (Annuity Repayment)

➢ សងការប្រាក់និងប្រាក់ដើមតាមកាលកំណត់ (Balloon Repayment Method)

- សងការប្រាក់រាល់ខែ ប្រាក់ដើមសងតាមការចរចា(Negotiation Principle Method)
- សងការប្រាក់រាល់ខែ ប្រាក់ដើមសងជាភាគរយ(Monthly Percentage Principle Repayment)

➢ សងការប្រាក់ និងប្រាក់ដើមចុងវគ្គ (Bullet Repayment Method)

- សងការប្រាក់ប្រចាំខែ និងប្រាក់ដើមនៅចុងវគ្គ (Bullet Repayment)

### ៣.៣.៩ ការសងផ្តាច់

ដើម្បីបំពេញតម្រូវការអតិថិជន ហត្ថាកសិករ លីមីតធីតបានសម្រួលនិងអនុញ្ញាតឱ្យអតិថិជន ទាំងអស់ដែលបានប្រើប្រាស់ឥណទានខ្នាតតូចនិងមធ្យមទាំងអស់អាចធ្វើការបង់ផ្តាច់ឥណទានទាំងអស់ដែលនៅសល់ដោយគ្មានការផាកពិន័យអ្វីទាំងអស់។ ការបង់ផ្តាច់មុននេះត្រូវអនុលោមតាមរូបមន្តដូចខាងក្រោម ៖

- ការសងផ្តាច់ធ្វើឡើងក្នុងខែដែលមានចំនួនប្រើប្រាស់ឥណទានតិចជាងឬស្មើរនិង១៥ថ្ងៃ គឺការប្រាក់ត្រូវទូទាត់សងតាមចំនួនថ្ងៃដែលប្រើប្រាស់ជាក់ស្តែង។
- ការសងផ្តាច់ធ្វើឡើងក្នុងខែដែលមានចំនួនថ្ងៃប្រើឥណទានច្រើនជាង១៥ថ្ងៃគឺប្រាក់ទូទាត់សងមួយខែពេញអនុលោមទៅតាមតារាងសងប្រាក់។

ការធ្វើវិសោធកម្មនេះអាចធ្វើបាន លុះត្រាតែមានការធ្វើការស្នើសុំដោយផ្ទាល់មាត់ពីសំណាក់អតិថិជននោះ( ដោយត្រូវឱ្យមានការសរសេរ ជាលាយល័ក្ខអក្សរ) និងត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖

- ប្រាក់ដើមត្រូវធ្វើការបង់សងមុនយ៉ាងតិចស្មើនិង៣ខែនៃប្រាក់ ដែលត្រូវបង់សងប្រចាំខែ។
- រយៈពេលឥណទានអាចតិចជាង ឬស្មើនិងឥណប្រតិទាន(រយៈពេលឥណទាន) ដែលនៅសល់។
- អត្រាការប្រាក់ត្រូវអនុលោមតាមការប្រាក់ដែលបានអនុលោមទៅតាមកិច្ចសន្យាខ្ចីចងការប្រាក់។

- ត្រូវមានការយល់ព្រមពីប្រធានសាខា។ រាល់ការរៀបចំធ្វើវិសោធកម្មលើតារាងកាលវិភាគសងការប្រាក់នេះត្រូវមានការចរចារបញ្ជាក់ ពីប្រធានសាខាលើតារាងសងការប្រាក់ចាស់ និងភ្ជាប់ជាមួយនិងតារាងកាលវិភាគសងការប្រាក់ថ្មីក្នុងឯកសារឥណទានរបស់អតិថិជន។

- ដំណាក់នៃការធ្វើវិសោធកម្មនៃការសងប្រាក់មាន ៤ ដំណាក់កាលដូចមានចែងយ៉ាងលំអិតក្នុង **ឧបសម្ព័ន ៤។**

### ៣.៣.១០ ការដោះស្រាយក្នុងការខកខានសងឥណទានរបស់អតិថិជន

➢ កត្តាដែលបណ្ដាលឱ្យមានភាពយឺតយ៉ាវះ

- កត្តាខាងក្នុង
  - អនុវត្តប្រាសចាកពីនិតិវិធីគោលការណ៍ឥណទាន
  - ទំហំឥណទានលើសពីលទ្ធភាពនឹងទំហំត្រូវការពិតរបស់អតិជន
  - មិនសិក្សាឱ្យបានច្បាស់ពីលំហូរសាច់ប្រាក់នឹងត្រឹមត្រូវតាមបរិបទទីផ្សារ
  - សិក្សាពីប្រវត្តិរបស់អតិថិជនមិនបានច្បាស់លាស់
  - កំពុងមានបំណុលជាមួយអ្នកដ៏ទៃ
  - វាយតម្លៃទ្រព្យធានាមិនបានត្រឹមត្រូវ
  - បញ្ចេញឥណទានដើម្បីកាតបន្ថយហានិភ័យឬក្នុងន័យប្រកួតប្រជែង
- កត្តាខាងក្រៅ
  - កង្វះខាតនៃការទទួលខុសត្រូវពីអាជ្ញាធរដែលបានចេញឯកសារដីធ្លីច្រើន
  - ភាពទន់ខ្សោយនៃច្បាប់សង្គម
  - សំពាធបរិយាកាសនៃការប្រគួតប្រជែង
  - ការប្រែប្រួលនយោបាយឬសេដ្ឋកិច្ច
  - គ្រោះធម្មជាតិឬគ្រោះថ្នាក់ផ្សេ

## ៣.៤ ការកាត់បន្ថយហានិភ័យ លើការផ្ដល់ឥណទាន

### ៣.៤.១ និយមន័យហានិភ័យឥណទាន

ហានិភ័យឥណទាន គឺជាការខាតបង់ឥណទានដោយសារតែកូនបំណុលមិនបានសងឥណទានមកវិញតាមកិច្ចសន្យា។ មូលហេតុសំខាន់ៗដែលបណ្ដាលឱ្យមានហានិភ័យឥណទានកើតឡើងះ

➢ ហានិភ័យប្រតិបត្តិការ : ជាឱកាសនៃការបរាជ័យឬបាត់បង់នូវលទ្ធផលដោយសារតែខ្វះខាត ឬការបង្កឱ្យមានកំហុសឆ្គងទាក់ទងទៅនឹង

- មនុស្ស
- ដំណើរការអនុវត្តការងារប្រចាំថ្ងៃ
- ការគ្រប់គ្រងពត៍មានវិទ្យា
- ឥទ្ធិពលនៃប្រត្តិការណ៍ខាងក្រៅ

➢ ហានិភ័យឥណទាន : គឺជាការខាតបង់ឥណទានដោយសារតែកូនបំណុលមិនព្រមសងឥណទានតាមកិច្ចសន្យាកំណត់។

➢ ហានិភ័យហិរញ្ញវត្ថុ : ជាការខាតបង់ដោយសារតែស្ថាប័នមិនអាចគ្រប់គ្រងសាច់ប្រាក់និងលំហូរសាច់ប្រាក់របស់ខ្លួនបានល្អ។

### ៣.៤.២ វាស់វែងគុណភាពឥណទាន

ផលិតផលឥណទាន គឺជាផលិតផលស្នូលរបស់ហត្ថាកសិករហើយម្យ៉ាងទៀតឥណទាន (កម្ចី) ក៏ជាទ្រព្យសម្បត្តិស្ទើរតែទាំងអស់របស់ហត្ថាកសិករ។ ទ្រព្យសកម្មនេះអាចប្រឈមនិងហានិភ័យខ្ពស់ ប្រសិនបើអ្នកខ្ចីជាច្រើនមិនអាចសងបំណុលតាមកិច្ចសន្យាខ្ចីបាន។

ដូច្នេះហានិភ័យឥណទាន និងការវាស់វែងគុណភាពគឺជាឧបករណ៍ដែលក្រុមហ៊ុនហត្ថាកសិករចាំបាច់ត្រូវប្រើដើម្បីវាស់គុណភាពឥណទានបច្ចុប្បន្ននិងអនាគត។ វិធីសាស្ត្រក្នុងការវាស់វែងត្រូវបានបញ្ជាក់ដូចតទៅៈ

- អត្រាឥណទានយឺតយ៉ាវកំពុងប្រឈម គឺជាសមាមាត្ររវាងចំនួនបំណុលហួសកំណត់ដែលត្រូវបង់ទៅនិងសមតុល្យឥណទានសរុប។

$$\text{អត្រាឥណទានយឺតយ៉ាវកំពុងប្រឈម}_{(\text{ចំនួនថ្ងៃ})} = \frac{\text{ចំនួនទឹកប្រាក់នៃការដាក់ពាក្យសរុបហួសកំណត់}}{\text{សមតុល្យឥណទានសរុប}} \times ១០០$$

កម្រិតហានិភ័យដែលប្រឈម (PAR) គឺជាសមាមាត្ររវាងផលប័ត្រប្រាក់កម្ចីហួសកំណត់ទៅនឹងផលប័ត្រឥណទានសរុប។

$$\text{កម្រិតហានិភ័យដែលប្រឈម}_{(\text{ចំនួនថ្ងៃ})} = \frac{\text{សមតុល្យប្រាក់ដើមនៃឥណទានដែលយឺតយ៉ាវ}}{\text{សមតុល្យឥណទានសរុប}} \times ១០០$$

ផលធៀបខាងលើនេះក្រៅពីអាចវាស់វែងលើកម្រិត និងគុណភាពរបស់ឥណទានរបស់ស្ថាប័នហត្ថាកសិករទាំងមូល ក៏ត្រូវបានយកមកប្រើក្នុងការវាស់លើកម្រិតហានិភ័យរបស់មន្ត្រីឥណទានមួយដែលទទួលបន្ទុកការិយាល័យសាខានីមួយៗ ។

ការគណនាផលធៀបទាំងពីរខាងលើ គឺត្រូវបានអនុលោមទៅតាមរយៈពេលនៃការបង់សងយឺតចាប់ពី ៣០ថ្ងៃឡើងទៅឬករណីលើសពី ៩០ថ្ងៃនិង ធំជាង៣៦០ថ្ងៃឡើងទៅ។

➢ អត្រាហានិភ័យសម្រាប់ភ្នាក់ងារឥណទាន

> ០% ទៅ <០.៥ % ត្រូវចាត់ទុកថាអនុវត្តបានល្អណាស់

> 0.៥% ទៅ >0.១% ការអនុវត្តអាចទទួលយកបាន

> ១% ទៅ <២% ការអនុវត្តនៅខ្សោយ ត្រូវពង្រឹងបន្ថែម

> ២% លិទ្ធផលមិនអាចទទួលយកបាន ត្រូវមានវិធានការ

➢ អត្រាហានិភ័យសម្រាប់សាខា

> 0% ទៅ <0.៥ % ត្រូវចាត់ទុកថាអនុវត្តបានល្អណាស់

> 0.៥% ទៅ >0.១% ការអនុវត្តអាចទទួលយកបានតែត្រូវពង្រឹងបន្ថែម

> ១% ទៅ <២% ការអនុវត្តនៅខ្សោយ ត្រូវពិនិត្យលើការធ្វើឥណទានបច្ចុប្បន្ន និងពង្រឹងបន្ថែមជាបន្ទាន់

> ២% លទ្ធផលមិនអាចទទួលយកបានត្រូវមានវិធានការ

### ៣.៤.៣ យុទ្ធសាស្ត្រក្នុងការកាត់បន្ថយហានិភ័យឥណទាន

ដើម្បីទប់ស្កាត់ នឹងកាត់បន្ថយហានិភ័យលើការផ្តល់ឥណទាន ហត្ថាកសិករបានបង្កើតនូវគោលការណ៍មួយចំនួន ដើម្បីឱ្យប្រតិបត្តិករឥណទានអនុវត្តន៍យ៉ាងតឹងរឹងដូចជា៖

➢ មន្ត្រីឥណទានត្រូវពង្រឹងឆន្ទៈ នឹងជំហរទទួលខុសត្រូវរបស់ខ្លួន

- ខិតខំធ្វើការតាមតួនាទី
- យល់ច្បាស់ពីកាតព្វកិច្ចរបស់ខ្លួន
- ដាក់ចិត្ត ដាក់កាយថានឹងអនុវត្តអោយបានល្អ
- ត្រូវគិតថាការខាតបង់របស់ស្ថាប័ន គឺជាការខាតបងរបស់ខ្លួន
- ត្រូវគិតថាការផ្តល់ឥណទានល្អ គឺជាការជួយទាញអតិថិជនចេញពីភាពក្រីក្រ

➢ ពង្រឹងការអនុវត្តតាមការណែនាំក្នុងគោលការណ៍ និងនិតិវិធីរបស់ស្ថាប័នអោយបានខ្ជាប់ខ្ជួន។

➢ បណ្តុះវិន័យឥណទានអោយបានច្បាស់លាស់(និយាយឱ្យចំៗត្រឹមត្រូវតាមគោលការណ៍ និងប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ)។

➢ វាយតម្លៃប្រាក់កម្ចីអោយបានត្រឹមត្រូវ(ត្រូវមានមូលដ្ឋានច្បាស់លាស់ នឹងមានអំនះអំណាងយ៉ាងត្រឹមត្រូវ យោងទៅតាមស្ថានភាពជាក់ស្តែងមុននិងធ្វើការសម្រេចចិត្តផ្តល់ឥណទាន)។

➢ កំណត់នឹងវាយតម្លៃទ្រព្យបញ្ចាំឱ្យបានត្រឹមត្រូវទៅតាមគោលការណ៍និងនិតិវិធី

➢ បង្កើនការតាមដាន ប្រមូលនឹងផ្ទៀងផ្ទាត់ ពត៏មានអោយបានគ្រប់ជ្រុងជ្រោយ។

➢ បញ្ឈប់ការដាក់ឥណទានជាន់គ្នាច្រើន(ស្ថាប័ន) និងពង្រឹងលើអតិថិជនដែលមានមុខរបរចងការប្រាក់ ។

➢ បង្កើនការសហការអោយកាន់តែជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាន។

➢ ចេះរំពឹងគិតពីគ្រោះថ្នាក់ធម្មជាតិ ឬបញ្ហាថៃដន្យផ្សេងៗ ដែលអាចនឹងកើតមានឡើងបានគ្រប់ពេល។

➢ «បង្កើតអោយមានសវនកម្មផ្ទៃក្នុង(Internal Audit) និងអ្នកត្រួតពិនិត្យឥណទានឯករាជ្យ ( Independent Credit Review ) ក្នុងគោលបំណងត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ថាប្រតិបត្តិករពិតជាបានធ្វើតាមការណែនាំរបស់ស្ថាប័ន ដើម្បីជៀសវាងកំហុសឆ្គងនិងហានិភ័យឥណទានដែលអាចកើតមានឡើង។

**៣.៤.៤ ការត្រួតពិនិត្យហានិភ័យឥណទាន**

ការត្រួតពិនិត្យឥណទានត្រូវបានធ្វើឡើងដើម្បីធានាឱ្យបានថាអតិថិជន មានលទ្ធភាពគ្រប់គ្រាន់ក្នុងការសងបំណុលឱ្យបានទៀងទាត់ បន្ទាប់ពីបានខ្ចីឥណទាននិងដើម្បីទប់ស្កាត់ជាមុននូវរាល់បញ្ហាដែលអាចកើតមានឡើង។ ការត្រួតពិនិត្យឥណទានត្រូវបានគេបែងចែកជាពីរប្រភេទ ៖

➢ ការត្រួតពិនិត្យជាប្រចាំ

មុនពេលមានហានិភ័យកើតឡើង នេះជាការត្រួតពិនិត្យជាប្រចាំទៅលើឥណទានដើម្បីអាចឱ្យយើងដឹងមុននិងកំណត់អំពីប្រភេទហានិភ័យដែលវាប្រុងនិងកើតមានឡើង។ យើងត្រូវធ្វើការត្រួតពិនិត្យទៅលើះ

- ការប្រើប្រាស់ឥណទានរបស់អតិថិជន។
- ស្ថានភាពមុខរបរ (ក្រោយពេលប្រើប្រាស់កម្ចី)។
- ស្ថានភាពគ្រួសារ (ក្រោយពេលប្រើប្រាស់កម្ចី)។
- ប្រភេទអាជីវកម្ម ឬមុខរបររបស់អតិថិជន។
- តើអតិថិជនមានបំណុលផ្សេងក្រៅពី ហត្ថាកសិករ ដែរឬទេ។
- ទ្រព្យធានាដែលអតិថិជនបានយកដាក់ធានាជាមួយ ហត្ថាកសិករ។
- ភូមិសាស្ត្រ ( ទីតាំងរស់នៅ)

➢ ការដោះស្រាយបំណុលក្រៅប្រព័ន្ធតុលាការ

- ការដោះស្រាយជាមួយហត្ថាកសិករតាមរយៈបុគ្គលិកហត្ថាកសិករ
  - មន្ត្រីឥណទាន
  - អ្នកប្រមូលឥណទានយឺតយ៉ាវ
  - ប្រធានផ្នែកឥណទាន
  - នាយកសាខា
  - នាយកតំបន់
  - ផ្នែកដោះស្រាយបំណូល (ការិយាល័យកណ្តាល)
  - ផ្នែកនិតិកម្មនឹងផ្នែកច្បាប់តំណាងអោយហត្ថាកសិករ
- ការដោះស្រាយជាមួយអាជ្ញាធរមូលដ្ឋាន
  - មេភូមិ
  - មេភូមិឬចៅសង្កាត់
  - អភិបាលស្រុក អភិបានខ័ណ្ឌ អភិបាលក្រុង

- ប៉ុស្តិ៍នគរបាលឃុំឬសង្កាត់
- អធិការនគរបាលស្រុក ខ័ណ្ឌ ក្រុង
- ស្នងការនគរបាលខេត្ត រាជធានី

➢ **ការធ្វើចំណាត់ថ្នាក់បំណុល**

- បំណុលស្តង់ដារ
  - ស្ថានភាពឥណទានល្អនិងការសងទៀងទាត់នៃប្រាក់ដើម និងការប្រាក់ឬសងយឺតយ៉ាវត្រឹម ៣០ថ្ងៃឬតិចជាងនេះ។
- បំណុលក្រោមស្តង់ដា
  - ការសងប្រាក់ដើម និង ការប្រាក់លើសពី ៣០ ថ្ងៃ។
- បំណុលសង្ស័យ
  - ការសងប្រាក់ដើម ឬការប្រាក់ដែលហួសកាលកំណត់
  - ច្រើនជាង៣០ថ្ងៃក្នុងករណីឥណទានមានឥណប្រតិទានតិចជាងឬស្មើ១ឆ្នាំ។
  - ច្រើនជាង ១៨០ ថ្ងៃ ក្នុងករណីឥណទានមានឥណប្រតិទានលើសពី ១ឆ្នាំ។
- បំណុលបាត់បង់
  - ការសងប្រាក់ដើម ឬការប្រាក់ដែលហួសកាលកំណត់
  - ច្រើនជាង៩០ថ្ងៃក្នុងករណីឥណទានមានឥណប្រតិទានតិចជាងឬស្មើ ១ឆ្នាំ។
  - ច្រើនជាង ៣៦០ ថ្ងៃ ក្នុងករណីឥណទានមានឥណប្រតិទានលើសពី ១ឆ្នាំ។
  - រយៈពេលយឺតយ៉ាវក្នុងការដោះស្រាយ
  - យឺតយ៉ាវពី ១ថ្ងៃ ទៅ៥ថ្ងៃ ត្រូវតែតាមដាននឹងរំលឹកអោយគាត់បង់ជាបន្ទាន់
  - យឺតយ៉ាវពី៦ថ្ងៃ ទៅ១៥ថ្ងៃ ត្រូវតែចុះទៅដោះស្រាយតាមយុទ្ធសាស្ត្ររវាងមន្ត្រីឥណទានជាមួយអ្នកធានា។
  - យឺតយ៉ាវពី ១៦ថ្ងៃ ទៅ ៣០ថ្ងៃ ត្រូវតែចុះទៅដោះស្រាយជាមួយប្រធានសាខាទៅដល់លំនៅដ្ឋាន ឬទីតាំងអាជីវកម្មរបស់អតិថិជន។ការដោះស្រាយក្នុងចំនុចនេះមានការដោះស្រាយមានពីរដំណាក់ការ គឺនៅលំនៅដ្ឋានរបស់អតិថិជននឹងនៅស្នាក់ការការិយាល័យហត្ថាកសិករ។
  - យឺតយ៉ាវពី ៣១ទៅដល់ ៩០ថ្ងៃ ត្រូវតែធ្វើលិខិតអញ្ជើញអតិថិជននិងអ្នកធានាបំណុលទៅសាលាឃុំឬសង្កាត់ដើម្បីធ្វើការដោះស្រាយជាមួយអាជ្ញាធរដោយធ្វើតាមលំដាប់លំដោយចាប់ពីមេភូមិ ឃុំ ចៅសង្កាត់ទៅដល់អភិបាល ស្រុកខណ្ឌ ក្រុង។
  - ការយឺតយ៉ាវពី ៩១ ថ្ងៃឡើងទៅបន្ទាប់ពីបានធ្វើការដោះស្រាយតាមជំហាន់ទី ១ រហូតដល់ទី៤ ហើយមិនទាន់មានដំណោះស្រាយទៀតគួរពិចារណាដោះស្រាយតាមប្រព័ន្ធតុលាកា

# ជំពូក ទី ៤
# ការវិភាគទិន្នន័យនៃការផ្ដល់ឥណទានគ្រឹះស្ថានមីក្រូ ហត្ថាកសិករ

## ៤.១ ស្ថានភាពឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត បានខិតខំប្រឹងប្រែងក្នុងការពង្រីកវិសាលភាពនឹងទំហំឥណទានរបស់ខ្លួនពីមួយឆ្នាំទៅមួយឆ្នាំ ព្រោះថាបច្ចុប្បន្ននេះមានការគំរាមកំហែងជាច្រើនពីសំណាក់ដៃគូប្រគួតប្រជែង តាមរយៈការទម្លាក់អត្រាការប្រាក់ឥណទានឱ្យមានកម្រិតនិងលក្ខខណ្ឌឥណទានមានភាពងាយស្រួលជាដើម។ ដោយឡែករយៈពេលបីឆ្នាំចុងក្រោយការបញ្ចេញឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីតសាខាបឹងកេងកងពីរ មានការប្រែប្រួលដែលគួរឱ្យកត់សំគាល់ ពោលគឺនៅឆ្នាំ ២០១៦ រហូតដល់ឆ្នាំ ២០១៨។

| ឆ្នាំ | ទំហំឥណទាន (ដុល្លារ) |
|---|---|
| ២០១៦ | 4035447.4 |
| ២០១៧ | 2849552.87 |
| ២០១៨ | 1892141.7 |

**ក្រាភិចបង្ហាញពីទំហំឥណទានដែលបានបញ្ចេញ**



**បំណកស្រាយក្រាភិច**

យោងតាមទិន្នន័យដែលបង្ហាញអោយឃើញនៅក្នុងក្រាភិចខាងលើបានបង្ហាញថាៈ បរិមាណទំហំឥណទានខ្នាតតូច និងមធ្យមរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហាត្ថាកសិករ លីមីធីត សាខាបឹងកេងកងពីរមានការធ្លាក់ចុះពីមួយឆ្នាំទៅមួយឆ្នាំ ពោលគឺនៅឆ្នាំ២០១៦រហូតដល់ឆ្នាំ ២០១៨។

ការវិភាគលើចំនួនអតិថិជនដែលទទួលបានឥណទានឆ្នាំ២០១៦ រហូតដល់ ២០១៨

| ឆ្នាំ | ចំនួនអតិថិជន (នាក់) |
|---|---|
| ២០១៦ | ៩២ |
| ២០១៧ | ៦៧ |
| ២០១៨ | ៥១ |

ក្រាភិចនៃចំនួនអតិថិជនដែលទទួលបានឥណទានឆ្នាំ ២០១៦ រហូតដល់ ២០១៨




ដោយយោងទៅតាមទិន្នន័យដែលបង្ហាញក្នុងក្រាភិចខាងលើ គឺជាចំនួនអតិថិជនដែលបានមកប្រើប្រាស់សេវាកម្មឥណទានរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហាត្ថាកសិករ លីមីតធីត សាខាបឹងកេងកងពីរ ចាប់ពីឆ្នាំ **២០១៦** រហូតដល់ **២០១៨**។ យើងអាចសង្កេតឃើញថា ចំនួនអតិថិជនមានការថយចុះ ពោលគឺនៅឆ្នាំ**២០១៦**មានចំនួន**៩២**នាក់ដោយប្រៀបធៀបជាមួយនឹងឆ្នាំ **២០១៧** ដែរមានចំនួន **៦៧** មានន័យថាចំនួនអតិថិជនមានការថយចុះចំនួន**២៥** នាក់ឬ **២៧%** ។ដោយឡែកនៅក្នុងឆ្នាំ**២០១៨**មានចំនួនអតិថិជនត្រឹមតែ**៥១**នាក់ដែរចំនួនអតិថិជននៅតែបន្តថយចុះរហូតដល់ **៣៧%**។

## ៤.២ ការវិភាគលើការផ្តល់ឥណទាន SME គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ

> ចំណុចខ្លាំង

បន្ទាប់ពីបានចុះទៅធ្វើកម្មសិក្សាស្រាវជ្រាវនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករលីមីតធីត រយៈពេលមួយខែរួចហើយក្រុមខ្ញុំបាទសង្កេតឃើញថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនេះមានចំនុចខ្លាំងខាងផ្នែកផ្តល់សេវាកម្មឥណទានជូនអតិថិជន។ បន្ថែមពីនេះទៀតគ្រឹះស្ថានក៏មានចំនុចខ្លាំងជាច្រើនទៀតដែលបាន ធ្វើឱ្យគ្រឹះស្ថាននេះមានកេរ្តិ៍ឈ្មោះនិងអាចពង្រីកវិសាលភាពរបស់ខ្លួននៅទូទាំងប្រទេស។ចំណុចខ្លាំងទាំងនោះរួមមាន ៖

- ហត្ថាកសិករលីមីតធីតមានមូលធនសរុប**១០៥.៤**លានដុល្លារអាមេរិចគិតត្រឹមឆ្នាំ២០១៧។
- មានការបើកនឹងពង្រីកសាខារហូតដល់១៧៨ដែលបម្រើឱ្យអតិថិជនបានទូទាំងប្រទេស។
- ការផ្តល់ឥណទានមានច្រើនជម្រើស ប្រាក់រៀល ប្រាក់បាត ប្រាក់ដុល្លារ។
- ទំហំឥណទានអាចខ្ចីបានរហូតដល់២០០០០០ដុល្លារអាមេរិចធៀបនិងរូបិយប័ណ្ណផ្សេង។
- មានបុគ្គលិកដែលរួសរាយ រាក់ទាក់និងប្រកបដោយទំនួលខុសត្រូវ។
- អត្រាការប្រាក់ទាបសមរម្យ។
- មានគោលការណ៍ច្បាស់លាស់ក្នុងការផ្តល់ឥណទាន។
- ហត្ថាកសិករ លីមីតធីត តែងតែផ្តល់ប្រឹក្សាទៅប្រជាពលរដ្ឋទូទៅដែលមានបញ្ហានិងសំនួរទាក់ទងវិស័យហិរញ្ញវត្ថុ។
- និតិវិធីក្នុងការផ្តល់ឥណទានមានភាពងាយស្រួលនិងស្របច្បាប់ប្រទេសកម្ពុជា។
- បុគ្គលិកទាំងអស់បានផ្តល់សេវាជូនអតិថិជន ដោយគិតគូរពីអតិថិជនធ្វើយ៉ាងណាកុំឱ្យអតិថិជនមានហានិភ័យ។
- តែងតែផ្តល់វគ្គសិក្សាដល់បុគ្គលិកដើម្បីឱ្យបុគ្គលិកបង្កើនសមត្ថភាពក្នុងវិស័យហិរញ្ញវត្ថុ។
- ប្រតិបត្តិការណ៍មានការចុះទៅជួបប្រាស្រ័យទាក់ទង់ជាមួយអតិថិជន ដើម្បីបង្កើនភាពស្និតស្នាលនិងផ្តល់យោបល់ក្នុងការគ្រប់គ្រងចំណូលជាដើម។
- ហត្ថាកសិករតែងតែ គោរពតាមគោលការណ៍របស់រាជរដ្ឋាភិបាលតាមរយៈការផ្តល់ឥណទានដែរមានប្រសិទ្ធភាព ដើម្បីជួយលើកស្ទួយជីវភាពរបស់ប្រជាជនក្នុងន័យកាត់បន្ថយភាពក្រីក្រ។
- រក្សាឯកសារ និងលិខិតស្នាមរបស់អតិថិជន បានសុវត្ថិភាព និងមានត្រឹមត្រូវ។
- កម្រិតហានិភ័យលើឥណទាន របស់ហត្ថាកសិករ មានកម្រិតតិចតួច ឬគ្មានហានិភ័យកើតឡើងលើការផ្តល់ឥណទានទេ។
- មុននឹងផ្តល់ឥណទាន ហត្ថាកសិករ តែងតែប្រាប់និតិវិធីផ្សេងៗដើម្បីឱ្យអតិថិជនងាយស្រួលក្នុងការសម្រេចចិត្ត ។
- ហត្ថាកសិករ តែងតែបង្កើតនូវអ្វីដែលថ្មីៗ ដើម្បីបំពេញតម្រូវការរបស់អតិថិជន

(កម្មវិធី Mobile App ជាដើម)។

- ហត្ថាកសិករ តែងតែមានកម្មវិធីចុះណែនាំក្នុងគោលបំណង ណែនាំពីផលិតផលទៅឱ្យអតិថិជន ជាពិសេសអតិថិជនគោលដៅ ។

➢ **ចំណុចខ្សោយ**

គ្រឹះស្ថានមីក្រូ ហត្ថាកសិករ លីមីតធីត គឺជាគ្រឹះស្ថានមួយដែលមាន កេរ្តិ៍ឈ្មោះល្បីល្បាញ និងមានប្រវត្តិយូរឆ្នាំមកហើយ ចំនុចវិជ្ជមានជាច្រើនដែលធ្វើឱ្យគ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត មានការអភិវឌ្ឍន៍ពីមួយឆ្នាំទៅមួយឆ្នាំ យ៉ាងណា ក៏ដោយទន្ទឹមនិងការរីកចម្រើននេះ ហត្ថាកសិករ ក៏មានចំនុចខ្សោយមួយចំនួន ដែរត្រូវឱ្យមានការពង្រឹងបន្ថែមទៀត ដើម្បីអាចឈរឈ្មោះបន្តទៅមុខទៀត។ ចំនុចខ្សោយទាំងនោះមាន ៖

- ការចំណាយលើសោហ៊ុយឥណទានទាំងអស់ ជាបន្ទុករបស់អតិថិជន។

- ចំណាយពេលវេលាយូរក្នុងការបំពេញសំណុំបែបបទឥណទាន។

- រាល់ការសងត្រលប់ដែលយឺតយ៉ាវរបស់អតិថិជន ត្រូវអោយមានការផាកពិន័យ។

- មូលដ្ឋានគ្រឹះក្នុងការផ្តល់កម្ចីទៅអោយអតិថិជន តម្រូវឱ្យអតិថិជនទាំងអស់មានវត្ថុបញ្ចាំ ជាហេតុដែលធ្វើឱ្យប្រជាជនដែលមានជីវភាពកម្រិតទាប មិនអាចប្រើប្រាស់កម្ចីបានទេ។

- តាមគោលការណ៍តម្រូវឱ្យប្រតិបត្តិការជាអ្នកវាយតម្លៃរាល់វត្ថុបញ្ចាំ ដែលជាហេតុធ្វើឱ្យកំហុស ក្នុងការវាយតម្លៃលើវត្ថុបញ្ចាំរបស់អតិថិជន។

- ទំហំឥណទានសហគ្រាសខ្នាតតូច និងមធ្យមមាននូវមានកម្រិតដែលធ្វើឱ្យអតិថិជនមានតម្រូវការទំហំឥណទានធំងាកទៅរកប្រើប្រាស់សេវាកម្មឥណទានរបស់ធនាគារវិញ។

# សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍

## សេចក្ដីសន្និដ្ឋាន

តាមរយៈការឆ្លងកាត់នូវការចុះកម្មសិក្សាស្រាវជ្រាវ អស់រយៈពេលកន្លងនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីធីត សាខាបឹងកេងកងទីពីរ ក្រោមប្រធានបទ "ការគ្រប់គ្រងឥណទានសហគ្រាសខ្នាតតូច និងមធ្យម" យើងសង្កេតឃើញថា គ្រឹះស្ថានពិតជាបានអនុវត្តទៅតាមគោលការណ៍របស់ធនាគារជាតិ ក៏ដូចជាការអនុម័តរបស់គណៈគ្រប់គ្រងរបស់ហត្ថាកសិករផងដែរ។ ចំពោះលំហូរនៃដំណើរការផ្ដល់ឥណទាន តាំងពីដំណាក់កាលដំបូងរហូតដល់ដំណាក់កាលចុងក្រោយ ដែលមានន័យថាតាំងពីអតិថិជនមកដាក់ពាក្យស្នើសុំខ្ចីឥណទាន រហូតដល់ឥណទានបានទៅដល់ដៃអតិថិជនដែលជាសេចក្ដីត្រូវការរបស់ពួកគាត់ គឺត្រូវឆ្លងកាត់ជាច្រើនដំណាក់កាល ហើយតម្រូវឲ្យមានការចូលរួមយ៉ាងម៉ត់ចត់ពីសំណាក់បុគ្គលិកជំនាញនូវក្នុងការវិភាគ ទៅលើឥណទានមួយនោះ ថាតើប្រវត្តិឥណទានរបស់អតិថិជនយ៉ាងម៉េចដែរ? គោលបំណងប្រើប្រាស់ឥណទាន ចំណូលរបស់ពួកគាត់ និងសុវត្ថិភាពឥណទាន ពីព្រោះរាល់ចំណុចទាំងអស់នេះពិតជាមានសារៈសំខាន់ណាស់ ហើយក៏ជាចំណែកមួយក្នុងការចូលរួមកាត់បន្ថយហានិភ័យឥណទានឲ្យកម្រិតអប្បបរិមា មុនពេលដែលអនុម័តឥណទានទៅកាន់អតិថិជន។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករអាចមានវត្តមាន ជោគជ័យចំពោះវិស័យហិរញ្ញវត្ថុ និងមានការរីកចម្រើននៅទូទាំងប្រទេសកម្ពុជាមកដល់សព្វថ្ងៃនេះ គឺឆ្លុះបញ្ចាំងពីការគាំទ្រយ៉ាងខ្លាំងពីសំណាក់អតិថិជនដែលតែងតែជឿជាក់ មានទំនុកចិត្តមកលើគ្រឹះស្ថាន ថាជាស្ថាប័នដែលស្វែងយល់អំពីតម្រូវការរបស់ខ្លួន។យ៉ាងណាមិញ ហត្ថាកសិករក៏នៅតែឈរនៅលើគោលជំហររបស់ខ្លួន និងព្យាយាមអភិវឌ្ឍន៍ខ្លួនតាមរយៈការរិះរកនូវយុត្តិសាស្ត្រថ្មីៗ ដើម្បីបំពេញសេចក្ដីត្រូវការរបស់អតិថិជន ក៏ដូចជាអាចធ្វើការប្រកួតប្រជែងដណ្ដើមចំណែកទីផ្សារផងដែរ។

## ការផ្ដល់អនុសាសន៍

ជាការពិតណាស់ ហត្ថាកសិករ ដែលជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយដែលទទួលបានភាពជោគជ័យ គឺមាននូវកត្តាសំខាន់ចំនួនពីររួមមានកត្តាបរិយាកាសខាងក្នុង និងកត្តាបរិយាកាសខាងក្រៅ។យោងលើការសរសេររបាយការណ៍កម្មសិក្សានេះ ក្រុមរបស់យើងខ្ញុំបានសង្កេតឃើញថា គ្រឹះស្ថានមាននូវចំណុចខ្លាំងជាច្រើនដូចជា ធនធានមនុស្ស យុទ្ធសាស្ត្រក្នុងការគ្រប់គ្រង ដើមទុន លក្ខណៈពិសេសនៃផលិតផល ការបម្រើសេវាកម្មជូនអតិថិជនប្រកបទៅដោយសេចក្ដីពេញចិត្តទំនុកចិត្ត។ទន្ទឹមនឹងនេះ ហត្ថាកសិករក៏នៅមានចំណុចមួយចំនួនដែលតម្រូវឲ្យគ្រឹះស្ថានយកទៅធ្វើការកែតម្រូវនិងធ្វើការអភិវឌ្ឍនូវចំណុចមួយចំនួនដូចជា៖

- គ្រឹះស្ថានគួរតែពិនិត្យកែសម្រួលនូវគោលការណ៍នីតិវិធីនៃផលិតផលជាពិសេស ផលិតផលឥណទានសហគ្រាសខ្នាតតូច និងមធ្យម។
- គ្រឹះស្ថានគួរតែកាត់បន្ថយចំណាយសាហ៊ុយឥណទាន ចំណាយលើការរៀបចំឯកសារផ្សេងៗ ដើម្បីទាក់ទាញអតិថិជនឲ្យប្រើប្រាស់ផលិតផលរបស់ខ្លួន។

- គ្រឹះស្ថានគួរតែសិក្សា និងអភិវឌ្ឍន៍ផលិតផល សេវាកម្មឱ្យបានរហ័សជាងនេះទៅទៀតធ្វើយ៉ាងណាបំពេញសេចក្តីត្រូវការរបស់អតិថិជន។

- ការផ្សព្វផ្សាយអំពីផលិតផល សេវាកម្មថ្មីៗរបស់ខ្លួនទៅកាន់អតិថិជន ក៏ជាចំណុចមួយដែលគ្រឹះស្ថានគួរតែពិចារណា។

- គ្រឹះស្ថានគួរតែពង្រឹងសមត្ថភាព និងជំនាញរបស់បុគ្គលិកបន្ថែម ។

- ការពង្រីកសាខា បន្ថែមទូរATM នៅតាមសាខា ឬទីសាធារណៈឲ្យច្រើនជាងនេះនៅទូទាំងប្រទេស។

# ឯកសារយោង

1. សៀវភៅគោលការណ៍ផ្តល់ឥណទានសហគ្រាសស្ទាតតូច និងមធ្យម របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកាសិករ លីមីតធីត ឆ្នាំ ២០១៧
2. របាយការណ៍ប្រចាំឆ្នាំ២០១៧ របស់គ្រឹះស្ថាមីក្រូហិរញ្ញវត្ថុ ហត្ថាកាសិករ លីមីតធីត
3. ឈាង ហ៊ុយ ការគ្រប់គ្រង់ឥណទាន

# ឯកសារលើគេហទំព័រ


- https://tradingeconomics.com/cambodia/gdp-growth-annual
  (retrieved 2019, Apr, 10 )
- (https://www.nbc.org.kh/about_the_bank/banking_terms.php)
  (retrieved 2019, Jun, 10 )
- https://www.calvertimpactcapital.org/blog/683-intro-to-mfis
  (retrieved 2019, Jun, 17 )
- (https://khemsarith.wordpress.com/blog/page/3/)
  (retrieved 2019, Jun, 22 )
- https://www.hkl.com.kh/kh
  (retrieved 2019, Jun, 23 )
- របាយការណ៍ប្រចាំឆ្នាំ ២០១៧ របស់គ្រឹះស្ថានមីក្រូ ហិរញ្ញវត្ថុ ហត្ថាកសិករលីមីតធីត
  (retrieved 2019, Jun, 24 )